ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ថ្ងៃ៧ មករា និង ការចងចាំ

◆ រាជវង្សានុវង្សនៃកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២១៧ ខែមករា ឆ្នាំ២០១៨

# ស្វែងរកការពិត

លេខ២១៧ ខែមករា ឆ្នាំ២០១៨

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ ថ្ងៃ៧ មករា និង ការចងចាំ ........................................ ១

**ផ្នែកឯកសារ**

◆ នៅ រី ក្លាក់ស៊ារស៊ើបការណ៍ឲ្យវៀតណាម ........................................ ៤

◆ ត្រិន ង៉ុកគាយ ពលទោផ្កាយ១ យោធាស្រុកកោះត្រល់ ........................................ ៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ មិនត្រឡប់ទៅស្រុកកំណើតដោយសារគ្មានមុខរបរ ........................................ ៩

◆ ឆាយ ម៉ឹន អតីតពេទ្យយោធាក្នុងរបបខ្មែរក្រហម ........................................ ១២

◆ អ្នកថតរូបទទួលគ្រឿងឥស្សរយស ........................................ ១៣

◆ វគ្គបណ្តុះបណ្តាលនិស្សិត ស្តីពីការបង្រៀនប្រវត្តិសាស្ត្រ ........................................ ១៧

◆ ការសិក្សាប្រវត្តិសាស្ត្រតាមរយៈភាពយន្តឯកសារ ........................................ ១៩

◆ ចំណាប់អារម្មណ៍របស់និស្សិតចំពោះភាពយន្តឯកសារ ........................................ ២០

◆ សិក្ខាសាលាអន្តរជាតិស្តីពីការពង្រឹងសមត្ថភាពការអប់រំ ........................................ ២២

◆ វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ ........................................ ២៨

◆ រឿងរ៉ាវរបស់ សុខ ស៊ីណន តាមរយៈប្រជាជនមូលដ្ឋាន ........................................ ៣២

**ផ្នែកច្បាប់**

◆ អំណះអំណាងមេធាវីការពារក្តីរបស់ នួន ជា ក្នុងការបិទបញ្ចប់ ....... ៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆ រាជវង្សានុវង្សនៃព្រះរាជាណាចក្រកម្ពុជា ........................................ ៤២

◆ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ........................................ ៤៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ រឿងរ៉ាវក្រុមគ្រួសារលោក ទេព ឌួង ........................................ ៥០

◆ ៧ មករា ១៩៧៩ ដល់ ៧ មករា ២០១៨ ........................................ ៥៣

◆ ព្រលឹងមាសម្តាយ ........................................ ៥៧




ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើតវិញក្រោយរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** : *សុខ វណ្ណៈ, វ៉ូនិត អារី, ហ៊ូលីយ៉ូ ដែលជ្រេស, ផេង ពង្សរ៉ាស៊ី, សែម ចិន្តា, ស សារិន, អ៊ុង វណ្ណា* ***អ្នកនិពន្ធនិងស្រាវជ្រាវ*** : *ឆេង វើង និង ហូ ជុនា* ***អ្នកបកប្រែ*** : *យូ វលក្ខណ៍* ***និពន្ធនាយកទូទៅ*** : *ឆាំង យុ* ***ជំនួយការនិពន្ធនាយក*** : *សោម ប៊ុនថន និង ឡុង ដានី* ***ក្រាហ្វិកកុំព្យូទ័រ*** : *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ*** : *សន ល័ក្ខ* **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, khmerrougehistory.org www.truthcambodia.com**

# ថ្ងៃ៧ មករា និងការចងចាំ

រាល់ឆ្នាំ រាជរដ្ឋាភិបាល បានប្រារព្ធទិវាជ័យជម្នះ ៧ មករា ហើយឆ្នាំនេះជាឆ្នាំខួបលើកទី៣៩ នៃការទទួលជ័យជម្នះលើរបបខ្មែរក្រហម ដែលបានគ្រប់គ្រងប្រទេសកម្ពុជា នៅចន្លោះពីថ្ងៃទី ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ ដែលបណ្តាលឲ្យប្រជាជនកម្ពុជាស្លូតត្រង់ប្រមាណជិតពីរលាននាក់ស្លាប់បាត់បង់ជីវិត ។

នៅក្នុងឱកាសនៃខួបលើកទី៣៩នេះ រាជរដ្ឋាភិបាលកម្ពុជា ទូរទស្សន៍ កាសែត និងបណ្តាញផ្សព្វផ្សាយជាច្រើន បានធ្វើអត្ថាធិប្បាយ និងសរសេរអត្ថបទដោយលើកឡើងអំណះអំណាងនានា ទាក់ទងការរំដោះប្រជាជនចេញពីរបបកាប់សម្លាប់ខ្មែរក្រហម ការខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធដែលខ្ទេចខ្ទាំក្នុងអំឡុងរយៈពេលជាងបីឆ្នាំនៃរបបនេះ រួមជាមួយការខិតខំប្រមែប្រមូល និងកសាងធនធានមនុស្ស ដែលស្ទើរតែបាត់បង់ទាំងស្រុងក្នុងរបបខ្មែរក្រហម ដើម្បីចូលរួមចំណែកក្នុងការកសាងសង្គមកម្ពុជាឲ្យបានប្រសើរឡើងវិញ ។ ប៉ុន្តែ ក៏មានមតិមួយចំនួនបានភ្ជាប់ហេតុផលនយោបាយផ្សេងៗ ដែលបណ្តាលឲ្យកងទ័ពវៀតណាមចូលមកគ្រប់គ្រងប្រទេសកម្ពុជារយៈពេល១១ឆ្នាំ (ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៨៩) និងបន្តឥទ្ធិពលរហូតមកដល់បច្ចុប្បន្ន ។



ឪពុកម្តាយរបស់ ប៊ុនថន នៅខេត្តស្វាយរៀង

ទោះបីមានទស្សនៈយល់ឃើញខុសគ្នាក៏ដោយ ក៏យើងមិនអាចបំភ្លេចចោលពីសោកនាដកម្មដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ដែលបណ្តាលឲ្យស្ទើរគ្រប់ក្រុមគ្រួសារនៃប្រជាជនកម្ពុជាព្រាត់ប្រាស់ បែកបាក់ និងស្លាប់បាត់បង់សមាជិកគ្រួសារជាទីស្រឡាញ់ និងធ្វើឲ្យសង្គមកម្ពុជាបែកបាក់រហូតមកដល់សព្វថ្ងៃ ។

ម្តាយខ្ញុំ រាជ សារ៉ាត អាយុ៦៥ឆ្នាំ រស់នៅជនបទក្នុងស្រុកចន្ទ្រា ខេត្តស្វាយរៀង តែងតែរំឭក និងចងចាំពីហេតុការណ៍រន្ធត់ដែលគាត់បានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ។ ម្តាយខ្ញុំ បានរស់ជីវិតដោយសារការរត់គេចខ្លួន ចំណែកឪពុកខ្ញុំ បានរស់ជីវិតដោយសារការលាក់ប្រវត្តិរូបជាទាហាន ក្នុងអំឡុងពេលកងទ័ពខ្មែរក្រហមគ្រប់គ្រងប្រទេសកម្ពុជា ។ ចំណែកបងប្រុសរបស់ម្តាយខ្ញុំម្នាក់ឈ្មោះ សាត ជាជាងឈើ គ្មានសំណាងបានរស់ជីវិតទេ ដោយសារខ្មែរក្រហមចោទគាត់ថា មានបងប្អូន និងម្តាយរត់ទៅនៅជាមួយយួន ។ ម្តាយខ្ញុំ បានរំឭកពីហេតុការណ៍ ដែលធ្វើឲ្យគាត់នៅតែចងចាំ នៅពេលដែលរត់គេចខ្លួនជាមួយបងប្អូន ។ ម្តាយខ្ញុំបានបន្តថា តែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ បងប្អូនជីដូនមួយរបស់គាត់ដែលដើរក្រោយគាត់បានក្លាយទៅជាបំណែកតូចៗ ដោយសារជាន់មីន ។ ម្តាយខ្ញុំឃើញតែក្រមាដែលបងប្អូនជីដូនមួយរបស់គាត់ទូរប៉ុណ្ណោះ ដែលហោះប៉ើងទៅលើអាកាសដោយសារកម្លាំងខ្យល់របស់មីន ។ ហេតុការណ៍នេះ បានធ្វើឲ្យម្តាយខ្ញុំរន្ធត់ និងចងចាំរហូតមកសព្វថ្ងៃ ។

រឿងរ៉ាវរបស់ ឪពុកម្តាយខ្ញុំ ដែលបានរៀបរាប់ខាងលើ ក៏មិនខុសពីរឿងរ៉ាវរបស់ជនរងគ្រោះ និងអ្នករួចរស់ជីវិតពីរបបខ្មែរក្រហមផ្សេងទៀតដែរ ហើយរឿងរ៉ាវទាំងនេះ គួរតែត្រូវបានចងចាំជារឿងរ៉ាវប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជា និងរបស់ជាតិទាំងមូល ដោយមិនភ្ជាប់នឹងហេតុផលនយោបាយ ។

**សោម ប៊ុនថន**

# ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩









# នៅ រី ភ្នាក់ងារស៊ើបការណ៍ឱ្យវៀតណាម

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព J០០០៣២*

នៅ រី ភេទប្រុស មានស្រុកកំណើតនៅភូមិត្នោត ឃុំត្នោត ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង។ មុនអង្គការចាប់ខ្លួន រី ជាភ្នាក់ងារស៊ើបការណ៍បម្រើឲ្យវៀតណាម ពីស្ថានភាពនៅកម្ពុជា។ នៅឆ្នាំ១៩៦២ រី បានធ្វើកិច្ចឲ្យទាហានវៀតកុង ឈ្មោះ ង្វៀង ប៊ិន នាទីសក្តិ១ នៅផ្សាររមេយ ជាប់ព្រំប្រទល់រវាងកម្ពុជា-វៀតណាម។ រហូតដល់១៩៧០ ង្វៀង ប៊ិន បានណែនាំ រី ឲ្យធ្វើការទាក់ទងជាមួយ ង្វៀង យូ នាទីស័ក្តិ២។ នៅឆ្នាំ១៩៧១ ទាហានយៀកកុងបានវាយចូលមក ពេលនោះ រី បានដាច់ការទាក់ទងជាមួយ ង្វៀង យូ ទើបមកភ្ជាប់ខ្សែកិច្ចជាមួយឈ្មោះ បុន នាទីស័ក្តិ៣ នៅបន្ទាយកំពង់រទេះ ក្នុងស្រុកកំពង់រោទ៍ ហើយរយៈពេលប្រហែលប្រាំខែក្រោយមកទើប បុន បានបញ្ចូល រី ជាខ្សែ សេ អ៊ី អា។ នៅឆ្នាំ១៩៧២ រី បានដាច់ខ្សែរយៈជាមួយ បុន ដោយសារបន្ទាយកំពង់រទេះ ត្រូវបានកងទ័ពកម្ពុជាវាយកម្ទេច។ ក្រោយមក រី បានរត់មករស់នៅក្នុងទឹកដីរំដោះរហូតដល់ឆ្នាំ១៩៧៥។

នៅដើមឆ្នាំ១៩៧៥ រី បានធ្វើការទាក់ទងជាមួយ ទឹម ជាប្រជាជនរស់នៅភូមិត្នោត និង សៅ នាទីប្រធានកងធំសហករណ៍ភូមិត្នោត។ បន្ទាប់មក រី បានទាក់ទងជាមួយឈ្មោះ អ៊ូ នាទីគណៈឃុំត្នោត តាមរយៈ សៅ។ ពេលនោះ អ៊ូ បានណែនាំ រី ឲ្យទៅជួបជនជាតិវៀតណាមឈ្មោះ ង្វៀង យៀក នាទីស័ក្តិ២។ នៅពាក់កណ្តាលឆ្នាំ១៩៧៥ ង្វៀង យៀក បានអប់រំ រី ឲ្យប្រឆាំងបក្ស



មន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង

កុម្មុយនីស្តកម្ពុជា ដោយពន្យល់ណែនាំ រី ថា បក្សកុម្មុយនីស្តកម្ពុជា បានបំបិទសិទ្ធិសេរីភាពរបស់ប្រជាជន បង្ខំឲ្យប្រជាជនធ្វើការគ្មានពេលសម្រាក ព្រមទាំងមិនឲ្យប្រជាជនហូបគ្រប់គ្រាន់ ។ បន្ទាប់ពីណែនាំរួចហើយ ង្វៀង យៀក បានឲ្យ រី ចូលរួមជាមួយកងទ័ពវៀតណាម ដើម្បីវាយបក្សកុម្មុយនីស្តកម្ពុជា និងចាត់តាំងបក្សជាថ្មី ទើបប្រជាជនមានសិទ្ធិសេរីភាព ។ ក្រោយមក ង្វៀង យៀក បានប្រគល់ភារកិច្ចឲ្យ រី ទៅស៊ើបការណ៍អំពីសកម្មភាពកងទ័ពបដិវត្តន៍កម្ពុជា និងប្រមូលកម្លាំងប្រឆាំងនឹងបដិវត្តន៍ ។ ក្រោយពីទទួលភារកិច្ចរួចហើយ រី បានចាប់ផ្តើមអនុវត្តផែនការ ព្រមទាំងបានរាយការណ៍ជាបន្តបន្ទាប់អំពីសកម្មភាពកងទ័ពបដិវត្តន៍ចេញចូលឬផ្លាស់ប្តូរ ។

នៅខែតុលា ឆ្នាំ១៩៧៧ ង្វៀង យៀក បានប្រគល់ភារកិច្ចថ្មីឲ្យ រី ដោយឲ្យកងកម្លាំងរបស់ រី ត្រៀមស្បៀង និងសម្ភារផ្សេងៗ សម្រាប់ឧបត្ថម្ភដល់កងទ័ពវៀតណាម ដើម្បីត្រៀមវាយកងទ័ពបដិវត្តន៍នាពេលខាងមុខ និងត្រៀមកម្លាំងសម្រាប់នាំផ្លូវកងទ័ពវៀតណាមឲ្យចូលវាយទៅតាមមុខសញ្ញា នៅក្នុងស្រុកកំពង់រោទ៍ នាចុងឆ្នាំ១៩៧៧ ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ ដដែល អ៊ូ បានចាត់តាំង រី និង សោ ឲ្យរៀបចំកម្លាំងពីរនាក់សម្រាប់នាំផ្លូវកងទ័ពវៀតណាមមានឈ្មោះ ឈុន នាំពីព្រំដែនចូលមកឃុំត្នោត និងឈ្មោះ ពែក នាំចូលពីមុខសញ្ញាឃុំចន្ទ្រា ។ បន្ទាប់ពី រី និង សោ បានរៀបចំកម្លាំង និងលាក់ស្បៀងសម្រាប់ត្រៀមបម្រុងប្រតិបត្តិការ ពេលនោះ ង្វៀង យៀក បានប្រាប់អំពីផែនការដែលកងទ័ពវៀតណាមត្រៀមវាយយកខេត្តកំពង់ចាម ស្វាយរៀង តាកែវ ចាប់ពីខែធ្នូ ឆ្នាំ១៩៧៧ រហូតដល់ខែមីនា ឆ្នាំ១៩៧៨ ។ នៅព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៧ យន្តហោះដប់គ្រឿងរបស់កងទ័ពវៀតណាមបានបាញ់រះក្នុងភូមិ បណ្តាលឲ្យប្រជាជនដែលរស់នៅក្នុងភូមិត្នោត ស្លាប់អស់មួយចំនួនរហូតដល់កងទ័ពវៀតណាមវាយចូលដល់សហករណ៍ត្នោតរីឯមុខសញ្ញានៅឃុំចន្ទ្រាវិញក៏វាយចូលដល់ដែរ ។ ពេលវាយមកដល់គោលដៅ ង្វៀង យៀក បានយកបក្ខពួករបស់ រី ឲ្យមកនៅមួយឡែក ឯប្រជាជននៅតាមផ្ទះដែលត្រូវរបួសបាក់ដៃជើង កងទ័ពវៀតណាមបានយកមកគម្រៀបនៅកណ្តាលផ្លូវ ។ រីឯប្រជាជនដែលសល់ពីការសម្លាប់ កងទ័ពវៀតណាមបានភ្ជង់នឹងកាំភ្លើងកៀរយកទៅប្រទេសវៀតណាម ប្រសិនបើប្រជាជនណារឹងរូសមិនព្រមទៅ កងទ័ពវៀតណាមបានចាប់ទាក់កអូសពីក្រោយរថក្រោះជាមិនខាន ។ ការកៀរប្រជាជនយកទៅនេះ កងទ័ពវៀតណាមបានឲ្យចាស់ៗដើរមួយប៉ែក ក្មេងៗដើរមួយប៉ែក និងនារីដើរមួយប៉ែក ។ នៅពេលទៅដល់ស្រុកបាក់ចិញ្ចៀន កងទ័ពវៀតណាមបានឲ្យប្រជាជនស្នាក់នៅក្នុងសាលាធំមួយដោយគ្មានបាយហូប ។ លុះព្រឹកឡើង កងទ័ពវៀតណាមជាង៥០នាក់ បានធ្វើបាបនារីៗដែលនៅសេសសល់ ។ មួយថ្ងៃក្រោយមក មានមេទាហានវៀតណាមពីរនាក់ ស្លៀកពាក់ស៊ីវិលបានដិះឡានហ្ស៊ីបមកអប់រំ រី និងប្រជាជនដែលកៀរមកថា បងប្អូនទាំងអស់មិនចាំបាច់ភ័យខ្លាចនោះទេ កងទ័ពវៀតណាមបានជួយរំដោះបងប្អូនហើយ ដូច្នេះយើងត្រូវរួបរួមគ្នាវាយបក្សកុម្មុយនីស្តកម្ពុជា ដោយឲ្យវៀតណាមគ្រប់គ្រងវិញ ។ រំលងបានប៉ុន្មានថ្ងៃ មានទាហានស័ក្តិ៤ម្នាក់ ឈ្មោះ ថាច់ សឺង និងទាហានស័ក្តិ៥ម្នាក់ទៀត (មិនស្គាល់ឈ្មោះ) បានហៅ រី, សោ, អ៊ូ, សេ, សៀន, ឆ្ងួយ, ពត់, ឆាន់ និង ទឹម ដែលជាខ្សែចាស់របស់ខ្លួន និងប្រជាជន១៨នាក់ទៀត យកទៅអប់រំដោយចាប់បង្ខំ ដោយមានគោលបំណងចាត់តាំងជាភ្នាក់ងារសម្រាប់ស៊ើបការណ៍អំពីសកម្មភាពនៅកម្ពុជា ។ ក្រោយពីអប់រំរួចហើយ ថាច់ សឺង បានប្រាប់ពីផែនការវាយយកខេត្តកំពង់ចាម ស្វាយរៀង និងតាកែវ ឲ្យបានក្នុងរយៈខែធ្នូ ឆ្នាំ១៩៧៧ រហូតដល់ខែមីនា ឆ្នាំ១៩៧៨ ខាងមុខនេះ ។ បន្ទាប់ពីចាត់តាំង និងប្រាប់ពីផែនការរួចហើយ ថាច់ សឺង បានសួរទៅកាន់បក្ខពួក រី និងប្រជាជន១៨នាក់ទៀតថា តើអ្នកទាំងអស់គ្នាព្រមទៅស៊ើបការនៅកម្ពុជាឬទេ? ពេលនោះគ្មាននរណាហ៊ានឆ្លើយថាព្រមឡើយ រហូតដល់ ថាច់ សឺង បានគម្រាមថា ប្រសិនបើអ្នកណាមិនព្រម គឺត្រូវយកទៅបាញ់ចោលអស់មួយពូជ ទើប រី និងបក្ខពួកព្រមទាំងប្រជាជនដទៃទៀតឆ្លើយថាព្រម ។

នៅចុងខែធ្នូ ឆ្នាំ១៩៧៧ ថាច់ សឺង បានបញ្ជូន រី និង ឆាន់ ព្រមទាំងទាហានវៀតណាម៤នាក់ទៀត ប្រដាប់ដោយកាំភ្លើងខ្លីមួយដើម កាំភ្លើងអាអ៊ែរ១៥-បួនដើម តេអូមួយគ្រឿង ត្រីវិស័យមួយ ផែនទីមួយ ពោងហែលទឹក៦ និងបាយជាង២០០កញ្ចប់ ។ នាថ្ងៃរសៀល រី និងបក្ខពួកបានដិះឡានមកព្រំដែនក្រែក ហើយ

ផាច់ សឺង បានប្រគល់ រី និងបក្ខពួកឲ្យទៅទាហានសក្តិ៣ ឈ្មោះ យ៉ាំង យឿង ដើម្បីរៀបចំផែនការចូលមកកម្ពុជា ។ ជាចុងក្រោយ ផាច់ សឺង និង យ៉ាំង យឿង បានអប់រំ រី និងបក្ខពួកបន្ថែមទៀត អំពីទិសដៅចូលទៅស៊ើបការណ៍ក្នុងខេត្តកំពង់ចាម និងប្រាប់ពីទីតាំង រថក្រោះ កាំភ្លើងធំ និងឈ្មោះមេបញ្ជាការនៅទីនោះ ។ ម្យ៉ាងទៀត ត្រូវចូលទៅទាក់ទងខ្មែរខាងក្នុង ដើម្បីប្រមូលកម្លាំងបង្កើតទ័ពក្នុង ព្រៃ សម្រាប់ត្រៀមវាយកម្ពុជាពីក្រោយ និងត្រូវពិនិត្យមើលពី មូលដ្ឋានឃ្លាំងសេដ្ឋកិច្ច ឃ្លាំងគ្រាប់ ឃ្លាំងស្បៀង ដើម្បីងាយស្រួល ដឹកយកចេញពេលកងទ័ពវៀតណាមវាយចូលដល់ ។ យ៉ាំង យឿង បានបញ្ជាក់ថា ត្រូវលាក់ការណ៍ដាច់ខាត ប្រសិនបើបដិវត្តន៍កម្ពុជា ចាប់បាន ក្នុងករណីណាក៏ដោយគឺមិនត្រូវសារភាពពីផែនការ និង ការចាត់តាំងរបស់វៀតណាមឡើយ ដោយឲ្យឆ្លើយថា ជាប្រជា ជនដែលវៀតណាមកៀរយកទៅ ដោយសារវៀតណាមធ្វើបាប ទើបរត់ត្រឡប់មកវិញ ។ ប្រាំមួយថ្ងៃក្រោយមក រី និងបក្ខពួកបាន ចេញដំណើរទៅកម្ពុជា ហើយបានឆ្លងកាត់តាមព្រៃក្រែកដើរ សំដៅទៅទិសខាងជើង អស់រយៈពេលជិតកន្លះខែទើប រី និងបក្ខពួក បានមកដល់ព្រៃស្រក នៅខាងជើងក្រុងកំពង់ចាម ស្ថិតក្នុងស្រុក កំពង់សៀម ដែលជាទីតាំងសម្រាប់ផែនការដែលបានកំណត់ ។ បន្ទាប់ពីមកដល់ទីតាំង រី និងបក្ខពួកបានរាយការណ៍ទៅ យ៉ាំង យឿង តាមរយៈតេអូជាប្រចាំ អំពីសភាពការណ៍យោធានៅខេត្ត កំពង់ចាមដែលក្តាប់បាន ។ រី និងបក្ខពួកបានរស់នៅក្នុងព្រៃស្រក អស់រយៈពេលប្រាំបីថ្ងៃ នៅថ្ងៃមួយ រី និងបក្ខពួកកំពុងហូបបាយ ថ្ងៃត្រង់ស្រាប់តែមានគ្រាប់កាំភ្លើងរបស់កងទ័ពកម្ពុជា បាញ់រះ មកលើក្បាលធ្វើឲ្យ រី និងបក្ខពួកភ័យស្លុតស្រឡាំងកាំង រកទាញ កាំភ្លើងបាញ់តបវិញមិនបាន ក៏រត់បែកគ្នាអស់ ចំណែក រី បានរត់ បែកតែម្នាក់ឯងហើយវង្វេងផ្លូវ រួចដើរចូលក្នុងសហករណ៍បុសពោរ ក៏ត្រូវបានអង្គការចាប់ខ្លួនបានតែម្តង គឺនៅថ្ងៃទី៩ ខែមីនា ឆ្នាំ ១៩៧៨ ។ **ហូ ថុនា**



កងទ័ពវៀតណាមចូលមកដល់មន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង នៅខែមករា ឆ្នាំ១៩៧៩ ។

# ត្រិន ង៉ុកតាយ ពលទោផ្កាយ១ យោធាស្រុកកោះត្រល់

***ដកស្រង់ចេញពីឯកសារចម្លើយសារភាព J០០០៣២***

ត្រិន ង៉ុកតាយ ភេទប្រុស មានស្រុកកំណើតនៅភូមិធីត្រិន ឃុំយឿងដុង ស្រុកកោះត្រល់ ខេត្តក្រមួនស ប្រទេសវៀតណាមខាងត្បូង ។ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ង៉ុកតាយ បានស្ម័គ្រចិត្តចូលបម្រើកងទ័ពវៀតណាម ។ ពេលនោះ ថ្នាក់លើបានចាត់តាំង ង៉ុកតាយ ឲ្យរៀនសូត្រវគ្គបច្ចេកទេសយោធា និងនយោបាយអស់រយៈពេលមួយខែ ដែលមានទីតាំងស្ថិតនៅក្នុងស្រុកកោះត្រល់តែម្តង ។ បន្ទាប់មកមានឈ្មោះ ត្រិន វ៉ុកស៊ី ហៅ ណាម ស៊ី នាទីអនុសេនីយ៍ផ្កាយ២ និងជាអនុប្រធានស្រុកកោះត្រល់ ព្រមទាំងមេបញ្ជាការផ្ទាល់របស់ ង៉ុកតាយ ដែលជាអ្នកដឹកនាំ ង៉ុកតាយ និងអ្នកផ្សេងទៀតក្នុងការរៀនសូត្រនេះ ។ ណាម ស៊ី បានលើកយកផ្នែកនយោបាយ មាគ៌ាយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តវៀតណាម ដែលជាបក្សឥណ្ឌូចិនពីមុនមកខុទ្ទេសនាមថា ហូជីមិញ បានបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិនចាប់តាំងពីឆ្នាំ១៩៣០ សម្រាប់ទុកឲ្យវៀតណាមយើងសព្វថ្ងៃនេះ ។

ណាម ស៊ី បានបន្ថែមថា យើងជា រៀមច្បងគេនៅឥណ្ឌូចិន ហើយមាគ៌ាជាយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តឥណ្ឌូចិន ត្រូវតែបង្កើតសហព័ន្ធឥណ្ឌូចិនឡើង នៅពេលដែលប្រទេសទាំងអស់នៅក្នុងឥណ្ឌូចិនបានរំដោះពីចក្រពត្តិ ។ មិនត្រឹមតែប៉ុណ្ណោះ ណាម ស៊ី



បានបញ្ជាក់ថា ចំពោះយើងជាជនជាតិវៀតណាម និងជាវៀមច្បង គឺត្រូវតែគ្រប់គ្រងត្រួតត្រាប្រទេសដែលជាប្អូនៗ នៅក្នុងសហព័ន្ធឥណ្ឌូចិននេះ ។

នៅខែមេសា ឆ្នាំ១៩៧៥ ប្រទេសទាំងអស់នៅឥណ្ឌូចិនត្រូវបានរំដោះពីនឹមចក្រពត្តិអាមេរិក ពេលនោះ ណាម ស៊ី បានលើកយកបណ្តាំ ហូ ជីមិញ មកអនុវត្តដោយចាប់បង្ខំប្រទេសប្អូនៗឲ្យរួមគ្នាធ្វើជាសហព័ន្ធឥណ្ឌូចិនឡើង ។ ប៉ុន្តែ ប្រទេសកម្ពុជាដែលជាប្អូនមួយដែរ បែរជាមិនព្រមធ្វើតាម និងមិនព្រមដើរតាមបក្សកុម្មុយនីស្តវៀតណាមយើង ។ ប្រទេសកម្ពុជាបានដើរតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តមួយផ្សេងទៀត ដាច់ដោយឡែកពីគោលគំនិតនៃបណ្តាំ ហូជីមិញ យើងទៅវិញ ។ ដូច្នេះ ណាម ស៊ី បានបញ្ជាក់ថា បក្សកុម្មុយនីស្តវៀតណាមយើងត្រូវតែវាយបង្ខំកម្ពុជា ឲ្យចូលជាសហព័ន្ធឥណ្ឌូចិនទាល់តែបាន ដោយ ណាម ស៊ី លើកឡើងថា កងកម្លាំងប្រមូលផ្តុំរវាងកងទ័ពវៀតណាមខាងជើង និងខាងត្បូងបានស្រុះស្រួលគ្នារួចរាល់ហើយ ដូចនេះយើងត្រូវវាយប្រទេសកម្ពុជាឲ្យចុះញ៉មព្រមចូលសហព័ន្ធឥណ្ឌូចិន ដែលមានវៀតណាមយើងជាអ្នកគ្រប់គ្រង ។ម្យ៉ាងទៀត ណាម ស៊ី បានក្រើនរំលឹកទៅបក្ខពួករបស់ខ្លួនថា ប្រសិនបើយើងវាយបានប្រទេសកម្ពុជា ឥទ្ធិពលរបស់ប្រទេសវៀតណាមទាំងផ្នែកនយោបាយ និងយោធា ត្រូវបានជះឥទ្ធិពលទៅលើអាស៊ីអាគ្នេយ៍ អ៊ីដែលពិសេសជាងនេះទៅទៀត ប្រទេសដែលនៅក្នុងឥណ្ឌូចិន មិនចាំបាច់មានព្រំដែនអ្វីទៀតនោះទេ ។ ឥណ្ឌូចិនត្រូវតែមានប្រទេសតែមួយ មានប្រជាជនតែមួយ រដ្ឋអំណាចតែមួយកងទ័ពតែមួយ ដែលប្រទេសវៀតណាមយើងជាអ្នកដឹកនាំ ។ ជាពិសេស ភោគទ្រព្យនៅកម្ពុជា ត្រូវធ្លាក់ក្នុងកណ្តាប់យើងដូចជា ព្រៃឈើ បឹងបួរត្រីសាច់ដីស្រែដ៏មានជីជាតិ កៅស៊ូ និងរ៉ែជាដើម ។

បន្ទាប់ពីរៀនសូត្រចប់ ង៉ុកតាយ ត្រូវបានថ្នាក់លើចាត់តាំងឲ្យនៅការពារសាលាស្រុកកោះត្រល់ ។ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៧៨ ឈ្មោះ អែម ចឹមក្វាត នាទីអនុសេនីយ៍ផ្កាយ១ និងឈ្មោះ ង៉ៀង វ៉ាន់ដូវ នាទីអនុសេនីយ៍ បានហៅ ង៉ុកតាយ និងបក្ខពួកដើម្បីប្រគល់ភារកិច្ចឲ្យធ្វើ ដោយចាត់តាំង ង៉ុកតាយ ធ្វើជាអ្នកស៊ើបការណ៍នៅកោះពូលូវ៉ៃ ដែលស្ថិតនៅក្នុងប្រទេសកម្ពុជា ។ ណាម ស៊ី បាននាំយកអាជ្ញាសឹកចាត់តាំងពីវរសេនីយ៍ផ្កាយ១ ឈ្មោះ ណាម លន់ នាទីលេខាស្រុកមកប្រគល់ឲ្យ ង៉ុកតាយ, អែម ចឹមក្វាត និង ង៉ៀង វ៉ាន់ដូវ ដើម្បីចាត់តាំងអ្នកទាំងអស់នោះ ទៅស៊ើបការណ៍នៅកោះពូលូវ៉ៃជាបន្ទាន់ ។ ណាម ស៊ី បានណែនាំ ង៉ុកតាយ និងបក្ខពួកថា ត្រូវរកទីតាំងបោះទ័ពកម្ពុជាឲ្យឃើញ និងត្រូវស៊ើបអំពីកប៉ាល់ថា តើមានធុនអ្វីខ្លះ ហើយមានប៉ុន្មានគ្រឿង មានកាំភ្លើងអ្វីខ្លះ និងត្រូវក្តាប់សភាពការណ៍នៅកោះពូលូវ៉ៃប្រចាំថ្ងៃឲ្យបាន ។ បន្ទាប់ពី ង៉ុកតាយ និងបក្ខពួកទទួលភារកិច្ចរួចរាល់ហើយ ក៏បានចេញដំណើរទៅកោះពូលូវ៉ៃ ហើយបានក្លែងខ្លួនធ្វើជាអ្នកនេសាទត្រីដោយជិះទូកម៉ាស៊ីនលេខ៦៨៥ ឆ្ពោះទៅកោះពូលូវ៉ៃ ។ នាពេលនោះ ង៉ុកតាយ និងបក្ខពួកបានជិះទូកជិតទៅដល់កោះ ស្រាប់តែមានកប៉ាល់កម្ពុជាព័ទ្ធជុំវិញ ង៉ុកតាយ និងបក្ខពួក រួចបានចាប់ខ្លួនយកទៅនៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៨ ។ **ហ្វូ ថុនា**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.d.dccam.org*

# មិនត្រឡប់ទៅស្រុកកំណើតដោយសារគ្មានមុខរបរ

ខឹម ប៊ុនថូ ភេទប្រុស មានស្រុកកំណើតនៅភូមិតាភេង ឃុំស្អាង ស្រុកស្អាង ខេត្តកណ្ដាល ។ ថុន មានប្រពន្ធឈ្មោះ សុខ ណា និងមានកូនចំនួន៧នាក់ (ប្រុស៤ ស្រី៣នាក់) ។ ប៊ុនថូ មានបងប្អូនបង្កើត៥នាក់ ប៉ុន្តែស្លាប់២នាក់ក្នុងរបបខ្មែរក្រហម ។

កាលពីសង្គមចាស់ ប៊ុនថូ រៀនបានបន្តិចបន្តួចដោយសារកាលណោះ គាត់កំព្រាឪពុកម្ដាយ នៅក្នុងវ័យ១៣ឆ្នាំ (ឪពុកម្ដាយប៊ុនថូ ស្លាប់នៅសម័យសង្គមរាស្ត្រនិយម) ។

នៅឆ្នាំ១៩៧០ ប៊ុនថូ បានស្នាក់នៅវត្តស្អាងស្រែ អស់រយៈពេលបីឆ្នាំ ទើបគាត់ចាកចេញពីវត្តទៅចូលធ្វើយោធាក្នុងកងពិសេសនៅក្នុងកងពល១១ ដែលមានអ្នកគ្រប់គ្រងឈ្មោះ សោម ។ ប៊ុនថូ បានធ្វើការជាមួយ សោម អស់រយៈពេលមួយឆ្នាំ ក្រោយមក គាត់ក៏ត្រូវរបួស និងពិការជើង ដោយសារវាយប្រយុទ្ធជាមួយទាហានលន់នល់ ។ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងយោធាខ្មែរក្រហមទទួលបានជ័យជម្នះទូទាំងប្រទេស ពេលនោះ ខ្មែរក្រហមបានចាត់តាំង ប៊ុនថូ ឲ្យនៅមន្ទីរពិការ ។ ប៊ុនថូ ធ្វើការនៅមន្ទីរពិការរហូតដល់ឆ្នាំ១៩៧៦ ទើបអង្គការបានដកគាត់ឲ្យមកធ្វើពេទ្យវិញ ។

នៅឆ្នាំ១៩៧៧ ប៊ុនថូ ត្រូវបានអង្គការចាប់គូរឲ្យរៀបការដែលកាលណោះមានប្អូនគូរ ដែលសុទ្ធតែត្រូវអង្គការចាប់បង្ខំ ។ ចាប់ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយប្រយុទ្ធជាមួយយោធាខ្មែរក្រហមនៅខេត្តរតនៈគិរី មណ្ឌលគិរី និងខេត្តព្រៃវែង ពេលនោះ កងទ័ពខ្មែរក្រហមបានត្រូវរបួស និង ស្លាប់ជាច្រើននាក់ ។

ប៊ុនថូ បានបន្តថា មានអ្នករបួសខ្លះ ពេលមកដល់មន្ទីរពេទ្យស្លាប់ក៏មាន ដោយសារនៅតាមផ្លូវមេរោគបានឆ្លងតាមមុខរបួសធ្វើឲ្យពិបាកព្យាបាល ។ រហូតដល់ឆ្នាំ១៩៧៩ ពេលដែលខ្មែរក្រហមត្រូវបានផ្ដួលរំលំ ដោយកងទ័ពវៀតណាម និងកងទ័ពរណសិរ្ស ពេលនោះ ប៊ុនថូ បានរត់គេចខ្លួនជាមួយនឹងបក្ខពួកដោយជិះម៉ូតូចេញពីភ្នំពេញ កាត់តាមផ្លូវជាតិលេខ៤ ។ ពេលទៅដល់ខត្តុង ប៊ុនថូ បានឮស្នូរកាំភ្លើងប្រយុទ្ធគ្នាកាន់តែកៀក ធ្វើឲ្យគាត់ភ័យខ្លាច និងព្រួយបារម្ភយ៉ាងខ្លាំង ។ ប៊ុនថូ បានទុកម៉ូតូចោល រួចរត់ចូលទៅក្នុងព្រៃ ។ ប៊ុនថូ បានធ្វើដំណើរនៅក្នុងព្រៃអស់រយៈពេលជាងបីខែ ទើបទៅដល់ព្រំដែនកម្ពុជា-ថៃ នៅម្ដុំស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ប៊ុនថូ បានសម្ងំលាក់ខ្លួននៅក្នុងព្រៃតាមព្រំដែន ជាមួយយោធាខ្មែរក្រហមជាច្រើននាក់ទៀត ដើម្បីធ្វើសកម្មភាពប្រយុទ្ធប្រឆាំងនឹងកងទ័ពវៀតណាម ប៉ុន្តែពេលនោះមិនសូវមានស្បៀងសម្រាប់ផ្គត់ផ្គង់ដល់កងយោធាទេ ។ នៅឆ្នាំ១៩៨០-៨១ កងយោធាខ្មែរក្រហមបានរៀបចំឲ្យមានប្រជាជនសារឡើងវិញ ដោយថ្នាក់លើបានប្រកាសថា ប្រសិនបើយោធាណាចង់ឈប់ ហើយមករស់នៅជាប្រជាជនសាមញ្ញវិញ គឺអាចឈប់បាន ប៉ុន្តែពេលនោះគ្មានយោធាណាម្នាក់និយាយថាចង់ឈប់ទេ ។

ក្រោយមក ប្រជាជនដែលរស់នៅក្នុងស្រុកម៉ាឡៃ បានទន្ទ្រានព្រៃដើម្បីសង់លំនៅដ្ឋាន ទើបមានយោធាមួយចំនួនបានលាឈប់មករស់ក្នុងជីវភាពជាប្រជាជនវិញ ។ នៅអំឡុងពេលនោះក៏មានប្រជាជនដែលកាប់ព្រៃឆ្ការព្រៃ បានជាន់មីនស្លាប់ និងរបួសជាច្រើននាក់ដែរ ។

រហូតមកដល់ឆ្នាំ១៩៩៨ កងយោធាខ្មែរក្រហមនៅម៉ាឡៃបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ពេលនោះ ប៊ុនថូ មិនបានត្រឡប់ទៅរស់នៅស្រុកកំណើតរបស់ខ្លួនទេ ដោយគាត់យល់ថា នៅស្រុកកំណើតពិបាកក្នុងការប្រកបរបររកស៊ី ដោយមានតែរបរនេសាទប៉ុណ្ណោះ ដែលខុសពីនៅស្រុកម៉ាឡៃដែលមានចំនួនប្រជាជនសមល្មមបង្កឲ្យមានភាពងាយស្រួលក្នុងការប្រកបរបររកស៊ី ។ ម្យ៉ាងទៀត ប្រសិនបើគាត់គ្មានដើមទុនរកស៊ី គាត់អាចស៊ីឈ្នួលឲ្យថៅកែ ឬអាចបេះផ្លែឈើ និងបន្លែយកទៅលក់ ។ ដូច្នេះហើយ ទើប ប៊ុនថូ និងប្រពន្ធបានសម្រេចចិត្តកសាងជីវិតថ្មីរស់នៅក្នុងស្រុកម៉ាឡៃ ចាប់តាំងតែពីពេលនោះមក ។

**ហូ ថុនា**

# ការិយាល័យព័ត៌មានសាធារណៈ

*“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អន វណ្ណារ៉ា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthvannara@dccam.org ។*





















# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ : ០០ ព្រឹក*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ស៊ាង ចិន្តា ទូរសព្ទលេខ ៖ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល ៖ truthchenda.s@dccam.org*

# ឆាយ ម៉ឺន អតីតពេទ្យយោធាក្នុងរបបខ្មែរក្រហម

***អំពីគ្រួសារ និងការសិក្សា***

ឆាយ ម៉ឺន កើតនៅឆ្នាំ១៩៦៤ នៅភូមិត្រោយឆ ឃុំរាក់ជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង ។ ម៉ឺន មានម្តាយឈ្មោះ ទុយ ម៉ន និងឪពុកឈ្មោះ ឆាយ មិញ ។ ម៉ឺន មានបងប្អូន៧នាក់ ប៉ុន្តែជាអកុសលបងប្រុសម្នាក់ឈ្មោះ ឆាយ ម៉ុត ត្រូវបានខ្មែរក្រហមសម្លាប់ក្រោមបទចោទថា ក្បត់អង្គការ ដោយសារបងប្រុសរបស់ ម៉ឺន នៅភូមិភាគបូព៌ាក្រោមការគ្រប់គ្រងរបស់ សោ ភឹម ។ ម៉ឺន រៀនបានត្រឹមថ្នាក់ទី១០ (សង្គមចាស់) ។

***សកម្មភាពមុនឆ្នាំ ១៩៧៥***

បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ឆ្នាំ ១៩៧០ ម៉ឺន បានឈប់រៀនដោយសារពេលនោះសាលារបស់ ម៉ឺន មិនមានគ្រូបង្រៀន ។ ម៉ឺន បានជួយធ្វើកិច្ចការឪពុកម្តាយ ហើយនៅឆ្នាំ ១៩៧៤ ម៉ឺន ក៏បានចាប់ផ្តើមចូលបម្រើបដិវត្តន៍ខ្មែរក្រហម ដែលនៅពេលនោះ ម៉ឺន បានបម្រើការងារជាកងឈ្លបឃុំ ។ ម៉ឺន ធ្វើជាកងឈ្លបឃុំ បានរយៈពេល៦ខែ គាត់ត្រូវបានអង្គភាពបញ្ជូនឲ្យធ្វើការងារនៅយោធាស្រុកបាភ្នំ ដែលមាននាទីជាយុទ្ធជនតស៊ូប្រឆាំង នឹងរដ្ឋាភិបាល លន់ នល់ ។ នៅខែមីនា ឆ្នាំ១៩៧៥ ម៉ឺន បានត្រូវរបួសក្នុងអំឡុងពេលប្រយុទ្ធជាមួយកងទ័ព លន់ នល់ នៅខាងកើតទន្លេ (ជិតអ្នកលឿង) ហើយគាត់ត្រូវបានបញ្ជូនឲ្យទៅសម្រាកនៅមន្ទីរពេទ្យអ្នកលឿង ។

***បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច (១៩៧៥ - ១៩៧៩)***

បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច នៅឆ្នាំ១៩៧៥ ម៉ឺន ត្រូវបានបញ្ជូនឲ្យទៅការពារនៅព្រំប្រទល់កម្ពុជាវៀតណាម ស្ថិតនៅក្នុងកងពល៨០៥ ដែលមាន រីម ជាប្រធានកងពល ។ ស្ថានភាពនៅព្រំដែនកម្ពុជា-វៀតណាម ក្នុងភូមិភាគបូព៌ា ឆ្នាំ១៩៧៥ ដល់ ១៩៧៦ មានការវាយប្រយុទ្ធគ្នាបន្តិចបន្តួចប៉ុណ្ណោះ ។ ប៉ុន្តែ ចាប់ពីឆ្នាំ១៩៧៧ ដល់ ១៩៧៩ នៅភូមិភាគបូព៌ា មានការប្រយុទ្ធគ្នាកាន់តែខ្លាំងឡើងរវាងកងទ័ពបដិវត្តន៍ខ្មែរក្រហម និងកងទ័ពវៀតណាម ហើយកងទ័ពទាំងសងខាងបានបាត់បង់ជីវិតដូចគ្នា ។

នៅពាក់កណ្តាលឆ្នាំ ១៩៧៧ ម៉ឺន ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅរៀនវិជ្ជាពេទ្យនៅខេត្តព្រៃវែង រយៈពេលជិតមួយឆ្នាំ ទើបត្រឡប់ទៅព្យាបាលកងទ័ពនៅព្រំដែនវិញ ។ ម៉ឺន នៅព្រំដែនបានមួយរយៈ ក៏កងទ័ពវៀតណាមវាយយកបានភូមិភាគបូព៌ា និងបានវាយជាបន្តបន្ទាប់រហូតដល់របបខ្មែរក្រហមដួលរលំ ។

***ជីវិតក្រោយរបបខ្មែរក្រហម***

បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានដួលរលំ នៅឆ្នាំ១៩៧៩ ម៉ឺន បានត្រឡប់ទៅរស់នៅស្រុកកំណើតវិញ ។ នៅស្រុកកំណើតបាន រយៈពេលមួយឆ្នាំ ម៉ឺន បានសម្រេចចិត្តចាកចេញពីស្រុកកំណើត ទៅរកស៊ីនៅព្រំដែនខ្មែរថៃ ដោយសារមិនមានមុខរបររកស៊ីនៅស្រុកកំណើត និងមានជីវភាពខ្វះខាត ។ ពេលទៅដល់ព្រំដែនខ្មែរ-ថៃ ម៉ឺន បានរកស៊ីរត់ពន្ធលក់ក្រណាត់ សារុង និងបារី នៅជិតភ្នំឆ័ត្រ ។

នៅឆ្នាំ១៩៨១ ម៉ឺន បានចូលបម្រើការងារជាពេទ្យរបស់កងទ័ពខ្មែរក្រហមនៅតំបន់ភ្នំឆ័ត្រ ។ រហូតមកដល់ឆ្នាំ១៩៨៣ ម៉ឺន បានត្រឡប់ទៅបម្រើការងារជាពេទ្យ នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យវិញ ។ នៅឆ្នាំ១៩៨៥ ម៉ឺន បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយ ឃួន អច ហើយប្រាំឆ្នាំក្រោយមក គាត់ក៏លាឈប់ពីយោធាខ្មែរក្រហម ដោយសារអស់ជំនឿចិត្តលើការដឹកនាំរបស់ខ្មែរក្រហម ។

សព្វថ្ងៃ ម៉ឺន មានកូន៧នាក់ (ប្រុស៤ ស្រី៣) រស់នៅឃុំផ្កាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ដោយប្រកបរបរជាកសិករ និងដើរព្យាបាលជំងឺស្រាលៗដល់ប្រជាជននៅក្នុងភូមិទៅតាមចំណេះដឹង និងបទពិសោធដែលគាត់ធ្លាប់បានរៀននៅក្នុងរបបខ្មែរក្រហម ។

**ឃាង សេងហឿន**

# អ្នកថតរូបទទួលគ្រឿងឥស្សរយស

ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សព្វព្រះរាជហរទ័យប្រោសប្រទានគ្រឿងឥស្សរយសថ្នាក់ ធិបឌិន្ទ ដល់ អ៊ូច មករា ទាក់ទងស្នាដៃថតរូបក្នុងសៀវភៅ «រាជវង្សានុវង្ស នៅកម្ពុជា» ។

អ៊ូច មករា តែងតែមានក្តីស្រមៃក្លាយជាអ្នកថតរូប និងអ្នកផលិតខ្សែភាពយន្តតាំងពីនៅវ័យក្មេង ។ ក្តីស្រមៃរបស់ មករា បានលេចឡើងកាន់តែច្បាស់តាមរយៈការខិតខំប្រឹងប្រែង រហូតដល់ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សព្វព្រះរាជហរទ័យប្រោសប្រទានគ្រឿងឥស្សរយសថ្នាក់ ធិបឌិន្ទ ដល់ អ៊ូច មករា ក្នុងស្នាដៃថតរូបក្នុងសៀវភៅ «រាជវង្សានុវង្សនៅកម្ពុជា» ។

មករា កើតនៅខែកក្កដា ឆ្នាំ១៩៨៩ នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ ក្នុងគ្រួសារដែលមានឪពុកម្តាយជាអ្នកស្រែចម្ការ ។ ឪពុកម្តាយ មករា បានរស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបាន


អ៊ូច មករា ថតរូបនៅព្រះបរមរាជវាំង

គ្រប់គ្រងប្រទេសកម្ពុជា ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ នៅក្នុងរបបនោះ ប្រជាជនប្រមាណជាងពីរលាននាក់ ត្រូវបានសម្លាប់ រីឯអ្នករស់រានមានជីវិតភាគច្រើន ក៏នៅតែបន្តរងការឈឺចាប់ផ្នែករាងកាយ និងផ្លូវចិត្ត ។ ឥទ្ធិពលនៃសង្គ្រាម អំពើឃោរឃៅ ការបង្អត់អាហារ នៅតែជាស្រមោលអន្ធកាលដែលតែងតែមកតាមលងឪពុកម្តាយរបស់ មករា ក៏ដូចជាប្រជាជនដទៃទៀត ដែលបានរួចជីវិតបន្ទាប់ពីរបបនេះ ។

ឪពុកម្តាយ មករា បានដាក់ឈ្មោះឲ្យ មករា ដោយយោងទៅតាមភាសាបាលីដែលពាក្យ «មករា» មានន័យថា សត្វនាគ រឺស្តេចសត្វ នៅក្នុងទឹកដែលសំដៅទៅលើខែទីមួយនៃឆ្នាំខ្មែរ ។ មករា ក៏ដូចជាក្មេងឯទៀតដែរ ដែលកើតក្រោយរបបខ្មែរក្រហម បានមើលឃើញពីផលប៉ះពាល់នៃរបបនេះ មកលើការរស់នៅ និងជីវភាពគ្រួសាររបស់គាត់ ។ ឪពុក មករា ដែលបានរងគ្រោះនាសម័យនោះ បានប្រើប្រាស់សុរាដើម្បីបំភ្លេចនូវការឈឺចុកចាប់ដែលគាត់បានទទួលរង ។ ក្រោយមក ដោយសារការរស់នៅមិនចុះសម្រុងគ្នា ម្តាយរបស់ មករា ក៏បានចាក់ចេញពីឪពុក ដែលបន្សល់នូវការចងចាំមួយសម្រាប់ មករា គឺការអស់សង្ឃឹមយ៉ាងខ្លាំងនៅក្នុងជីវិត ។

ដោយសារជីវភាពក្រីក្រ ទើប មករា និងម្តាយ បានផ្លាស់ទីលំនៅពីកន្លែងមួយ ទៅកន្លែងមួយទៀត ដើម្បីជៀសផុតពីសេចក្តីស្លាប់ ។ ភាពទីទ័លក្រគឺជាអ្វីដែល មករា និងម្តាយ បានជួបប្រទះរៀងរាល់ពេល ហើយ មករា មិនដឹងថាត្រូវធ្វើបែបណាដើម្បីជួយរំលែកទុក្ខពីម្តាយបាននោះទេ ។ ពេលរៀនដល់ថ្នាក់ទី១០ មករា ក៏បានសម្រេចចិត្តចេញរកការងារដើម្បីជួយផ្គត់ផ្គង់គ្រួសាររបស់គាត់ ។ ដំបូង មករា បានធ្វើការឲ្យគ្រួសារមិត្តភក្តិរបស់គាត់ ជាថ្នូរដើម្បីទទួលបានអាហារហូប និងផ្ទះស្នាក់នៅ ។ មករា ប្រៀបបីដូចជាមនុស្សដែលគ្មានគោល ពីព្រោះគាត់មិនបានកំណត់ក្តីស្រម័យជាក់លាក់សម្រាប់ខ្លួននាពេលនោះទេ ។ ប៉ុន្តែភាពគ្មានគោលមួយ

នេះត្រូវបានបាត់ទៅវិញ នៅកំឡុងពេលដែលមិត្តភក្តិរបស់ មករា បានណែនាំ មករា ទៅអោយបងប្រុសរបស់គេ នៅការិយាល័យមួយដែលមានឈ្មោះថា ផលិតកម្ម ខ្មែរមេគង្គ ដែលពេលនោះ មករា ត្រូវបានណែនាំឲ្យស្គាល់នូវពិភពផលិតខ្សែភាពយន្ត ។

ការត្រៀមខ្លួនរបស់ មករា មកកាន់វិស័យភាពយន្តនេះ នៅមានកម្រិតនៅឡើយនាពេលនោះ ។ ដោយសារតែភាពទីទាល់ក្រដូចនេះ មករា មិនបានរៀនសូត្រ ឬហ៊ឹកហាត់នូវជំនាញមួយនេះទេ ។

មករា គ្មានអ្វីក្នុងខ្លួនក្រៅតែអំពីក្តីស្រមៃនោះទេ ក៏ប៉ុន្តែម្តាយរបស់ មករា ធ្លាប់បានប្រាប់ មករា ថា សូមកុំបោះបង់ចោលនូវក្តីស្រមៃដែលខ្លួនមាន ទោះក្នុងកាលៈទេសៈណាក៏ដោយ ។ បន្ទាប់ពីបញ្ចប់ថ្នាក់វិទ្យាល័យ មករា ក៏បានដាក់ពាក្យស្នើរ៍ចិត្តនៅកន្លែងការងារមួយ ហើយក៏ទទួលបាននូវភាពទុកចិត្តអំពីសំណាក់អ្នកធ្វើការមុនៗនៅទីនោះ ។ បន្ទាប់មក មករា ក៏ត្រូវបានជ្រើសរើសជាលេខានៅផលិតកម្មនោះ ហើយ មករា ត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកត្រួតពិនិត្យសំឡេងនៅក្រៅឆាក ។ មករា តែងតែមានក្តីស្រមៃចង់ក្លាយជាអ្នកថតរូបជំនាញ និងជាផលិតករខ្សែភាពយន្ត ប៉ុន្តែដោយសារកង្វះខាតដែលមិនបានរៀនដូចគេឯទៀត ទើប មករា បានប្រើប្រាស់នូវពេលវេលាដែលខ្លួនមានទាំងអស់ដើម្បីរៀនសូត្រអំពីវិស័យនេះដោយខ្លួនឯង ។ មករា បានប្រើប្រាស់បណ្តាញសង្គមដែលមានឈ្មោះថា យូធ្យូប និង គេហទំព័រនានាក្នុងការរៀនសូត្រ ។ នៅក្នុងម៉ោងការងារ មករា បានត្រៀមចិត្តយ៉ាងមោះមុតថា នឹងរៀនសូត្រឲ្យបានច្រើនពីអ្នកនៅជុំវិញខ្លួនជាពិសេសពី ម៉ាធ្យូ រូប៊ីនសុន ដែលជាផលិតករ និងជាអ្នកដឹកនាំរឿងប្រចាំផលិតកម្ម ខ្មែរមេគង្គ ។ រយៈពេលកន្លងមក ការខិតខំប្រឹងប្រែងរបស់ មករា ក៏បានទទួលនូវផ្លែផ្កា ដោយ មករា បានផលិតរឿងមួយចំនួននៅក្នុងផលិតកម្មនេះ ។ សំខាន់ជាងនេះ មករា បានដឹកនាំរឿងភាគខ្លីមួយចំនួនដែលទទួលបានភាពល្បីល្បាញទូទាំងប្រទេស ។

បន្ទាប់ពីការសិក្សារៀនសូត្រពង្រឹងជំនាញមួយនេះមក មករា ក៏បានក្លាយជាអ្នកថតរូបជំនាញ ក៏ដូចជា ផលិតករ នៅមជ្ឈ



អ៊ូប មករា ថតរូបនៅក្នុងព្រះបរមរាជវាំង

មណ្ឌលឯកសារកម្ពុជា ដែលជាស្ថាប័នសិក្សាស្រាវជ្រាវនៅប្រទេសកម្ពុជា ដែលធ្លាប់ទទួលពានក្នុងការផលិតខ្សែភាពយន្តឯកសារ ដែលមានចំណងជើងថា "ក្បង់ទឹកទន្លេ" និង ខ្សែភាពយន្តឯកសាថ្មីមួយទៀត ដែលមានចំណងជើងថា "កុំស្អប់បងក្មេច" ។

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានទទួលស្គាល់ថា ជាកន្លែងដែលផ្ទុកនូវឯកសារជាច្រើន ដូចជា ឯកសារភ័ស្តុតាងទាក់ទងនឹងឧក្រិដ្ឋកម្មសង្រ្គាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ដែលបានកើតឡើងនៅប្រទេសកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មជ្ឈមណ្ឌល ក៏បានបង្កើតនូវកេរ្តិ៍ឈ្មោះពិសេសក្នុងការថែរក្សា និងលើកកម្ពស់បេតិកភណ្ឌវប្បធម៌កម្ពុជាដែរ ។

នៅរយៈពេលធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា មករា ត្រូវបានផ្តល់កិត្តិយសពីបណ្ឌិត ហូលីយ៉ូ ដែលជ្រេស អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ជ្រើសរើសឲ្យចូលរួមក្នុងកិច្ចការងារសរសេរសៀវភៅថ្មី ដែលមានចំណងជើងថា "រាជវង្សានុវង្សនៅកម្ពុជា" ដោយ ទទួលការងារខាងថតរូបភាព ។

សៀវភៅ "រាជវង្សានុវង្សនៅកម្ពុជា" ដែលសរសេរដោយបណ្ឌិត ហូលីយ៉ូ ដែលជ្រេស បានបោះពុម្ពលើកទីមួយ នៅឆ្នាំ ២០០៣ ។ សៀវភៅថ្មីនេះ ត្រូវបានបោះពុម្ពឡើងវិញ នៅខែធ្នូ ឆ្នាំ២០១៧ ដោយបានបន្ថែមនូវព័ត៌មានក្នុងជំពូកថ្មីៗរបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី រួមជាមួយសមាជិកជាន់ខ្ពស់ដែលជាខ្សែស្រឡាយរាជវង្ស ក៏ដូចជាព្រះរាជនត្តាដែលធ្វើការនៅក្នុងប្រទេសកម្ពុជា និងបានបន្ថែមព្រះឆាយាល័ក្ខថ្មីៗជាច្រើនទៀតរបស់សែស្រឡាយរាជវង្ស ។ ជំពូកថ្មីនេះ ក៏មានផ្ទុកនូវព័ត៌មានទាក់ទងអំពីអតីតព្រះមហាក្សត្រអង្គមុនៗដែលជាប់សែស្រឡាយព្រះបាទអង្គដួង ដែរ ។

មករា ដែលបានចូលរួមចំណែកក្នុងការងារសរសេរសៀវភៅនេះ ត្រូវបានព្រះរាជានុញ្ញាតឲ្យថតរូបសែស្រឡាយរាជវង្សទាំងអស់នៅកម្ពុជា ដែលមានសាច់រឿងទាក់ទងក្នុងសៀវភៅនេះ ។



អ៊ួច មករា ថតរូបនៅព្រះបរមរាជវាំង



ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី និង អ៊ូច មករា នៅព្រះបរមរាជវាំង

ក្នុងអំឡុងឱកាសបំពេញការងារនេះ មករា ត្រូវបានផ្តល់កិត្តិយស និង ព្រះរាជនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី និង សម្តេច ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ឲ្យចូលក្រាបបង្គំគាល់ និងថតព្រះឆាយាល័ក្ខព្រះអង្គនៅព្រះបរមរាជវាំង ។

មករា បានឲ្យដឹងថា នៅពេលចូលគាល់ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី និង សម្តេច ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ដំបូង បេះដូងរបស់គាត់លោតញាប់យ៉ាងខ្លាំង ដោយសារការភិតភ័យ លាយឡំនឹងការរំភើប ។ ប៉ុន្តែ គាត់បាននឹកទៅដល់ពាក្យដែលម្តាយរបស់គាត់តែងធ្លាប់ទូន្មានគាត់ថា "សូមកុំបោះបង់ឱកាសរបស់កូន ទោះមានអ្វីកើតឡើង និងស្ថិតក្នុងកាលៈទេសៈណាក៏ដោយ" ទើបនៅទីបញ្ចប់គាត់អាចធ្វើការងារដ៏ធំនេះ និងបានជួបព្រះភក្ត្រព្រះអង្គដោយផ្ទាល់ ។

រយៈពេលពីរឆ្នាំ ក្នុងការបំពេញការងារថតរូបរបស់ មករា សៀវភៅ "រាជវង្សានុវង្សនៅកម្ពុជា" ដែលសរសេរដោយបណ្ឌិត ហូលីយ៉ូ ដែលជ្រេស (*Julio A. Jeldres*) អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ សម្តេច ព្រះបាទនរោត្តម សីហនុ បានបើកសម្ពោធជាផ្លូវការនៅព្រះបរមរាជវាំង នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៧ ក្រោមព្រះរាជវត្តមានដ៏ខ្ពង់ខ្ពស់ពី ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី និង សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ។

ក្នុងឱកាសសម្ពោធសៀវភៅ "រាជវង្សានុវង្សនៅកម្ពុជា" នេះ មករា ក៏ត្រូវបានអញ្ជើញឲ្យចូលរួម និងថតរូបក្នុងពិធីនេះដែរ ហើយដោយសារកិច្ចខិតខំប្រឹងប្រែងរបស់ មករា កន្លងមក ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សព្វព្រះរាជហឫទ័យប្រោសប្រទានគ្រឿងឥស្សរិយសថ្នាក់ ធិបឌិន្ទ ដល់ មករា ។

មករា បានឆ្លៀតឱកាសនេះ សូមព្រះរាជានុញ្ញាតសម្តែងនូវអំណរព្រះគុណដល់ព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី និង សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ដែលទ្រង់បានព្រះរាជប្រទានមេដាយ និងជំរុញឲ្យគាត់កាន់តែមានក្តីសង្ឃឹមដើម្បីក្លាយជាអ្នកថតរូបជំនាញ និងផលិតខ្សែភាពយន្តទៅថ្ងៃខាងមុខ ។

**សោម ប៊ុនថន**

# វគ្គបណ្តុះបណ្តាលនិស្សិត ស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) នៅសាលសិល្បៈសហសម័យវិទ្យាស្ថានស្ទឹករីត

នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា រៀបចំវគ្គបណ្តុះបណ្តាលនិស្សិត ដើម្បីបង្កើតប្រសិទ្ធភាព និរន្តរភាព និងបង្កើនសមត្ថភាពក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) តាមរយៈការប្រើប្រាស់វិធីសាស្ត្របង្រៀនដ៏សម្បូរណ៍បែប នៅសាលសហសម័យវិទ្យាស្ថានស្ទឹករីត ស្ថិតក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ ។ វគ្គបណ្តុះបណ្តាលនេះ នឹងផ្តល់នូវវិធីសាស្ត្រថ្មីមួយ ដោយបង្កើតឲ្យមានការសន្ទនាពីបទពិសោធផ្ទាល់ខ្លួន និងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលនឹងត្រូវបានអញ្ជើញឲ្យចូលរួមធ្វើជាវាគ្មិននៅក្នុងថ្នាក់រៀន ។

វគ្គបណ្តុះបណ្តាលនេះមានរយៈពេលពីរខែ ដោយសិស្សទទួលការបណ្តុះបណ្តាលរយៈពេលមួយម៉ោងក្នុងមួយថ្ងៃ ដែលនឹងផ្តោតសំខាន់ទៅលើការអភិវឌ្ឍន៍ចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ



វគ្គបណ្តុះបណ្តាលនិស្សិតស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

ក៏ដូចជាការជួយដល់សមត្ថភាពរបស់គ្រូបង្រៀនក្នុងការប្រើប្រាស់វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ។ វគ្គបណ្តុះបណ្តាលនេះ នឹងផ្តល់នូវការធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) និងវិធីសាស្ត្រទំនើប ព្រមទាំងការពិភាក្សាជាក្រុម និងការអនុវត្តលំហាត់ ដែលបង្ហាញឲ្យឃើញចំណេះដឹងរបស់គរុនិស្សិត បន្ទាប់ពីបានសិក្សាជំពូកនីមួយៗនៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) និង «សៀវភៅណែនាំសម្រាប់គ្រូបង្រៀន» ។

គោលបំណងរបស់វគ្គបណ្តុះបណ្តាលគឺ ១) អភិវឌ្ឍន៍ចំណេះដឹងរបស់គរុសិស្ស-និស្សិត ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យក៏ដូចជាជួយដល់សមត្ថភាពបង្រៀនរបស់ខ្លួនក្នុងការប្រើប្រាស់វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ។ ២) ប្រើប្រាស់រឿងរ៉ាវ និងបទពិសោធរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងការបង្រៀន និងផ្តល់នូវមធ្យោបាយសម្រាប់ការពិភាក្សាពីរឿងរ៉ាវជីវិតផ្ទាល់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់វាគ្មិនក្នុងចំណោមសិស្ស ។ ៣) លើកកម្ពស់ប្រសិទ្ធភាព និងនិរន្តរភាពនៃកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍ តាមរយៈសិក្ខាសាលាស្តីពីការអភិវឌ្ឍន៍វិជ្ជាជីវៈ ការបោះពុម្ព និងចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

មុននឹងចាប់ផ្តើមកម្មវិធីបណ្តុះបណ្តាល លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានសំណេះសំណាលជាមួយនិស្សិត ព្រមទាំងបានចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) និងចែកកម្រងសំណួរដើម្បីវាស់ស្ទង់ចំណេះដឹងរបស់គរុនិស្សិត អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលមានចំនួនសរុប២០សំណួរ ទាក់ទងនឹងការវាយតម្លៃលើមាតិកាប្រវត្តិសាស្ត្រ និងវិធីសាស្ត្របង្រៀនមុនពេលបណ្តុះបណ្តាល ។ បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលនេះ និស្សិតនឹងទទួលបាននូវចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកាន់តែច្បាស់ឡើង ។

នៅក្នុងវគ្គបណ្តុះបណ្តាលនេះ និស្សិតមួយចំនួនបានបញ្ចេញនូវចំណាប់អារម្មណ៍ដូចខាងក្រោមៈ

◆ មី បូរី និស្សិតឆ្នាំទី២ ផ្នែកប្រវត្តិវិទ្យា នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានរៀបរាប់ថា ដំបូងឡើយគាត់ធ្លាប់បានឮអំពីរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈឪពុកម្តាយ និងចាស់ទុំដែលរស់នៅក្បែរគ្នា ប៉ុន្តែកាលណោះ គាត់មិនសូវចាប់អារម្មណ៍ពីរបបនេះឡើយ ដោយគាត់យល់ថា សម័យកាលនោះគួរឲ្យខ្លាច និងអាក្រក់យ៉ាងខ្លាំង ។ ប៉ុន្តែនៅពេលដែលគាត់បានសិក្សានៅថ្នាក់អនុវិទ្យាល័យទាក់ទងមេរៀនអំពីសម័យខ្មែរក្រហម ទើបគាត់ចាប់ផ្តើមមានចំណាប់អារម្មណ៍អំពីប្រវត្តិសាស្ត្ររបស់ខ្លួន ជាពិសេសប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

បូរី បន្តថា គាត់មានឱកាសចូលរួមវគ្គបណ្តុះបណ្តាលនៅថ្ងៃនេះ នឹងធ្វើឲ្យគាត់ទទួលបានចំណេះដឹងទាក់ទងនឹងរបបខ្មែរក្រហម និងវិធីសាស្ត្រកាន់តែច្បាស់លាស់ ហើយគាត់នឹងចែករំលែកចំណេះដឹងទាំងអស់នេះ ទៅកាន់មិត្តភក្តិរបស់គាត់ ។ គាត់នឹងយកចំណេះដឹងទាំងនេះទៅពិភាក្សាជាមួយឪពុកម្តាយរបស់គាត់ ព្រោះឪពុករបស់គាត់ចូលចិត្តប្រវត្តិសាស្ត្រ និងធ្លាប់បានឆ្លងកាត់សម័យខ្មែរក្រហម ។ បូរី ចង់ដឹងថាឪពុករបស់គាត់ធ្លាប់ឆ្លងកាត់រឿងរ៉ាវអ្វីខ្លះ ហើយដូចទៅនឹងការសិក្សារបស់គាត់ដែរឬទេ ដើម្បីធ្វើការប្រៀបធៀប ។

◆ កែន ជ្រា និស្សិតឆ្នាំទី៣ ផ្នែកប្រវត្តិវិទ្យា នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានរៀបរាប់ថា ការរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ វាពិតជាមានសារសំខាន់ខ្លាំងណាស់ ជាពិសេសសម្រាប់អ្នកសិក្សាស្រាវជ្រាវ ។ ជ្រា បានបន្តថា ចំពោះប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺជាប្រវត្តិសាស្ត្រដ៏ព្រៃផ្សៃសម្រាប់ប្រជាជនខ្មែរទូទៅត្រូវយល់ដឹង ជាពិសេសសិស្ស-និស្សិត និងក្មេងជំនាន់ក្រោយដើម្បីជៀសវាងកុំឲ្យប្រវត្តិសាស្ត្រនេះកើតឡើងម្តងទៀត ។

ជ្រា ធ្លាប់បានសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យតាមរយៈកម្មវិធីក្រសួងអប់រំដែរ ប៉ុន្តែគាត់នៅយល់ដឹងតួចនៅឡើយអំពីប្រវត្តិសាស្ត្រនេះ ។ ជ្រា រំពឹងថា ចាប់ពីថ្ងៃនេះទៅគាត់នឹងទទួលបានចំណេះដឹងកាន់តែច្រើនពីវគ្គបណ្តុះបណ្តាល ។

**ហូ ថុនា**

# ការសិក្សាប្រវត្តិសាស្ត្រតាមរយៈភាពយន្តឯកសារ

នៅព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ និស្សិតផ្នែកច្បាប់ឆ្នាំទី១ ប្រមាណជាង៦៥នាក់ មកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានចាប់អារម្មណ៍មកធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលសិល្បៈសហសម័យវិទ្យាស្ថានស៊ីករីត ។ កម្មវិធីទស្សនកិច្ចសិក្សានេះ ក៏មានការចូលរួមពីសំណាក់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងវាគ្មិនពីររូប គឺលោក ប៉េង ផល្លា និង លោក ឡុង សំសារីម ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ។ មុននឹងចាប់ផ្តើមកម្មវិធី លោក ឆាំង យុ ធ្វើការសំណេះសំណាលទៅកាន់និស្សិតទាំងអស់ និងបង្ហាញពីសារសំខាន់នៃការចងចាំអំពីប្រវត្តិសាស្ត្ររបស់ខ្លួនតាមរយៈភាពយន្តឯកសារ ការស្រាវជ្រាវ ប្រមែប្រមូលចងក្រងឯកសារក្នុងសម័យខ្មែរក្រហម ។

ក្នុងឱកាសនោះដែរ និស្សិតទាំងអស់បានទស្សនាកុនឯកសាររឿង "កុំស្មានបងភ្លេច" ជាខ្សែភាពយន្តនិយាយអំពីអំឡុងទសវត្សរ៍៦០ និងដើមទសវត្សរ៍៧០ ដែលឆ្លុះបញ្ចាំងអំពីតន្ត្រីរ៉ក អេន រ៉ូល ដែលខ្មែរបានបាត់បង់អំឡុងពេលប្រទេសមានសង្គ្រាម ។ តន្ត្រីមួយនេះ គឺបានចម្លងចេញពីបស្ចិមប្រទេស ដោយមានបុសគល់នៃតន្ត្រីដើមរបស់ខ្លួន និងបានបង្កើតជាតន្ត្រីមួយបែបថ្មី ខុសពីតន្ត្រីដទៃ ។

តន្ត្រីករខ្មែរបានបង្កើតតន្ត្រីមួយបែបនេះ ចេញពីក្បួនខ្នាតដ៏សំខាន់នៃតន្ត្រីរ៉កផ្សេងៗរបស់ អាមេរិក អង់គ្លេស និងបារាំង ដោយដាក់បញ្ចូលសំឡេង និងចង្វាក់តន្ត្រីប្រពៃណីខ្មែរតែមួយគត់របស់ខ្លួន ។

សំឡេងដ៏ពិរោះរបស់អ្នកចម្រៀងស្ត្រីដែលល្បីឈ្មោះ បានក្លាយជាចំណុចទាក់ទាញ ហើយធ្វើឲ្យតន្ត្រី ច្នៃប្រឌិតមួយនេះទទួលបានការពេញនិយមយ៉ាងខ្លាំងពីសំណាក់សាធារណជន ។ ប៉ុន្តែនៅពេលដែលសង្គមខ្មែរ ជាពិសេសតន្ត្រីវ័យក្មេង ដែលទទួលយកវប្បធម៌បស្ចិមប្រទេស ហើយបានវិវឌ្ឍន៍ខ្លួនក្រោមឥទ្ធិពលនៃវប្បធម៌នេះ ប្រទេសកម្ពុជាគឺបានធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាមយ៉ាងឆាប់រហ័ស ។ "កុំស្មានបងភ្លេច" ខ្មែរបាត់បង់តន្ត្រី រ៉ក អេន រ៉ូល បានដឹកកកាយនូវលក្ខណៈធាតុផ្សំរបស់តន្ត្រីខ្មែរដែលបានប្រែក្លាយទៅជាតន្ត្រី រ៉ក អេន រ៉ូល ហើយបានរីកចម្រើនឆ្ពោះទៅមុខ ប៉ុន្តែស្ទើរតែត្រូវបាបបំផ្លិចបំផ្លាញចោលទាំងស្រុងនៅក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។ ខ្សែភាពយន្តឯកសារនេះ បានផ្តល់គំហើញថ្មីស្តីពីប្រទេសមួយ ដែលធ្លាប់តែពុះពីសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ។ ខ្សែភាពយន្តនេះ នឹងនាំយើងជាអ្នកទស្សនាបានយល់ដឹងអំពីសិល្បៈតន្ត្រីពីសង្គមអតីតកាល និងរហូតមកដល់បច្ចុប្បន្ន ។

បន្ទាប់ពីបានទស្សនាខ្សែភាពយន្តឯកសាររឿង "កុំស្មានបងភ្លេច" នេះមក និស្សិតទាំងអស់ដែលបានចូលរួម មានការពេញចិត្តចំពោះភាពយន្តនេះណាស់ ។ អ្នកទាំងអស់គ្នាយល់ថា ភាពយន្តឯកសារ "កុំស្មានបងភ្លេច" នេះ ពិតជាមានសារសំខាន់ណាស់ ព្រោះភាពយន្តនេះ បានឆ្លុះបញ្ចាំងពីអតីតកាលជាច្រើនជំនាន់នៃប្រវត្តិសាស្ត្ររបស់កម្ពុជា ។ ជាមួយគ្នានេះដែរ អ្នកដែលចូលរួមមានឱកាសចោទសួរជាសំណួរទៅកាន់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីចម្ងល់ទាំងឡាយជុំវិញកុនឯកសារនេះ និងមូលហេតុ ក៏ដូចជាគោលបំណងដែលបង្កើតឲ្យមានកុនឯកសារនេះមក និងជាពិសេសចម្ងល់មួយចំនួនដែលទាក់ទងនឹងរបបខ្មែរក្រហម ។ ក្នុងនោះដែរ និស្សិតបានចោទជាសំណួរដូចតទៅ ៖

១) តើមូលហេតុអ្វីដែលជំរុញឲ្យលោកបង្កើតកុនឯកសារនេះឡើង?

២) តើកុនឯកសារនេះបានផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់ប្រវត្តិសាស្ត្រកម្ពុជា?

៣) តើមូលហេតុអ្វីបានជាមានអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា?

**ហួ ថុនា**

# ចំណាប់អារម្មណ៍របស់និស្សិតចំពោះភាពយន្តឯកសារ «កុំស្មានបងភ្លេច»

កាលពីខែធ្នូ ឆ្នាំ២០១៧ និស្សិតច្បាប់ឆ្នាំទី៤ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងបានមកធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងទស្សនាខ្សែភាពយន្តឯកសារ "កុំស្មានបងភ្លេច" នៅសាលសិល្បៈសហសម័យនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។

បន្ទាប់ពីដំណើរទស្សនកិច្ច និងទស្សនាខ្សែភាពយន្តឯកសារនេះ និស្សិតទាំងអស់បានយល់ដឹងកាន់តែច្រើនអំពីប្រវត្តិសាស្ត្ររបស់ជាតិខ្លួន និងសិល្បៈអំឡុងទសវត្សរ៍៦០ និងដើមទសវត្សរ៍៧០ ថែមទាំងបានបញ្ចេញនូវចំណាប់អារម្មណ៍ផ្ទាល់ខ្លួនដូចខាងក្រោម៖

◆ ខែម នីតា និស្សិតឆ្នាំទី៤ ជំនាញនីតិសាស្ត្រ បានរៀបរាប់ថា នៅពេលដែល នីតា បានមកធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងបានទស្សនាកុនឯកសារ "កុំស្មានបងភ្លេច" ពេលនោះ នីតា ពិតជាមានអារម្មណ៍រំភើបយ៉ាងខ្លាំង ដោយសារនៅទីនោះ មានវត្ថុជាច្រើន និងមានផ្ទាំងគំនូរដែលឆ្លុះបញ្ចាំងអំពីអតីតកាល ដែល នីតា មិនធ្លាប់បានឃើញកន្លងមក ព្រមទាំងមានឯកសារអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលបានតម្កល់ទុកនៅទីនោះជាច្រើន ជាពិសេសគឺការរៀបចំទុកដាក់ឯកសារទាំងនោះ មានសណ្តាប់ធ្នាប់ដែលធ្វើឲ្យងាយស្រួលដល់អ្នកស្រាវជ្រាវជាតិ និងអន្តរជាតិធ្វើការស្នើសុំឯកសារ ។ម្យ៉ាងទៀត នីតា បានបញ្ជាក់ថា សម្រាប់ខ្លួនគាត់ផ្ទាល់ ពិតជាមានអារម្មណ៍ត្រេកអរដែលមានឱកាសចូលរួមទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារ


ក្រុមនិស្សិតមកពីសាកលវិទ្យាល័យប្រ៊ូកលីន កំពុងទស្សនាខ្សែភាពយន្តឯកសារ "កុំស្មានបងភ្លេច" ។



ក្រុមនិស្សិតមកពីសាកលវិទ្យាល័យប្រ៊ូកលីន កំពុងស្តាប់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើបទបង្ហាញអំពីខ្សែភាពយន្តឯកសារ “កុំស្មានបងភ្លេច” ។

កម្ពុជា ព្រមទាំងទទួលបានចំណេះដឹង អំពីរឿងរ៉ាវដែលកើតឡើងពីអតីតកាលធ្វើឲ្យ នីតា យល់កាន់តែច្បាស់ថែមទៀត ។

◆ សាយ លក្ខិណា និស្សិតឆ្នាំទី៤ ជំនាញនីតិសាស្ត្រ បាននិយាយថា បន្ទាប់ពី លក្ខណា បានទស្សនាខ្សែភាពយន្ត “កុំស្មានបងភ្លេច” រួចមក លក្ខណា គិតថាខ្សែភាពយន្តនេះពិតជាមានសារសំខាន់ខ្លាំងណាស់ ពីព្រោះវាបានឆ្លុះបញ្ចាំងជាច្រើនសម័យកាល និងទិដ្ឋភាពនៃការបាត់បង់តន្ត្រី សិល្បៈករ សិល្បៈការិនី និងតារាចម្រៀងល្បីៗតាំងពីសម័យក្រោយអាណានិគម រហូតដល់ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។ តាមរយៈខ្សែភាពយន្តនេះ លក្ខិណា យល់ឃើញថា តន្ត្រីនៅសម័យកាលនោះ ពិតជាមានភាពល្បីល្បាញ និងមានតារាចម្រៀងល្បីៗជាច្រើន រីឯការរស់នៅរបស់ប្រជាពលរដ្ឋវិញ មានសុខសន្តិភាពល្អ និងមានជីវភាពយ៉ាងសមរម្យ ។ អ្វីដែល លក្ខិណា ចាប់អារម្មណ៍ គឺបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការយ៉ាងយកចិត្តទុកដាក់ចំពោះតួនាទីរបស់ពួកគាត់ និងមានការរួសរាយរាក់ទាក់ទៅកាន់ក្រុមនិស្សិតទស្សនកិច្ចសិក្សារបស់ លក្ខណា ផ្ទាល់ ។

◆ ហេង ថាលីន និស្សិតឆ្នាំទី៤ ជំនាញនីតិសាស្ត្រ បានរៀបរាប់ថា ក្រោយពីបានទស្សនាខ្សែភាពយន្ត “កុំស្មានបងភ្លេច” រួចមក ថេងលី បានយល់កាន់តែច្បាស់អំពីសិល្បៈខ្មែរក្រោយឯករាជ្យជាតិ រហូតមកដល់ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ថាតើវាមានលក្ខណប្រែប្រួលយ៉ាងដូចម្តេច ។ ថេងលី បានបន្តថា កុនឯកសារ “កុំស្មានបងភ្លេច” បានធ្វើឲ្យ ថេងលី ស្វែងយល់អំពីសិល្បតន្ត្រីខ្មែរពីដើមដែលមានសភាពរស់រវើក និងគួរឲ្យទាក់ទាញយ៉ាងខ្លាំង ។ មិនត្រឹមតែប៉ុណ្ណោះ នៅសម័យកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រើប្រាស់តន្ត្រីសម្រាប់បម្រើវិស័យនយោបាយរបស់ខ្លួនទៀតផង ។ ម្យ៉ាងទៀត ថាលីន បានសង្កេតឃើញថា ការរៀបចំឯកសាររបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាពិតជាមានភាពងាយស្រួលក្នុងការស្វែងរកនៅពេលដែលអ្នកស្រាវជ្រាវត្រូវការប្រើប្រាស់ឯកសារ ដោយសារតែការរៀបចំគឺបានធ្វើទៅតាមប្រភេទនៃឯកសារនីមួយៗ ។ ចំណែកឯការប្រមូលឯកសារ និងព័ត៌មានវិញ ថេងលី យល់ឃើញថា វាពិតជាមានការលំបាកខ្លាំងណាស់ ដោយឯកសារខ្លះត្រូវបានកម្ទេច ខ្លះទៀតនៅឯបរទេស និងនៅតាមក្រសួងនានាជាដើម ។ ជាងនេះទៅទៀត បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅសម្ភាសប្រជាជននៅតាមតំបន់ឬគ្រប់ខេត្តទាំងអស់ដែលស្ថិតនៅក្នុងប្រទេសកម្ពុជា ។

សរុបសេចក្តីមក ថេងលី ពិតជាមានអារម្មណ៍រំភើប រីករាយ និងភ្ញាក់ផ្អើលយ៉ាងខ្លាំង អំពីទស្សនកិច្ចសិក្សានេះ ដោយ ថេងលី យល់ថា សម្រាប់ខ្លួនគាត់ផ្ទាល់ ពិតជាទទួលបានចំណេះដឹងជាច្រើន អំពីរឿងរ៉ាវដែលបានកើតឡើងពីអតីតកាល និងជាចុងបញ្ចប់ ថេងលី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលទទួលស្វាគមន៍ដល់ក្រុមនិស្សិតទាំងអស់យ៉ាងកកក្តៅ ។

**ហ៊ូ ផុនា**

# សិក្ខាសាលាអន្តរជាតិស្តីពីការពង្រឹងសមត្ថភាពការអប់រំ អំពីប្រវត្តិសាស្ត្រ និងការទប់ស្កាត់អំពើហិង្សា

សិក្ខាសាលាអន្តរជាតិ ស្តីពីការពង្រឹងសមត្ថភាពការអប់រំអំពីប្រវត្តិសាស្ត្រ និងការទប់ស្កាត់អំពើហិង្សា ត្រូវបានរៀបចំឡើង ដោយអង្គការសម្ព័ន្ធអន្តរជាតិបណ្តុះមនសិការ *(Sites of Conscience)* សហការជាមួយមជ្ឈមណ្ឌលកម្ពុជានៅវិចិត្រសាល សហសម័យវិទ្យាស្ថានស៊ីករិត ក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ ។ កម្មវិធីសិក្ខាសាលាអន្តរជាតិនេះ នឹងធ្វើឡើងរយៈពេលបួនថ្ងៃ ចាប់ពីថ្ងៃទី១៥ ដល់ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ដែលមានសមាជិក និងអង្គការជាដៃគូមកពីប្រទេសទីម័រ ហ្គាតាម៉ាឡា ប្រទេសឥណ្ឌូនេស៊ី និងប្រទេសកម្ពុជា ។ លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា តំណាងក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើការផ្សារលើកម្រោងអប់រំស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ក៏បានចូលរួម និងធ្វើជាគណអធិបតីក្នុងពិធីបើកវគ្គសិក្ខាសាលាអន្តរជាតិនេះ ព្រមទាំងមានគ្រូប្រវត្តិសាស្ត្រថ្នាក់ជាតិ គរុនិស្សិតមកពីវិទ្យាស្ថានជាតិអប់រំ និងសមាជិកមកពីអង្គការជាដៃគូ ។

សារ៉ា ប្រេដស អ្នកសម្របសម្រួល មកពីអង្គការសម្ព័ន្ធអន្តរជាតិបណ្តុះមនសិការ *(Sites of Conscience)* បានឡើងបង្ហាញពីគោលបំណងរបស់សិក្ខាសាលាអន្តរជាតិ ស្តីពីការពង្រឹងសមត្ថភាពការអប់រំអំពីប្រវត្តិសាស្ត្រ និងការទប់ស្កាត់អំពើហិង្សាថាៈ អង្គការសម្ព័ន្ធអន្តរជាតិបណ្តុះមនសិការ *(Sites of Conscience)* ជាអង្គការសម្ព័ន្ធអន្តរជាតិមួយដែលធ្វើការទាក់ទងជាមួយប្រទេសក្រោយជម្លោះ ដើម្បីផ្លាស់ប្តូរឲ្យទៅជាសង្គមមួយដែលមានការអប់រំ និងការដោះស្រាយជាមួយនឹងអតីតកាល លើសពីនេះទៀតជាអង្គការសម្ព័ន្ធថ្នាក់ពិភពលោកមួយដែលធ្វើឲ្យមានការចងចាំចំពោះប្រទេសដែលប្រឈមនឹងប្រវត្តិសាស្ត្រដ៏ជូរចត់ ។ អង្គការសម្ព័ន្ធអន្តរជាតិនេះ ក៏បានធ្វើការនៅប្រទេសកម្ពុជាអស់រយៈ



*ពិធីបើកសិក្ខាសាលាអន្តរជាតិ ស្តីពីការពង្រឹងសមត្ថភាពការអប់រំ អំពីការបង្រៀនប្រវត្តិសាស្ត្រ និងការទប់ស្កាត់អំពើហិង្សា ត្រូវបានរៀបចំដោយអង្គការសម្ព័ន្ធអន្តរជាតិបណ្តុះមនសិការ (Sites of Conscience) សហការជាមួយមជ្ឈមណ្ឌលកម្ពុជានៅវិចិត្រសាល សហសម័យវិទ្យាស្ថានស៊ីករិត ក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ ក្រោមអធិបតីភាពលោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា ។*

ពេលជាច្រើនឆ្នាំមកហើយទាក់ទងជាមួយនឹងប្រវត្តិសាស្ត្រដ៏ជូរចត់នេះ ។ ថ្ងៃនេះ ក៏មិនខុសពីពេលមុនដែរ យើងបង្កើតសិក្ខាសាលាអន្តរជាតិនៅទីនេះ ក្នុងគោលបំណងស្វែងរកការពិត និងយុត្តិធម៌អន្តរកាល ។ ក្នុងរយៈពេលបីឆ្នាំ សម្ព័ន្ធអង្គការអន្តរជាតិ យើងបានធ្វើការជាមួយនឹងប្រទេសចំនួន១៧ និងអង្គការសង្គមស៊ីវិលចំនួន ២៥០ ក្នុងចំណោម៥៥ប្រទេស ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាសមាជិកទី៩នៃសម្ព័ន្ធអន្តរជាតិ ។

ក្នុងឱកាសចូលរួមបើកសិក្ខាសាលាអន្តរជាតិ ស្តីពីការពង្រឹងសមត្ថភាពការអប់រំអំពីប្រវត្តិសាស្ត្រ និងការទប់ស្កាត់អំពើហិង្សា លោកជិទាវ ទន់ សាអ៊ីម បានសម្តែងនូវអារម្មណ៍រីករាយ ដែលសិក្ខាសាលានេះបានធ្វើឡើងនៅប្រទេសកម្ពុជា និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះកិច្ចសហការដ៏ល្អ រវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយអង្គការជាដៃគូដែលធ្វើការលើការអប់រំពីប្រវត្តិសាស្ត្រ ហើយទទួលបាននូវភាពជោគជ័យគួរឲ្យកត់សម្គាល់ ។ ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បានផ្តល់នូវព័ត៌មាន និងបទពិសោធដល់ក្មេងជំនាន់ក្រោយឲ្យដឹងពីរបបនេះ ដែលបានប្រព្រឹត្តមកលើប្រជាជន ។ ប្រជាជនកម្ពុជាជាច្រើនបានឆ្លងកាត់ជីវិតរស់នៅយ៉ាងលំបាក និងបានបាត់បង់នូវសិទ្ធិសេរីភាព ។ លោកជិទាវបានបន្តថា ប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងគ្រោះមហន្តរាយទាំងស្រុងក្នុងរបបនេះ ហើយក្រសួងអប់រំ យុវជន និងកីឡា បានខិតខំបញ្ជ្រៀតកម្មវិធីសិក្សា និងមេរៀនទាក់ទងរបបកម្ពុជាប្រជាធិបតេយ្យ ទៅតាមថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យនៅទូទាំងប្រទេស ។ លោកជិទាវ ដែលជាជនរងគ្រោះក្នុងរបបនេះផ្ទាល់បានលើកឡើងថា អតីតកាលគឺជាមេរៀនសម្រាប់ជីវិតរបស់យើងនៅក្នុងបច្ចុប្បន្ននេះ យើងរៀនអំពីអតីតកាលដើម្បីរក្សាការការពារកុំឲ្យប្រវត្តិសាស្ត្រដ៏សាហាវនេះកើតឡើងម្តងទៀត ។ យើងត្រូវបណ្តុះបណ្តាលយុវជនឲ្យក្លាយទៅជាទំពាំងស្នងឬស្សី ។ យើងកំពុងខិតខំប្រឹងប្រែងធ្វើសព្វថ្ងៃនេះដើម្បីឆ្ពោះទៅរកការលើកកំពស់សីលធម៌ និងស្វែងរកយុត្តិធម៌ទៅដល់ជនរងគ្រោះ និងឈានទៅដល់ការផ្សះផ្សាជាតិ ។ លោកជិទាវ ក៏បានថ្លែងអំណរគុណដល់តំណាងសមាជិកដែលមកពីប្រទេសទាំងបួន ដែលនឹងចែករំលែកអំពីប្រវត្តិសាស្ត្ររបស់ប្រទេសនីមួយៗ និងជូនពរដល់គណៈអធិបតីភ្ញៀវជាតិអន្តរជាតិ លោកគ្រូអ្នកគ្រូ និងគរុនិស្សិតដែលបានអញ្ជើញចូលរួមនៅថ្ងៃនេះ និងបានប្រកាសបើកវគ្គសិក្ខាសាលាអន្តរជាតិចាប់ពីពេលនេះទៅ ។

បន្ទាប់ពី ការបើកកម្មវិធី អង្គសិក្ខាសាលា បានចាប់ផ្តើមបើកកម្មវិធីពិភាក្សាដោយមានការចូលរួមពីតំណាងអង្គការ និងស្ថាប័នមកពីប្រទេសទីម័រ ប្រទេសហ្គាតាម៉ាឡា ឥណ្ឌូណេស៊ី និងប្រទេសកម្ពុជា ។ កម្មវិធីពិភាក្សានេះ បានបើកឱកាសឲ្យវាគ្មិនតំណាងឲ្យអង្គការមកពីប្រទេសនីមួយៗបង្កើតជាសំណួរទាក់ទងនឹងសិក្ខាសាលាស្តីពីការពង្រឹងការអប់រំស្តីពីប្រវត្តិសាស្ត្រ និងការទប់ស្កាត់អំពើហិង្សា ។ ជាមួយគ្នានេះ តំណាងមកពីប្រទេសនីមួយៗក៏បានលើកឡើងពីគម្រោងសំខាន់ដែលខ្លួនបានធ្វើកន្លងមក និងអ្វីដែលខ្លួនចង់បាន បន្ទាប់ពីសិក្ខាសាលានេះ ដូចជាការបង្កើតឲ្យមានសារមន្ទីរ ការបង្រៀនប្រវត្តិសាស្ត្រ ដោយឡែកអនុប្រធានការិយាល័យអប់រំស្រុកស្រីសន្ធរ តំណាងមកពីប្រទេសកម្ពុជា ចង់បង្កើតឲ្យមានបណ្ណាល័យនៅតាមសាលាដើម្បីឲ្យសិស្សានុសិស្សចូលអាន ។

នៅពេលរសៀលថ្ងៃដដែល តំណាងអង្គការមូលនិធិកោសល្យវិច័យ មកពីប្រទេសហ្គាតាម៉ាឡា បានធ្វើបទបង្ហាញស្តីពីកិច្ចការងារស្រាវជ្រាវ និងស៊ើបអង្កេត និងការធ្វើកោសល្យវិច័យ (DNA) ទាក់ទងនឹងការបាត់ខ្លួន និងការស្លាប់របស់ជនរងគ្រោះនៅក្នុងប្រតិបត្តិការយោធាក្នុងប្រទេសនេះ ។

តំណាងមកពីប្រទេសទីម័រ ក៏បានចែករំលែកបទពិសោធនៃការបង្រៀនប្រវត្តិសាស្ត្រ និងការចងចាំនៅតាមសាកលវិទ្យាល័យ និងនៅថ្នាក់មូលដ្ឋាន ។ ការអប់រំទាំងនេះនឹងផ្តោតសំខាន់ទៅលើសន្តិភាព និងការផ្សះផ្សាជាតិក្នុងប្រទេស ។

លោកគ្រូ ស៊ីវ ធួន តំណាងឲ្យប្រទេសកម្ពុជាបានចែករំលែកបទពិសោធមួយចំនួន ដល់សិក្ខាសាលាអន្តរជាតិ ដោយបានយករឿងរ៉ាវ និងសោកនាដ្ឋកម្មផ្សេងៗ ចាប់តាំងពីខ្មែរក្រហមបានចូលកាន់កាប់អំណាច រហូតដល់ថ្ងៃរបបខ្មែរក្រហមត្រូវបានដួលរលំនៅថ្ងៃទី៧ មករា ១៩៧៩ ។ សិក្ខាសាលាអន្តរជាតិនេះ ត្រូវបានបញ្ចប់នៅម៉ោង៥កន្លះល្ងាច និងបន្តទៅថ្ងៃស្អែកតាមកម្មវិធីដែលបានគ្រោងទុក ។ **ហូ ថុនា**

# សិក្ខាសាលាអន្តរជាតិ ស្តីពីការពង្រឹងសមត្ថភាពការអប់រំអំពីប្រវត្តិ
# អង្គការសម្ព័ន្ធអន្តរជាតិបណ្តុះមនសិការ សហការជាមួយមជ្ឈមណ្ឌល










## ត្តិសាស្ត្រ និងការទប់ស្កាត់អំពើហិង្សា ត្រូវបានរៀបចំឡើងដោយ ឯកសារកម្ពុជា នៅវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្ទីករឹត












Peace School Foundation
December 13th 2002


INTERNATIONAL EDUCATORS WORKSHOP
ON
STRENGTHENING CAPACITY
FOR EDUCATION ON HISTORY AND VIOLENCE PREVENTION
January 15th-16th, 2018
Contemporary Art Gallery of Sleuk Rith Institute





# វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន កោះដាច់

*សង្កាត់កោះដាច់មានទីតាំងស្ថិតនៅក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។ កោះដាច់មានចម្ងាយប្រមាណ២០គីឡូម៉ែត្រពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៦A ត្រូវធ្វើដំណើរឆ្លងកាត់តាមទូកដពីកំពង់ចម្លងបាក់ខែងឆ្ពោះទៅកោះដាច់ ។ ជាទូទៅ កោះដាច់ ត្រូវបានអ្នកទីក្រុងភ្នំពេញ ជាពិសេសយុវជនយុវនារីស្គាល់ថា ជាកន្លែងកម្សាន្ត និងងូតទឹកលេងតាមឆ្នេរខ្សាច់ទន្លេមេគង្គនារដូវប្រាំងនៅចុងសប្តាហ៍ ។ អ្នកភូមិកោះដាច់ភាគច្រើនប្រកបរបរធ្វើស្រែចម្ការ ត្បាញសូត្រ ហូល និង ផាមួង ។ តម្បាញនេះ មានលក្ខណៈបែបប្រពៃណីខ្មែរ ដោយប្រើប្រាស់ឧបករណ៍បែបបុរាណ ហើយស្ត្រីជាអ្នកត្បាញនៅក្រោមផ្ទះ ។*

*នៅក្នុងរបបខ្មែរក្រហម (១៩៧៥-៧៩) កោះដាច់ ស្ថិតនៅក្នុងស្រុកមុខកំពូល តំបន់២២នៃភូមិភាគបូព៌ា ។ បន្ទាប់ពីឡើងកាន់កាប់អំណាចនៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្ខំប្រជាជននៅកោះដាច់ឲ្យធ្វើស្រែចម្ការដូចប្រជាជននៅតំបន់ផ្សេងៗទៀត ដើម្បីយកទិន្នផលទៅផ្គត់ផ្គង់អង្គការ ។ នៅរដូវប្រមូលផលម្តងៗ ខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនដឹកកសិផលយកទៅប្រគល់ជូនអង្គការនៅត្រើយម្ខាងទៀតនៃទន្លេមេគង្គ ។*

*នៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ បន្ទាប់ពីកម្មាភិបាលស្រុក តំបន់ និងភូមិភាគបូព៌ាភាគច្រើនត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខស-២១ ប្រជាជនដែលរស់នៅកោះដាច់ ក៏ដូចជាប្រជាជនដទៃ ក្នុងតំបន់២២ និងតំបន់ផ្សេងៗទៀតនៅក្នុងភូមិភាគនេះ ត្រូវបានខ្មែរក្រហមបង្ខំជម្លៀសទៅភូមិភាគពាយ័ព្យ ។ ប្រជាជននៅកោះដាច់មួយចំនួនធំត្រូវបានសម្លាប់ និងស្លាប់ដោយសារជំងឺ ខណៈពេលដែលប្រជាជនផ្សេងទៀត ត្រូវបានបង្ខំឲ្យធ្វើការហួសកម្លាំង និងធ្ងន់ធ្ងរនៅភូមិភាគពាយ័ព្យ ។ មកដល់សព្វថ្ងៃ ប្រជាជននៅកោះដាច់នៅតែចងចាំពីការជម្លៀស និងការទទួលរងទុក្ខវេទនានៅក្នុងរបបខ្មែរក្រហម ។*

*ដើម្បីរំឭកហេតុការណ៍ទាំងនេះឡើងវិញ និងដើម្បីជាមេរៀនសម្រាប់ក្មេងជំនាន់ក្រោយបានសិក្សារៀនសូត្រ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំយុវជន និងកីឡា បានរៀបចំវេទិកាថ្នាក់រៀនមួយស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន កោះដាច់ ដែលមានទីតាំងស្ថិតនៅក្នុងភូមិល្វា សង្កាត់កោះដាច់ ។*

*ដំបូងឡើយវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន កោះដាច់នេះគឺជាអតីតសាលាបឋមសិក្សាកោះដាច់ដែលបានបង្កើតឡើងនៅឆ្នាំ១៩៨៣ បន្ទាប់មកសាលាបឋមសិក្សានេះត្រូវបានដំឡើងឲ្យទៅជាអនុវិទ្យាល័យកោះដាច់ ។ នៅឆ្នាំ២០០៩ អនុវិទ្យាល័យកោះដាច់នេះ ត្រូវបានក្រសួងអប់រំ យុវជន និងកីឡា បានប្រែក្លាយឲ្យទៅជាវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន កោះដាច់ ។ សព្វថ្ងៃវិទ្យាល័យនេះមានសិស្សកំពុងសិក្សាចាប់ពីថ្នាក់ទី៧ រហូតដល់ថ្នាក់ទី១២ ដែលមានចំនួនសរុប១.០៨០នាក់ ។*

*នៅវេលាម៉ោង១ៈ៣០នាទីរសៀល ថ្ងៃដដែល លោក ប៊ិច ចាម នាយកសាលាវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន កោះដាច់ បានមានប្រសាសន៍ទៅកាន់សិស្សថ្នាក់ទី១២ ដែលបានចូលរួមក្នុងវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចំនួនសរុប១១៦នាក់ថា ថ្ងៃនេះវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន កោះដាច់ពិតជាមានកិត្តិយសណាស់ ដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មកជួយបង្ហាត់បង្រៀនដល់សិស្សានុសិស្សទាំងអស់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ លោក ប៊ិច ចាម បន្ថែមថា សិស្សទាំងអស់គួរយកចិត្តទុកដាក់ស្តាប់ការបង្រៀននេះ ព្រោះទាំងអស់គ្នានឹងទទួលបានអត្ថប្រយោជន៍ជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាវិញ្ញាសារធ្លាប់បានចេញពេលប្រឡងទុតិយភូមិកាលពីឆ្នាំ*

សិក្សាកន្លងមក ។ កាលពីឆ្នាំមុនវិញ្ញាសាប្រវត្តិវិទ្យា ក៏មានសំណួរឲ្យសិស្សធ្វើការប្រៀបធៀបរវាងរបបសង្គមរាស្ត្រនិយម និងរបបកម្ពុជាប្រជាធិបតេយ្យ ថាតើវាមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច ។ ជាចុងក្រោយ លោក ប៉ិច ចាម បានសំណូមពរដល់សិស្សានុសិស្សទាំងអស់ឲ្យកត់ត្រាទុកនូវចំណុចសំខាន់ៗ ព្រោះវាអាចជួយដល់សំណេររបស់ខ្លួននៅថ្ងៃប្រឡងទុតិយភូមិខាងមុខនេះ ។

បន្ទាប់ពី លោក ប៉ិច ចាម មានប្រសាសន៍ចប់ លោក ឡុង ដានី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បាននិយាយពីគោលបំណងនៃការបង្កើតវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យថា គោលបំណងទី១) គឺ រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ជំរុញឲ្យមានការផ្សះផ្សា និងអប់រំក្មេងៗជំនាន់ក្រោយឲ្យចេះអត់ឱន និងអធ្យាស្រ័យគ្នា ។ គោលបំណងទី២) គឺ រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីទប់ស្កាត់កុំឲ្យរបបប្រល័យពូជសាសន៍កើតឡើងម្តងទៀត ។

ក្រោយពីនិយាយអំពីវត្ថុបំណងនៃការធ្វើវេទិកាថ្នាក់រៀនចប់ លោក ឡុង ដានី បានផ្តល់ឱកាសឲ្យសិស្សានុសិស្សទាំងអស់សរសេរនូវអ្វីដែលខ្លួនបានដឹង និងអ្វីដែលខ្លួនចង់ដឹងអំពីរបបខ្មែរក្រហម ។ បន្ទាប់មក ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារមានចំណងជើងថា "កុមារកម្ពុជា" ដែលបង្ហាញពីជីវិតក្មេងកំព្រាក្រោយរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩ ។ បន្ទាប់ពីសិស្សានុសិស្សទស្សនាខ្សែភាពយន្តឯកសារចប់ លោក ឡុង ដានី ក៏បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងឆ្លើយសំណួរផ្សេងៗដែលសិស្សានុសិស្សចង់ដឹងទាក់ទងទៅនឹងរបបនេះ ។ តមក លោក ស៊ាង ចិន្តា ប្រធានវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត បានបង្ហាញពីការតាំងពិព័រណ៍ជម្លៀសដោយបង្ខំទៅកាន់សិស្សានុសិស្សទាំងអស់ ដើម្បីបញ្ជ្រៀបការយល់ដឹងមួយផ្នែកទៀត នៃប្រវត្តិសាស្ត្រដែលឆ្លុះបញ្ចាំងពីរឿងរ៉ាវនៃការបម្លាស់ទីដោយបង្ខំរបស់ប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហម ។

សេត ឈួហេង រៀនថ្នាក់ទី១២A នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន កោះដាច់ បានរៀបរាប់ថា ដំបូងឡើយ គាត់ធ្លាប់បានឮសម័យខ្មែរក្រហមតាមរយៈឪពុកម្តាយនិយាយប្រាប់ ប៉ុន្តែកាលណោះគាត់មានការយល់ដឹងពីរបបនេះតិចតួចណាស់ ។ ឈួហេង បានបន្ថែមថា "មុនខ្មែរក្រហមកាន់អំណាច ឪពុកម្តាយរបស់គាត់ រស់នៅទីក្រុងភ្នំពេញ ក្រោយពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះទូទាំងប្រទេស ឪពុកម្តាយរបស់គាត់ត្រូវបានខ្មែរក្រហមបង្ខំជម្លៀសចេញពីភ្នំពេញ ឲ្យទៅខេត្តបាត់ដំបង ។ បន្ទាប់មកខ្មែរក្រហមបានចាត់តាំងឪពុកម្តាយរបស់គាត់ឲ្យធ្វើស្រែ និងលើកទំនប់ដោយគ្មានពេលឈប់សម្រាកឡើយ ចំណែករបបអាហារ ឪពុកម្តាយគាត់មិនដែលបានហូបឆ្អែតទេ ។ ។

ឈួហេង បន្ថែមថា វេទិកាថ្នាក់រៀនថ្ងៃនេះ ពិតជាមានសារសំខាន់ខ្លាំងណាស់ចំពោះសិស្សានុសិស្សដែលត្រូវប្រឡងទុតិយភូមិឆ្នាំនេះ ព្រោះមានឱកាសទទួលបាននូវចំណេះដឹងបន្ថែមទៀតពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលជាប្រវត្តិសាស្ត្រដ៏ឃោរឃៅដែលប្រជាជនកម្ពុជាមិនអាចបំភ្លេចបាន ។ ឈួហេង មានការចាប់អារម្មណ៍ខ្លាំងពីវីដេអូទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងនៃរបបនោះ ទាំងការហូបចុក ការរស់នៅ និងធ្វើការ ជាដើម ។

យ៉ាន ដារីកា ជាសិស្សរៀនថ្នាក់ទី១២A នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន កោះដាច់ បានរៀបរាប់ថា "ពីមុនមក គាត់ធ្លាប់បានដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈការសិក្សារៀនសូត្រ និងអ្នកភូមិដែលរស់នៅក្បែរគ្នា ជាពិសេសតាមរយៈឪពុកម្តាយរបស់គាត់និយាយប្រាប់" ។ ដារីកា បន្ថែមថា វេទិកាថ្នាក់រៀនថ្ងៃនេះ ពិតជាជួយបង្កើនចំណេះដឹងរបស់គាត់បានច្រើនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដូចជាការយល់ដឹងអំពីទុក្ខវេទនាការប្រើអំពើអមនុស្សធម៌ ការបង្អត់អាហារ ការធ្វើទុក្ខបុកម្នេញ និងការធ្វើទារុណកម្មមកលើប្រជាជនកម្ពុជា ។

ជាចុងក្រោយ ដារីកា សំណូមពរចង់ឲ្យមានវេទិកាថ្នាក់រៀនបែបនេះឲ្យបានច្រើន ព្រោះគាត់គិតថា ចំណេះដឹងរបស់គាត់ទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យនៅមានកម្រិតនៅឡើយ ។ ប្រសិនបើគាត់ទទួលបានចំណេះដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យកាន់តែច្រើន គាត់នឹងចែករំលែកចំណេះដឹងទាំងនេះជាមួយមិត្តភក្តិរបស់គាត់តាមរយៈការសន្ទនា និងបណ្តាញព័ត៌មានសង្គម ។ **ហួ ថុនា**

# រូបថតវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុ










# ជាប្រជាធិបតេយ្យ នៅវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន កោះដាច់












# រឿងរ៉ាវរបស់ សុខ ស៊ីណាន តាមរយៈប្រវត្តិមូលដ្ឋាន

គីម ចេង មានអាយុ៦៨ឆ្នាំ មានស្រុកកំណើតនៅភូមិពោធិ៍កណ្តាល ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ។ ចេង មានឪពុកឈ្មោះ ង៉ែន និងម្តាយឈ្មោះ អៀង និងមានបងប្អូនបង្កើតចំនួនប្រាំនាក់ ។ ចេង មានប្តីឈ្មោះ ប៉ិច ប្រាវ និងមានកូនចំនួនបួននាក់ សព្វថ្ងៃរស់នៅស្រុកកំណើត ។

ដើមឡើយ ចេង រៀនសូត្របានត្រឹមថ្នាក់ទី៨ (ពីសង្គមចាស់) នៅសាលាបឋមសិក្សាពោធិ៍អណ្តែត ។ ក្រោយមក ចេង បានឈប់រៀនហើយមកជួយធ្វើស្រែចម្ការឪពុកម្តាយ ។ ចេង បានរៀបការជាមួយគ្រួសារ និងរស់នៅក្នុងភូមិកំណើត ។ នៅក្នុងឆ្នាំ១៩៧០ ពេលដែលប្រទេសកើតមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ដោយលោកសេនាប្រមុខ លន់ នល់ បានធ្វើឲ្យប្រទេសកម្ពុជាចាប់កើតមានសង្គ្រាមតាំងពីពេលនោះមក ។ ពេលនោះ ចលនាខ្មែរក្រហមបានធ្វើសកម្មភាពវាយប្រហារជាមួយនឹងទាហាន លន់ នល់ ជាបន្តបន្ទាប់ ។ នៅឆ្នាំ១៩៧១ មានយន្តហោះមួយចំនួន បានមកទម្លាក់គ្រាប់បែក ប៉ុន្តែការទម្លាក់គ្រាប់បែកនោះមិនបណ្តាលឲ្យអ្នកស្រុកភូមិខូចខាតទ្រព្យសម្បត្តិ និងបាត់បង់អាយុជីវិតមនុស្សច្រើនទេ ។ លើកលែងតែការបាញ់ផ្លោងពីត្រើយខាងលិច ហើយគ្រាប់ផ្លោងបានធ្លាក់នៅក្បែរៗផ្ទះ បណ្តាលឲ្យត្រូវយាយ យឹក ស្លាប់ភ្លាមៗនៅនឹងកន្លែងកើតហេតុ ។


គីម ចេង

បន្ទាប់ពីសង្គ្រាមប្រាំឆ្នាំបញ្ចប់ នៅឆ្នាំ១៩៧៥ ហើយខ្មែរក្រហមបានកាន់កាប់ប្រទេសទាំងស្រុង ប្រជាជនថ្មីជាច្រើនត្រូវបានខ្មែរក្រហមជម្លៀសពីភ្នំពេញឲ្យមករស់នៅក្នុងភូមិពោធិ៍កណ្តាលនេះ ។ មិនយូរប៉ុន្មាន ប្រជាជនថ្មីមួយចំនួនក៏បានចាកចេញពីភូមិពោធិ៍កណ្តាលវិញ ។ ក្នុងចំណោមប្រជាជនថ្មីដែលបានមករស់នៅក្នុងភូមិពោធិ៍កណ្តាលនេះ មានស្ត្រីម្នាក់ឈ្មោះ ស៊ី ណាន បានសុំអង្គការរស់នៅក្នុងភូមិពោធិ៍កណ្តាលបន្តទៀត ដោយបានសុំស្នាក់នៅជាមួយគ្រួសាររបស់ ចេង និងបានសុំការអនុញ្ញាតពីឪពុកម្តាយរបស់ ចេង ធ្វើជាឪពុកម្តាយធម៌របស់ខ្លួនទៀត ។ ពេលដែល ស៊ី ណាន សុំឪពុកម្តាយរបស់ ចេង ធ្វើជាឪពុកម្តាយធម៌នោះ ឪពុកម្តាយរបស់ ចេង ក៏មិនបានបដិសេធនឹងបំណងរបស់ ស៊ី ណាន ដែរ ដោយគាត់គិតថា “កូនគេកូនយើង ចេះតែជួយយកអាសារគ្នាទៅ ធ្វើម៉េចបើប្រទេសជាតិជួបនឹងសង្គ្រាមបែបនេះទៅហើយ” ។ ដូច្នេះ បូករួមនឹង ស៊ី ណាន ម្នាក់ទៀត សមាជិកក្នុងគ្រួសាររបស់ ចេង ឡើងដល់ទៅប្រាំមួយនាក់ រស់នៅក្នុងផ្ទះមួយមានទំហំបណ្តោយប្រវែង៦ម៉ែត្រ និងទទឹងប្រវែង៥ម៉ែត្រ ។ ចាប់តាំងពីពេលដែល ស៊ី ណាន បានមករស់នៅជាមួយគ្រួសាររបស់ ចេង ស៊ី ណាន មិនដែលបានរៀបរាប់ពីប្រវត្តិដំណើររឿងរ៉ាវរបស់ខ្លួនប្រាប់ឲ្យគ្រួសាររបស់ ចេង បានដឹងឡើយ ។

ពេលដែលខ្មែរក្រហមបានកាន់កាប់អំណាចភ្លាម នៅក្នុងភូមិមិនទាន់មានផែនការរឹតបន្តឹងប្រជាជនទេ ។ ប្រជាជននៅមានសេរីភាព ហើយការហូបចុកនៅមានលក្ខណៈជាឯកជន គឺនៅហូប

តាមផ្ទះរៀងៗខ្លួននៅឡើយ ។ បន្ទាប់ពីស្នាក់នៅជាមួយគ្រួសាររបស់ ចេង បានពីរបីថ្ងៃមក ស៊ី ណាន បានរៀបរាប់ប្រាប់គ្រួសាររបស់ ចេង ថា “គាត់ជាអ្នកធ្វើការផាររនៅភ្នំពេញ ហើយចេះភាសាអង់គ្លេស” ។ ស៊ី ណាន បានបន្តទៀតថា ខ្លួនមានប្តីហើយ (តែមិនបានប្រាប់ថាប្តីឈ្មោះអ្វីទេ) ។ ពេលរៀបការហើយ ស៊ី ណាន បាននាំប្តីចូលគាល់ព្រះមហាក្សត្រីយានី កុសុមៈ ហើយព្រះអង្គបានប្រទានខ្សែដៃមាសមួយខ្សែក្នុងគ្រានោះ ។ នៅពេលដែលខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញភ្លាម ស៊ី ណានមិនបានរួមដំណើរតាមយន្តហោះទៅប្រទេសក្រៅជាមួយប្តីរបស់ខ្លួនទេ ដោយសារទើបវះកាត់ពោះ មិនទាន់ជាស្រួលបួលនៅឡើយ (ពេលនិយាយប្រាប់នោះ ចេង មិនបានមើលស្នាមរបួសរបស់ ស៊ី ណាន ទេ) ។ ស៊ី ណាន ជាស្ត្រីម្នាក់មានមុខមាត់ស្អាតបាត សម្បុរស្រអែម មាឌធំមាំ ហើយជាមនុស្សរួសរាយរាក់ទាក់ ។ ស៊ី ណាន បានប្រាប់បន្តថា ពេលខ្មែរក្រហមជម្លៀសចេញពីភ្នំពេញ គាត់មានវ៉ាលីសចំនួនបី តែនៅតាមផ្លូវម្តុំព្រែកគយក្នុងស្រុកស្អាង អ្នកដែលជួយយួរវ៉ាលីសទាំងនោះ បានគេចខ្លួនដោយនាំយកទាំងវ៉ាលីសទាំងបីរបស់គាត់ទៅជាមួយផង ។ ពេលដែល ស៊ី ណាន មកស្នាក់នៅផ្ទះរបស់ ចេង ដំបូង ចេង បានឃើញស្ត្រីម្នាក់មកជាមួយ ស៊ី ណាន ដែរ ។ បើមើលពីអត្តចរិកខាងក្រៅ ស្ត្រីម្នាក់នោះជាមនុស្សដែលចេញមកពីគ្រួសារស្តេច ឬ គ្រួសារអ្នកធ្វើការផាររធំ ប៉ុន្តែ ស៊ី ណាន មិនបានធ្វើការណែនាំពីស្ត្រីម្នាក់នោះឲ្យគ្រួសាររបស់ ចេង បានស្គាល់ទេ ។ បន្ទាប់មក ស្ត្រីម្នាក់នោះក៏បានជម្រាបលាគ្រួសាររបស់ ចេង និង ស៊ី ណាន ដោយធ្វើដំណើរបន្តទៅមុខទៀតមិនដឹងជាទៅរស់នៅទីណាទេ ។ ពេលដែល ស៊ី ណានមកស្នាក់នៅជាមួយគ្រួសាររបស់ ចេង ស៊ី ណាន បានបែកពីមិត្តភក្តិអស់ហើយ ។ មួយអាទិត្យក្រោយមក ស៊ី ណាន បានយកប្រាក់ដុល្លារ និងមាសមួយចំនួន រួមមាន ខ្សែដៃ ខ្សែកដែលមានទម្ងន់ធ្ងន់គួរសមមកផ្ញើគ្រួសាររបស់ ចេង ឲ្យថែរក្សាទុក ។ កាលនោះ គ្រួសាររបស់ ចេង មិនដែលស្គាល់ប្រាក់ដុល្លារទេ តែនៅពេលបានទទួលពី ស៊ី ណាន ក៏យកទៅចែកគ្នាទុក ។ ចេង បានឲ្យម្តាយរបស់គាត់ ដេរហោប៉ៅខោខាងក្នុងទុកប្រាក់ដុល្លារ និងមាសនៅជាប់នឹងចង្កេះ ចំណែកខ្លួនគាត់ ក៏បានដេរហោប៉ៅខាងក្នុងសម្រាប់ទុកដាក់មាសមួយដែរ ។



ភូមិរបស់ គីម ចេង



ផ្ទះរបស់ គីម ចេង ដែលសាងសង់ក្រោយរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩

មួយខែក្រោយមក ប្រធានឃុំឈ្មោះ ជួន និងឈ្មោះ អេង បានចុះមកស្រង់ប្រវត្តិរូបប្រជាជនថ្មីទាំងអស់នៅក្នុងភូមិ ។ ពេលនោះ គ្រួសាររបស់ ចេង បានប្រាប់ ស៊ី ណន ឲ្យនិយាយប្រាប់ទៅមេឃុំថា នៅភ្នំពេញអត់មានធ្វើការងារធ្វើទេ ។ បន្ទាប់មក អង្គការបានហៅប្រជាជនឲ្យទៅប្រជុំ ហើយបានប្រកាសឲ្យប្រជាជនទាំងអស់យកមាសប្រាក់ និងរបស់មានតម្លៃប្រគល់ទៅឲ្យអង្គការទាំងអស់ មិនត្រូវទុកនៅជារបស់សួនតួទេ ព្រោះពេលនេះយើងទាំងអស់គ្នារស់នៅក្រោមការដឹកនាំរបស់អង្គការ ធ្វើការងាររួម ហូបបាយរួមនៅតាមសហករណ៍ ។ ក្រោយពេលអង្គការប្រកាសរួច ប្រជាជនមួយចំនួនធំបានយករបស់របរមានតម្លៃទៅជូនអង្គការ ចំណែក ចេង និង ស៊ី ណន មិនបានយកប្រាក់ដុល្លារ និងមាសទៅប្រគល់ជូនអង្គការទេ ។ ស៊ី ណន បានចុះទៅធ្វើការជាមួយប្រជាជនមូលដ្ឋានតាមកងចល័ត រហូតដល់ពេលល្ងាចម៉ោងប្រាំទើបវិលត្រឡប់មកផ្ទះវិញ ។ នៅក្បែរផ្ទះរបស់ ចេង ចម្ងាយប្រហែលជា ៥០ម៉ែត្រ មានមន្ទីរពេទ្យមួយ ។ ប្រជាជនតែងនាំគ្នាមកសម្រាកព្យាបាលជំងឺជាបន្តបន្ទាប់នៅមន្ទីរពេទ្យនោះ ។ អ្នកជំងឺខ្លះដែលមានជំងឺស្រាលក៏បានជាសះស្បើយ ឯអ្នកខ្លះទៀតដែលមានជំងឺធ្ងន់ក៏ស្លាប់បាត់បង់ជីវិត ព្រោះមន្ទីរពេទ្យនេះមិនមានថ្នាំល្អៗសម្រាប់ព្យាបាលជំងឺទេ គឺមានតែថ្នាំអាចម៍ទន្សាយប៉ុណ្ណោះ ។

នៅឆ្នាំ១៩៧៦ កម្មាភិបាលខ្មែរក្រហម បានចុះមកស្រាវជ្រាវ ហើយបានយកប្រជាជនថ្មីទៅដាក់នៅ "កោះគ" ដែលជាមន្ទីរសន្តិសុខ និងជាកន្លែងសម្លាប់មនុស្ស ។ ស៊ី ណន ក៏បានដឹងដែរថា "កោះគ" គឺជាកន្លែងសម្លាប់មនុស្ស ។ ចាប់ពីពេលនោះមក ស៊ី ណន បានខិតខំប្រឹងប្រែងធ្វើការងារ ហើយក៏បានខិតខំយកចិត្តយកថ្លើមប្រជាជនចាស់ដែលជាអ្នកមូលដ្ឋានមានមុខមានមាត់នៅក្នុងភូមិ ពិសេសគ្រួសាររបស់ ចេង ។ នៅពេលកម្មាភិបាលខ្មែរក្រហមមកសួរនាំរឿងរ៉ាវរបស់ ស៊ី ណន ឪពុកម្តាយរបស់ ចេង ក៏បានប្រាប់ទៅអង្គការវិញថា "ស៊ី ណន ជាក្មេងកំព្រា គ្មានឪពុកម្តាយទេ ទុកគ្នាឲ្យរស់នៅផងទៅ" ។ នៅក្នុងភូមិពោធិ៍កណ្តាល ក្រោយពីចាប់ប្រជាជនថ្មីយកទៅដាក់នៅកោះគ អង្គការក៏បានធ្វើការជម្លៀសប្រជាជនចេញពីភូមិស្ទើរតែទាំងអស់ឲ្យទៅរស់នៅភូមិភាគពាយ័ព្យ ក្នុងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ។ នៅភូមិពោធិ៍កណ្តាល ប្រជាជនត្រូវបានអង្គការបង្ខំឲ្យធ្វើការគ្មានថ្ងៃឈប់សម្រាក ចំណែកការហូបចុកអង្គការបានផ្តល់ឲ្យល្មមតែប្រជាជនអាចរស់ជីវិតបានតែប៉ុណ្ណោះ ។ ចេង បានឃើញ ស៊ី ណន ត្រឡប់មកពីធ្វើការតាមកងចល័តវិញនៅពេលយប់តែប៉ុណ្ណោះ ហើយ ស៊ី ណន តែងតែទៅចុះងូតទឹកនៅក្នុងទន្លេបាសាក់តែម្នាក់ឯងដោយមិនមានខ្លាចអ្វីទាំងអស់ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៨ ស៊ី ណន បានចេញពីគ្រួសាររបស់ ចេង ទៅរស់នៅតាមការដ្ឋាន ដោយមិនបានយកមាស និងប្រាក់ដុល្លារទៅជាមួយទេ ដោយផ្ញើទុកនៅជាមួយនឹង ចេង ។ ចេង បាននិយាយថា ពេល ស៊ី ណន ចេញទៅនៅតាមការដ្ឋានមិនបានត្រឡប់មកផ្ទះវិញទេ តាមដឹងនៅតាមការដ្ឋាននោះ មានរោងវែងៗសង់ឡើងសម្រាប់ឲ្យយុវជនយុវនារីក្នុងក្រុមកងចល័តស្នាក់នៅ ។

នៅឆ្នាំ១៩៧៩ ពេលដែលរបបខ្មែរក្រហមត្រូវបានដួលរំលំ ស៊ី ណន បានវិលត្រឡប់មករស់នៅជាមួយក្រុមគ្រួសាររបស់ ចេង វិញ ។ ដោយយល់ថា បានរួចផុតពីរបបខ្មែរក្រហមហើយ ចេង ក៏បានយកមាស និងប្រាក់ដុល្លារមកប្រគល់ឲ្យ ស៊ី ណន វិញទាំងអស់ ។ ពេលនោះ ស៊ី ណន បានពិនិត្យមើលរបស់ទាំងអស់នោះដោយមានទឹកមុខញញឹមសប្បាយរីករាយ បន្ទាប់មក ស៊ី ណន ក៏

បានយកខ្សែកមួយខ្សែ និងមានបន្តោងមួយមានទម្ងន់ប្រាំជី ប្រគល់ឲ្យទៅ ចេង ជាការអរគុណដល់ ចេង ដែលបានជួយថែរក្សារបស់ទាំងអស់នេះ ។

ក្រោយឆ្នាំ១៩៧៩ អ្នកចេះដឹងត្រូវបានខ្មែរក្រហមសម្លាប់ស្ទើរអស់ ។ បន្ទាប់មក អ្នកភូមិពោធិ៍កណ្ដាលបានដឹងថា ស៊ី ណាន ជាអ្នករៀនសូត្រចេះដឹង ក៏បានស្នើសុំឲ្យ ស៊ី ណាន ជួយបង្រៀនក្មេងៗនៅក្នុងភូមិ ។ ពេលនោះ ស៊ី ណាន បានយល់ព្រមបង្រៀនក្មេងៗក្នុងភូមិតាមការស្នើសុំរបស់ប្រជាជន គឺបង្រៀននៅក្នុងសាលាបឋមសិក្សាពោធិ៍អណ្ដែតបានរយៈពេលមួយឆ្នាំ ។ នៅឆ្នាំ១៩៨០ ស៊ី ណាន បានទៅភ្នំពេញចំនួនពីរដង ពេលត្រឡប់មកភូមិពោធិ៍កណ្ដាលវិញ ស៊ី ណាន បាននិយាយប្រាប់គ្រួសារ ចេង ថា ខ្លួនបានជួបបងប្អូននៅភ្នំពេញ និងបានទាក់ទងជាមួយអ្នកបើកយន្តហោះបានហើយ នៅរង់ចាំតែថ្ងៃត្រូវធ្វើដំណើរចេញទៅប្រទេសក្រៅតែប៉ុណ្ណោះ ។

មិនយូរប៉ុន្មាន ស៊ី ណាន បានជម្រាបលាឪពុកម្ដាយ និងក្រុមគ្រួសាររបស់ ចេង និងអ្នកភូមិផង ដោយបាននិយាយថា «ពេលបានចេញទៅរស់នៅប្រទេសក្រៅ គឺឈប់វិលមករស់នៅស្រុកខ្មែរវិញហើយ ព្រោះស្រុកខ្មែរជួបតែសង្គ្រាមសម្លាប់គ្នាឯងមិនចេះចប់មិនចេះហើយ រស់នៅគួរឲ្យខ្លាចណាស់» ។

ចាប់តាំងពីពេលដែល ស៊ី ណាន បានចាកចេញពីគ្រួសាររបស់ ចេង ចេង មិនដែលបានទទួលដំណឹងអ្វីពី ស៊ី ណាន ទេ ។ ថ្ងៃមួយ ចេង បានជួបនឹងអ្នកដែលរស់នៅសហរដ្ឋអាមេរិកដែលបានមកលេងស្រុកកំណើត ។ ចេង ក៏បានមកសួរនាំអ្នកមកលេងស្រុកកំណើតពីដំណឹងរបស់ ស៊ី ណាន ប៉ុន្តែដំណឹងដែល ចេង ទទួលបានហាក់ស្រពិចស្រពិល មិនច្បាស់លាស់ ហើយក៏គ្មានលេខទូរសព្ទដើម្បីធ្វើការទាក់ទងទៅ ស៊ី ណាន ដែរ ។ លុះដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ នាពេលថ្មីៗនេះ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅធ្វើការងារនៅក្នុងភូមិពោធិ៍កណ្ដាលដើម្បីសួររកឈ្មោះ ស៊ី ណាន ។ ពេលនោះ ចេង មានការភ្ញាក់ផ្អើលជាខ្លាំង ព្រោះគាត់យល់ថា និងបានទទួលដំណឹងល្អពី ស៊ី ណាន ជាក់ជាមិនខាន ។ តែក្ដីសង្ឃឹមរបស់ ចេង ត្រូវបាត់បង់ទៅវិញ បន្ទាប់ពីក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានជម្រាបគាត់ថា ស៊ី ណាន បានស្លាប់នៅក្នុងឆ្នាំ២០១០ ហើយ ។ **សុខ ខណ្ណា**



ផ្លូវទៅស្រុកស្អាង ខេត្តកណ្ដាល ពេលបច្ចុប្បន្ន

# អំណះអំណាងមេធាវីការពារក្តីរបស់ នួន ជា ក្នុងការបិទបញ្ចប់ សវនាការសួរដេញដោលនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

*នៅវេលាម៉ោង៩ព្រឹក ចៅក្រម និល ណុន បានចាប់ផ្តើមបើកសវនាការ ។ ចៅក្រម និល ណុន បានបញ្ជាក់ថា រាល់ជនជាប់ចោទគឺមានវត្តមាននៅទីនេះ លើកលែងតែ នួន ជា ព្រោះគាត់មានបញ្ហាផ្នែកសុខភាព ដូចនេះហើយពុំអាចមានវត្តមាននៅទីនេះបានទេ ក៏ប៉ុន្តែទោះជាមានមូលហេតុនេះក្តី ក៏ការកាត់ក្តី នឹងប្រព្រឹត្តទៅដូចសព្វដង ។*

*ចៅក្រម និល ណុន បានផ្តល់ឱកាសបកស្រាយទៅសហមេធាវីការពារក្តីរបស់លោក នួន ជា ។ លោក សុន អរុណ សហមេធាវីការពារក្តីរបស់លោក នួន ជា បានស្វាគមន៍ និង ណែនាំខ្លួនទៅកាន់អង្គជំនុំជម្រះទាំងមូល ។*

***សេចក្តីផ្តើម***

*មេធាវី សុន អរុណ បានចាប់ផ្តើមលើកឡើងដោយសង្ខេបរឿងក្តីរបស់ នួន ជា ។ ក្នុងវេលានេះ និងថ្ងៃស្អែក លោកជាមួយក្រុមការងារ និងធ្វើការឆ្លើយតបតចំពោះការចោទប្រកាន់មកលើ នួន ជា ធ្វើការសង្ខេប ក៏ដូចជាធ្វើការបកស្រាយសំណុំរឿងនេះ ។ មេធាវី សុន អរុណ បានបញ្ជាក់ថា នេះគឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយសម្រាប់ នួន ជា ក៏ដូចជាប្រជាជនខ្មែរ ។ មេធាវី សុន អរុណ ក៏បានបញ្ជាក់ថា នួន ជា នឹងទទួលខុសត្រូវចំពោះការឈឺចាប់ ក៏ដូចជាការប៉ះពាល់ផ្លូវចិត្តរបស់ប្រជាជនចំពោះរឿងរ៉ាវដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នួន ជា ក៏នៅតែបន្តចូលរួមក្នុងដំណើរការក្តីនេះ ព្រោះវាជាភារកិច្ចរបស់គាត់ដើម្បីបកស្រាយឲ្យប្រជាជនខ្មែរយល់ដឹងនូវបញ្ហាដែលបានកើតឡើងនាសម័យនោះ ។*

*មេធាវី សុន អរុណ បានលើកឡើងថា ការបន្តប្រឆាំង ឬចោទប្រកាន់ទៅលើ នួន ជា បានប្រើពេលអស់ជាង១០ឆ្នាំហើយ ហើយមកទល់ពេលនេះ នួន ជា ក៏មានអាយុជាង៩១ឆ្នាំដែរ ។ បន្ថែមលើនេះ សាក្សីជាច្រើនក៏បានស្លាប់ រីឯខ្លះទៀត ក៏មិនបានចូលរួមជាសាក្សី ចាប់តាំងពីការចាប់ផ្តើមនៃដំណើរការកាត់ក្តីមកម្ល៉េះ ។ មេធាវី សុន អរុណ បានបន្ថែមថា ដំណើរឆ្ពោះកាន់ការពិតគឺមានរយៈពេលវែងឆ្ងាយនៅឡើយ ហើយដោយសារតែវាជាសវនាការចុងក្រោយ ដូច្នេះរាល់ការប្រឆាំង ឬ ការតទល់ គឺជាវិធីតែមួយគត់ដើម្បីស្វែងរកនូវការពិតឲ្យកូនខ្មែរ ។*

*មេធាវី សុន អរុណ បានបញ្ជាក់ថា លោក និងក្រុមការងារបានប្រមូលផ្តុំឯកសារប្រមាណជាង៥៥០ទំព័រ ទាក់ទងនឹងករណីរបស់ នួន ជា ហើយដោយសារតែការស្តាប់សវនាការសួរដេញដោលនេះ មានរយៈពេលត្រឹមតែពីរថ្ងៃ ដូចនេះ លោកសូមលើកឡើងត្រឹមតែផ្នែកសំខាន់ៗសម្រាប់ប្រជាជន ក៏ដូចជា ផ្នែកដែលលើកឡើងនៅក្នុងសវនាការនេះ ។ ក្រុមការងាររបស់លោក និងត្រៀមនូវការសួរដេញដោលដោយផ្ទាល់មាត់ដែលនឹងបង្ហាញអំពីប្រវត្តិសាស្ត្រ នីតិវិធីទាក់ទងជាមួយនឹងសំណុំរឿងមួយនេះ ។ លោក វិកទ័រ កុប៉េ សហមេធាវីការពារក្តីរបស់លោក នួន ជា នឹងបកស្រាយផ្នែកសំខាន់ក្នុងសំណុំរឿងមួយនេះដែលមេធាវីការពារក្តីបានផ្តល់ងារឲ្យថា សត្វក្រពើ ។*

*មេធាវី សុន អរុណ បានបន្តទៀតថា ការកាត់ទោសនេះបានកាត់ត្រឹមតែខ្លួនរបស់សត្វក្រពើប៉ុណ្ណោះ ប៉ុន្តែផ្នែកក្បាល និងដងខ្លួនមិនត្រូវបានលើកយកមកកាត់ទេ ។ ផ្នែកក្បាល ឬ ផ្នែកចាប់ផ្តើម គឺសំដៅទៅលើការចាប់ផ្តើម ពីឆ្នាំ១៩៧៥ រីឯផ្នែកកន្ទុយសំដៅទៅលើលទ្ធផលបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ ។ រឿងហេតុនៃការចាប់ផ្តើម គឺត្រូវបកស្រាយរឿងរ៉ាវដែលបានកើតឡើងនាសម័យនោះ ដែលមានដូចជា ការគំរាមកំហែងពីប្រទេសវៀតណាម ក៏ដូចជា ការបង្អិនបង្អោចដោយសារការទម្លាក់គ្រាប់បែករបស់អាមេរិក និងជម្លោះផ្ទៃក្នុងដែលកើតឡើងនៅក្នុងប្រទេស ។*

*មេធាវី សុន អរុណ បានបញ្ជាក់ថា គាត់ និងសហការមេធាវី វិកទ័រ កុប៉េ និងបកស្រាយឲ្យលម្អិតអំពីភ័ស្តុតាងដែលបង្ហាញថា វៀតណាមបានជ្រើសរើសគិញសម្ងាត់ដែលមានតំណែងខ្ពស់ក្នុង*

បក្សកុម្មុយនីស្តកម្ពុជា ដែលពួកគេធ្លាប់មានប្រវត្តិចង់ផ្តួលរំលំរដ្ឋាភិបាលចំនួនបីដង តែពុំបានសម្រេច ។ ការធ្វើរដ្ឋប្រហារមួយនេះនឹងអាចទម្លាក់បក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជា ផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ និងបន្ថែមភាពរីកវរទៅដល់ប្រទេសទាំងមូល ប្រសិនបើរដ្ឋប្រហារនេះបានសម្រេច ។ មេធាវី វិកទ័រ កុប៉េ នឹងបន្ថែមការពិភាក្សាអំពីទង្វើដែលវៀតណាមបានប្រព្រឹត្តនាសម័យនោះ ដែលជាលទ្ធផលនាំមកនូវការឈ្លានពានខុសច្បាប់មកលើប្រទេសកម្ពុជានាឆ្នាំ១៩៧៨ ។ បន្ទាប់ពីនោះ វៀតណាមបានក្តោបក្តាប់ ក៏ដូចជាត្រួតត្រាប្រទេសកម្ពុជា ដែលហៀបនឹងឈានដល់ការបង្កើតសហព័ន្ធឥណ្ឌូចិន ដែលមានប្រទេសកម្ពុជា និង ប្រទេសឡាវជារដ្ឋរណប ។

មេធាវី សុន អរុណ រួមជាមួយក្រុមការងារ នឹងពិភាក្សាអំពីការការពារជាតិ និងនយោបាយសន្តិសុខក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ មេធាវី លីវ សុវណ្ណ និង បកស្រាយអំពីរដ្ឋក្នុងសភាពប្រកាសអាសន្ន ដែលកើតមាននាសម័យកម្ពុជាប្រជាធិបតេយ្យ ដែលនយោបាយនាពេលនោះពុំសូវប្រើប្រាស់ដោយសមហេតុផល និងត្រឹមត្រូវទេ ។ ជាចុងក្រោយ លោកនឹងបកស្រាយអំពីការអនុវត្តគោលនយោបាយយោធា ក៏ដូចជានយោបាយសន្តិសុខនាសម័យនោះ ។ លោក ដូរីន ចេន នឹងបកស្រាយពីមន្ទីរសន្តិសុខក្រាំងតាចាន់ អូរកន្សែង និង ភ្នំក្រោល និងបញ្ចប់ជាមួយការបកស្រាយពីមន្ទីរស-២១ ។

បន្ទាប់មក មេធាវី សុន អរុណ ក៏បានផ្ទេរការបកស្រាយនេះទៅមេធាវី លីវ សុវណ្ណ ។

## យន្តការក្នុងការបកស្រាយភស្តុតាង

មេធាវី លីវ សុវណ្ណ បានចាប់ផ្តើមដោយលើកឡើងថា ការកាត់ទោសក្នុងសំណុំរឿងនេះ គឺពោរពេញទៅដោយការប្រម៉ាតម៉ាក់ងាយខាងសីលធម៌ទៅជនជាប់ចោទ បើទោះបីគាត់ ពុំដែលប្រកែកចំពោះការរងទុក្ខវេទនារបស់ប្រជាជនខ្មែរនាសម័យនោះក៏ដោយ ។ តួនាទីទីមួយរបស់មេធាវីការពារក្តី គឺសូមឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធ្វើការប្រកបទៅដោយសច្ចភាពភាពត្រឹមត្រូវ និងគោរពទៅតាមច្បាប់ ។ តួនាទីទីពីរ គឺ ត្រូវតែធ្វើការកាត់ទោសប្រកបដោយភាពត្រឹមត្រូវ និងមានទំនួលខុសត្រូវខ្ពស់ ចំណែកការកាត់ទោសត្រូវតែបង្ហាញនូវភស្តុតាងគ្រប់បែបយ៉ាង ដើម្បីកុំឲ្យបន្សល់នូវការងឿងឆ្ងល់ទៅថ្ងៃក្រោយ ។ បន្ថែមពីនេះ អង្គជំនុំជម្រះត្រូវដើរតួដោយត្រឹមត្រូវ និងប្រកបដោយភាពយុត្តិធម៌ និងសច្ចធម៌ ។ មេធាវីការពារក្តី មានជំនឿយ៉ាងមុតមាំថា ការកាត់ទោសនេះនឹងអាចស្វែងរកនូវការពិតជាក់លាក់ ព្រោះ វាជាស្ពានដើម្បីឈានទៅរកភាពយុត្តិធម៌ដ៏សំខាន់មួយ ។ ទាំងនេះ គឺជាអ្វីដែល នួន ជា ចង់បានពីការកាត់ទោសមួយនេះ ក៏ប៉ុន្តែ គាត់ពិតជាមានការអន់ចិត្តជាខ្លាំងនៅពេលដែលតុលាការ ពុំបានចាប់អារម្មណ៍ចំពោះអ្វីដែលជាការពិត ។

មេធាវី លីវ សុវណ្ណ បានទទូចថា តុលាការ មិនបានស្វែងរកនូវការពិតនោះទេ ក៏ប៉ុន្តែបែរជានិយាយច្រំដែលអំពីរឿងប្រឌិតទៅវិញ ។ រឿងប្រឌិតនេះត្រូវបានផ្សព្វផ្សាយដោយវៀតណាម ហើយត្រូវបានយកមកនិយាយដោយរដ្ឋាភិបាលកម្ពុជាសព្វថ្ងៃ ក៏ដូចជាបាន ចុះផ្សាយតាមសៀវភៅ អត្ថបទ ពិព័រណ៌ និងកម្មវិធីផ្សេងៗច្រំដែល ។ រឿងប្រឌិតនេះ បានក្លាយជាផ្នែកមួយនៃការស៊ើបអង្កេត ហើយក៏បានប្រែក្លាយជាផ្នែកមួយនៃការកាត់ទោស ។ នៅពេលមេធាវីការពារក្តី អានសំណុំរឿង០០១ និងសំណុំរឿង ០០២/០១ យើងយល់ឃើញថា អង្គជំនុំជម្រះពិតជាមានជំនឿលើរឿងប្រឌិតនេះ ។

មេធាវី លី សុវណ្ណ បានបន្តថា នួន ជា នឹងធ្វើការតវ៉ា ក៏ដូចជាឆ្លើយតបទៅកាន់រឿងប្រឌិតនេះ ។ រឿងនេះបានឆ្លុះបញ្ចាំងថា សម័យកម្ពុជាប្រជាធិបតេយ្យ គឺជាសម័យដែលពោរពេញទៅដោយភាពឃោរឃៅ និង ព្រៃផ្សៃ ដែលគោលបំណងធំ គឺដើម្បីធ្វើបាបប្រជាជនកម្ពុជា ។ សហមេធាវីអន្តរជាតិរបស់យើងបានឲ្យឈ្មោះវាថា ជារឿងប្រឌិតដ៏មិនសមគួរមួយ ។ រឿងប្រឌិតនេះបកស្រាយសាច់រឿងបែបសាមញ្ញពេក ហើយសាច់រឿងទាំងនោះសុទ្ធសឹងតែជាពាក្យមិនពិត ។ នៅចុងបញ្ចប់ គឺបានត្រឹមតែធ្វើការប្រៀបធៀប រវាងសភាវល្អ និង អាក្រក់ ដែលក្នុងនោះ បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគេកំណត់ថា ជាតួអង្គឃោរឃៅ និងកាចសាហាវខ្លាំង ។

មេធាវី លីវ សុវណ្ណ បានបកស្រាយថា រឿងប្រឌិតនេះបានបែងចែកជា ៤ ចំណុច ធំៗគឺៈ

ទី១) ការឃោសនារបស់វៀតណាម ដោយចោទប្រកាន់

*ថា បក្សកុម្មុនីស្តកម្ពុជា គឺជាមនុស្សឃោរឃៅ*

*បន្ទាប់ពីការលុកលុយអំពីសំណាក់កងទ័ពវៀតណាម នាឆ្នាំ ១៩៧៨ មក ក៏មានការឃោសនារីកដុះដាលថា វត្តមានរបស់កងទ័ពទាំងនេះមកកាន់ប្រទេសកម្ពុជា គឺជាសកម្មភាពមនុស្សធម៌ មិនមែនជាការរំលោភ ឬឈ្លានពាននោះទេ ។ ការឃោសនានេះ ត្រូវបានគេប្រើប្រាស់រយៈពេលជាង១០ឆ្នាំបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ ពីសំណាក់សម្ព័ន្ធមិត្តរបស់ពួកគេ មានដូចជា សហភាពសូវៀត និង ប្រទេសអាល្លឺម៉ង់ខាងកើត ។ រឿងនេះបានបន្តនិយាយរហូតមកដល់សព្វថ្ងៃ សូម្បីតែសារមន្ទីរទួលស្លែង ឬអតីតមន្ទីរសន្តិសុខស-២១ក៏បានបង្ហាញព័ត៌មានទាំងនេះដែរ ។*

*ទី២) ជនភៀសខ្លួនកម្ពុជា*

*ប្រជាជនភាគច្រើនដែលស្ថិតនៅក្នុងវណ្ណៈកណ្តាល និងវណ្ណៈខ្ពស់ នៅតែបន្តជះឥទ្ធិពលមកលើការយល់ដឹងពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។*

*ទី៣) ប្រព័ន្ធផ្សព្វផ្សាយ*

*បន្ទាប់ពីរបបខ្មែរក្រហម ប្រព័ន្ធផ្សព្វផ្សាយនានា ក៏បានចែករំលែកព័ត៌មានទាំងនេះ ដោយពុំបានត្រិះរិះ ហើយបណ្តាលឲ្យមានរឿងប្រឌិត មានសភាពដូចការពិតជាងមុន ព្រោះវាត្រូវបានគេយកមកនិយាយជាច្រើនសារ ។*

*ទី៤) ការប្រមូលផ្តុំនូវព្រឹត្តិការណ៍*

*ការចងចាំ ត្រូវបានផ្លាស់ប្តូរនៅពេលដែលមនុស្សបានដឹងនូវអ្វីដែលបានកើតឡើងរួចមក ។ រឿងទាំងនេះនឹងបន្តប្តូរនៅពេលមនុស្សនិយាយពីវាច្រំដែលៗ ។ យើងមិនបានចោទថា សាក្សីពោលពាក្យកុហកនោះទេ ដោយឡែកករណីនេះអាចកើតឡើងខ្លះដែរ ។ វាមានភាគរយខ្ពស់ដែលបុគ្គលមួយចំនួននិយាយពាក្យកុហកពីព្រោះរាល់ការនិយាយនានា មិនត្រូវបានឆ្លងកាត់នូវការធ្វើតេសនោះទេ បើទោះបីជាគាត់មិនបាននិយាយកុហក តែពេលខ្លះក៏យើងមិនអាចពឹងផ្អែកនូវការចងចាំរបស់គាត់ទាំងអស់បានដែរ ព្រោះការចងចាំពេលខ្លះ គឺមិនអាចយកជាការបានទេ ។ បន្ថែមលើនេះទៀត បញ្ហាដ៏លំបាកមួយ គឺការប្រមូលផ្តុំនូវការចងចាំនាសម័យនោះ ព្រោះចម្លើយខ្លះ គឺមិនអាចយកជាការបាន ។*

*មេធាវី លីវ សុវណ្ណ បានបន្ថែមថា បញ្ហាដ៏ធំដែលកើតមាននៅតុលាការ គឺបានលើកយក រឿងមិនពិតដែលយើងបានឮច្រើនដងមកនិយាយច្រំដែលៗ ហើយការស្វែងរកការពិតគឺមានភាគរយតិច ប្រសិនបើតុលាការនៅតែប្រើប្រាស់វិធីសាស្ត្រមួយនេះ ការពិតគឺមិនអាចរកឃើញនោះទេ ។*

*នៅត្រង់ចំណុចនេះ មេធាវី លីវ សុវណ្ណ បានបន្ថែមថា ការយល់ស្របទៅលើរឿងប្រឌិតនៃការកាត់ក្តីនេះ ត្រូវបានផ្លាស់ប្តូរដោយព្រឹត្តិការណ៍ធំៗចំនួន៣ ទី១) ដោយសារការរិះគន់អំពីសារព័ត៌មានឯករាជ្យ ដែលបានធ្វើការរិះគន់ទៅលើការកាត់ក្តីសំណុំរឿង០០២/០១ ។ ទី២) អង្គជំនុំជម្រះបានបញ្ជាក់ថា នេះ ជាការកាត់ក្តីចុងក្រោយរបស់ នួន ជា ។ ទី៣) ដោយសារអង្គជំនុំជម្រះតុលាការកំពូលបានចេញនូវការកាត់ក្តីសំណុំរឿង០០២/០១ ។ អង្គជំនុំជម្រះតុលាការកំពូល បានទម្លាក់ចោលការចោទប្រកាន់ នួន ជា ទាក់ទងការជម្លៀសប្រជាជន ការផ្លាស់ទីរបស់ប្រជាជនក្នុងសម័យនោះ និងការលើកលែងការចោទប្រកាន់ផ្នែកនយោបាយក្នុងអំឡុងជម្លៀសប្រជាជនជាលើកទីពីរ ។ អង្គជំនុំជម្រះបានធ្វើការចោទប្រកាន់ចំនួន៣ ទៅលើ នួន ជា ទាក់ទងទៅនឹងការសម្លាប់អតីតទាហានសម័យរដ្ឋការចាស់ និងការសម្លាប់ទាហាននៅទួលពោធិ៍ជ្រៃរួមជាមួយ ការសម្លាប់ និងការធ្វើឃាតអ្នកនយោបាយផ្សេងទៀត ។*

*មេធាវី លីវ សុវណ្ណ បានបកស្រាយទៀតថា នេះជាលើកទីមួយហើយដែលមេធាវីការពារក្តី ធ្វើការតតាំងទៅលើរឿងរ៉ាវនេះ ហើយបានបញ្ជាក់ថា ជោគវាសនារបស់ នួន ជា គឺពុំទាន់បានវិនិច្ឆ័យនោះទេ ។ ផ្នែកខ្លះក្នុងការវិនិច្ឆ័យរបស់តុលាការ គឺពុំសូវសមស្រប ព្រោះគោលគំនិតទាំងនេះមិនសូវមានភាពទាក់ទងជាមួយគ្នា បើពិនិត្យពិច័យលើផ្លូវច្បាប់ ។*

*បន្ទាប់មក មេធាវី លី សុវណ្ណ បានបកស្រាយពីសារសំខាន់នៃការកាត់ក្តីសំណុំរឿង០០២/០២ ។ អង្គជំនុំជម្រះតុលាការកំពូលយល់ថា ឈ្មោះ សំ សុធី ពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើសាក្សីទេ ។ សំ សុធី បាននិយាយថា គ្រួសាររបស់គាត់ត្រូវបានសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយចោទគ្រួសារគាត់ថា ជាអតីតនាយទាហានរបស់រដ្ឋការចាស់ ។ សុធី បានរៀបរាប់បន្តថា គាត់បានឃើញរឿងហេតុទាំងនេះដោយផ្ទាល់ភ្នែក ។*

*មេធាវី លីវ សុវណ្ណ បាននិយាថា នៅពេលដែល លោក សំ*

សុធី ត្រូវបានអង្គជំនុំជម្រះកោះហៅឲ្យមកផ្ដល់សក្ខីកម្ម លោកហាក់បីដូចជាបង្ហាញអារម្មណ៍ពេញចិត្ត ។ ប៉ុន្ដែ លោកហាក់បីដូចជាភ្លេចនូវរឿងរ៉ាវដ៏សែនសង្វេគ ដែលបានកើតឡើងចំពោះគ្រួសាររបស់លោក ។ រាល់ព័ត៌មានដែលលោកបានផ្ដល់ ហាក់ដូចជាពុំសូវពិត និងពោរពេញដោយភាពមិនអាចជឿទុកចិត្តបាន ។ ជាលទ្ធផល មេធាវីការពារក្ដីបានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលស៊ើបអង្កេតសក្ខីកម្មរបស់គាត់បន្ថែមទៀត ។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយនឹងសំណើររបស់មេធាវីការពារក្ដី ដើម្បីរកឲ្យឃើញថា ព័ត៌មានដែលទទួលបានហាក់បីដូចជាពុំមានភាពច្បាស់លាស់ និងមានភាពទន់ខ្សោយ ។ មេធាវីការពារក្ដីបានបន្ថែមទៀតថា គាត់អាចនឹងបំភ្លៃការពិត ឬ ប្រឌិតឡើងនូវព័ត៌មាន ព្រោះគាត់ធ្លាប់បានសរសេរអត្ថបទចុះផ្សាយ ដែលមានចំណុចខ្លះទាក់ទងនឹងរឿងនេះ ។

មេធាវី លីវ សុវណ្ណា បានរំឭកទៅកាន់អង្គប្រជុំថា នេះគឺជាអ្វីដែលចៅក្រមត្រូវផ្ដើរនៅអំឡុងពេលកាត់ក្ដី ។ លោកបានបន្ថែមថា ទោះបីជារឿងដែលទាក់ទងនឹងភាពឈឺចាប់របស់មនុស្សជាច្រើនក្ដី ក៏ប៉ុន្ដែ វានៅតែមានសារសំខាន់សម្រាប់មនុស្សគ្រប់គ្នាក្នុងការសួរសំណួរទៅកាន់សាក្សី ។ អង្គជំនុំជម្រះតុលាការកំពូលត្រូវសួរសំណួរលំបាកៗ ទៅកាន់ សំ សុធី ហើយអង្គជំនុំជម្រះក៏ពុំត្រូវមានភាពរអែងក្នុងការសួរនោះដែរ ។ មេធាវី លីវ សុវណ្ណា បានបន្ថែមថា លោកពិតជាជឿជាក់ថា ប្រធានអង្គជំនុំជម្រះ នឹងប្រាប់សាក្សីឲ្យនិយាយ ក៏ដូចជាផ្ដល់ចម្លើយដែលជាការពិតតែប៉ុណ្ណោះ ។ គាត់ក៏បានបន្ដទាមទារឲ្យតុលាការថ្លឹងថ្លែងនូវចម្លើយដែលសាក្សីបាន ផ្ដល់ ក៏ដូចជាបុគ្គលផ្សេងៗ ។ ជាបន្ទាប់ មេធាវី លីវ សុវណ្ណា ក៏បានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណា និងសម្រេចចំពោះភ័ស្ដុតាងផ្សេងៗ ទៀត ។

មេធាវី លីវ សុវណ្ណា បានបន្ថែមថា ឧទាហរណ៍ទីពីរ នៃភាពខុសគ្នាចំពោះការកាត់ក្ដី គឺការកំណត់លក្ខខណ្ឌ របៀបណាដែលអាចចោទជនម្នាក់អំពីបទមនុស្សឃាត ។

អង្គជំនុំជម្រះតុលាការកំពូល បានលើកឡើងថា រាល់ការពិតនីមួយៗ ត្រូវតែបញ្ជាក់រហូតទាល់តែអស់ចម្ងល់ ។ អង្គជំនុំជម្រះតុលាការកំពូលបានបន្ដថា ការបំបែកខ្សែសង្វាក់នៃភ័ស្ដុតាង គឺមិនអាចប្រព្រឹត្តទៅបានទេ ។ អង្គជំនុំជម្រះតុលាការកំពូល បានបកស្រាយពីអំពើឃាតកម្មដែលកើតមានឡើង ហើយអង្គប្រជុំនេះដែរបានប្រព្រឹត្តនូវកំហុសមួយយ៉ាងធ្ងន់ធ្ងរ គឺមើលត្រឹមតែរឿងទូទៅធម្មតា តែពុំបានសង្កេតឲ្យបានច្បាស់លាស់នូវការសម្លាប់ប្រជាជន ។ ហេតុផលនេះ តុលាការត្រូវស៊ើបឡើងវិញ ក៏ដូចជាត្រួតពិនិត្យនូវភ័ស្ដុតាងឡើងវិញ និងពិចារណាម្ដងទៀតនូវរាល់ការវិនិច្ឆ័យនានា ។

មេធាវី លីវ សុវណ្ណា ក៏បានសំណូមពរ ឲ្យអង្គជំនុំជម្រះពង្រឹងឡើងវិញ ព្រោះនេះគឺជាការកាត់ក្ដីចុងក្រោយរបស់ នួន ជា ហើយជនរងគ្រោះ ក៏ដូចជាជនជាប់ចោទ មិនអាចពឹងផ្អែកទៅលើការកាត់ទោសផ្សេងៗ ដើម្បីទទួលបានលទ្ធផលប្រសើរជាងនេះទេ ។ មេធាវី លីវ សុវណ្ណា បានបញ្ជាក់ថា វាអស់ពេលសម្រាប់ នួន ជា ក៏ដូចជាសាក្សី និងបុគ្គលផ្សេងៗ ប្រសិនបើ ការយល់ឃើញរបស់អង្គប្រជុំទាំងមូលមិនមានភាពផ្លាស់ប្ដូរ ។

បន្ទាប់មក មេធាវី លីវ សុវណ្ណា បានលើកឡើងវិញនូវច្បាប់ថ្មី ដើម្បីតវ៉ា ។ មេធាវី លីវ សុវណ្ណា បានបញ្ជាក់ថា ការដោះស្រាយថ្មីនេះ គឺមានភាពខុសគ្នាទៅនឹងអ្វីដែលអង្គប្រជុំនេះបានប្រើប្រាស់ពីមុនមក ។ មេធាវីការពារក្ដី ក៏បានរៀបចំឯកសារថ្មីទាក់ទងទៅនឹងច្បាប់ថ្មីដើម្បីតទល់ ។ មេធាវី បានបន្ថែមទៀតថា អ្នកស៊ើបអង្កេតពុំបានប្រើប្រាស់ច្បាប់ថ្មីដែលបានចែងនោះទេ ។ មេធាវី លី សុវណ្ណា បានរៀបរាប់ពីច្បាប់នេះថា ៖

១) នួន ជា នឹងត្រូវបានជាប់ទោស ប្រសិនបើមានភ័ស្ដុតាងជាក់លាក់ដាក់បន្ទុកទៅរូបគាត់ ក៏ប៉ុន្ដែប្រសិនភ័ស្ដុតាងនៅមានភាពមន្ទិលសង្ស័យនោះ នួន ជា នឹងត្រូវបានរួចខ្លួន ។ ភ័ស្ដុតាងដ៏ជាក់លាក់ និងច្បាស់លាស់មួយ គឺមិនសំដៅទៅលើចំនួននៃភ័ស្ដុតាងនោះទេ ។ យើងចង់បញ្ជាក់ឲ្យច្បាស់ថា មានតែការស្វែងរកកំហុសរបស់ នួន ជា ប៉ុណ្ណោះ ទើបអាចចាត់ទុកជាការបញ្ចប់នៃរឿងក្ដីនេះបាន ។

២) ភ័ស្ដុតាងទាំងអស់មិនត្រូវបានឲ្យតម្លៃស្មើគ្នានោះទេ

◆ ភ័ស្ដុតាងដែលផ្ដល់នៅក្នុងនៅតុលាការ គឺមានភាពជឿជាក់ជាងភ័ស្ដុតាងដែលបានមកពីសាក្សី ។ ភ័ស្ដុតាងដែលផ្ដល់នៅក្នុងតុលាការមានឥទ្ធិពលខ្លាំងជាងភ័ស្ដុតាងដែលបានមកពីប្រជាជនស៊ីវិល ពីព្រោះអ្នកទាំងនេះបានជួបបញ្ហានេះដោយផ្ទាល់ ។

◆ អង្គជំនុំជម្រះគួរតែពិចារណាចំពោះភាពជឿទុកចិត្តពីសាក្សី និងពីប្រជាជនស៊ីវិល

◆ អត្ថបទដែលត្រូវបានសរសេរឡើងដោយប្រជាជនស៊ីវិល ក៏ដូចជា អត្ថបទដែលបានប្រមូលផ្តុំក្រៅប្រព័ន្ធតុលាការ ពុំសូវមានតម្លៃនោះទេ ពីព្រោះភាពគួរឲ្យទុកចិត្តនៅមានកម្រិត

◆ ប្រសិនបើសាក្សីដែលជាប្រជាជនស៊ីវិល ឬ អ្នកជំនាញ មិនបានចូលរួមធ្វើជាសាក្សីនៅក្នុងតុលាការ នោះចម្លើយ ឬបទសម្ភាសរបស់ពួកគេ គឺពុំមានប្រសិទ្ធភាពនោះទេ លុះត្រាតែអត្ថបទទាំងនេះត្រូវបានអង្គជំនុំជម្រះធ្វើការត្រួតពិនិត្យជាមុនសិន ។ ដូចគ្នានេះដែរ ឯកសារដែលបានប្រមូលផ្តុំក្រៅប្រព័ន្ធតុលាការ ក៏ពុំសូវមានតម្លៃដែរ ពីព្រោះឯកសារទាំងនេះពុំបានឆ្លងកាត់ការវិនិច្ឆ័យឲ្យបានត្រឹមត្រូវ ។

◆ ភស្តុតាងដែលបានមកពីពាក្យចចាមអារាមមិនត្រូវបានឲ្យតម្លៃខ្ពស់នោះទេ ។

◆ ការអង្កេតភស្តុតាង ត្រូវតែធ្វើឡើងដោយយកចិត្តទុកដាក់ ព្រោះបុគ្គលមួយចំនួនដែលបានប្រព្រឹត្តអំពើនេះ អាចនឹងទម្លាក់កំហុសទាំងអស់មកលើ នួន ជា ហើយយករួចខ្លួន ។

◆ តម្លៃនៃភស្តុតាងពីអ្នកជំនាញ គឺចាំបាច់ត្រូវតែពឹងផ្អែកទៅលើភាពជឿជាក់ ភាពមិនលម្អៀង និងពោរពេញទៅដោយការសិក្សាស្រាវជ្រាវដែលមានគុណភាព ។

មេធាវី លីវ សុវណ្ណ បានសម្តែងការអាក់អន់ចិត្ត ចំពោះការិយាល័យស៊ើបអង្កេត ដែលមានជំនឿខ្លាំងពេកចំពោះរឿងមិនពិត ហើយមិនបានប្រើប្រាស់នូវច្បាប់ថ្មី ក៏ដូចជា មិនយកចិត្តទុកដាក់ចំពោះនីតិវិធីថ្មី ក្នុងការប្រមូលភស្តុតាង ។ មេធាវីការពារក្តីបានបញ្ជាក់ថា ការកាត់ទោសមួយនេះ បានពឹងផ្អែកតែលើភស្តុតាងដែលអង្គជំនុំយល់ស្របជាមួយតែប៉ុណ្ណោះ ។ មេធាវីការពារក្តីបានបន្តថា ការកាត់ទោសមួយនេះពឹងផ្អែកតែអំពីភស្តុតាងមួយចំនួនធំដែលទាក់ទងទៅនឹងការចោទប្រកាន់ ក៏ប៉ុន្តែភស្តុតាងដែលមានហេតុផលត្រឹមត្រូវ គឺពុំបានយកមកប្រើប្រាស់នោះទេ ។ ក្នុងនាមជាមេធាវីការពារក្តី ពិតជាមានការខកចិត្តជាខ្លាំងចំពោះចៅក្រមស៊ើបអង្កេត ពីព្រោះឯកសារដែលបានយកមកប្រើប្រាស់មួយចំនួន គឺបានប្រមូលផ្តុំក្រៅប្រព័ន្ធតុលាការ ដោយមានឯកសារខ្លះពុំមានលក្ខណៈសមស្របទៅតាមច្បាប់ថ្មីដែលបានចែង ហើយចម្លើយខ្លះទៀត គឺពុំអាចយកធ្វើជាភស្តុតាងបាននោះទេ ដោយសារវាជាពាក្យចចាមអារាម ។ រីឯឯកសារខ្លះទៀត គឺបានមកពីព័ត៌មាន និងសៀវភៅដែលអ្នកសរសេរខ្លះទទូចមិនចង់ធ្វើជាសាក្សី ។

មេធាវី លីវ សុវណ្ណ បាននិយាយថា ទោះបីជាការកាត់ក្តីផ្ទាល់មាត់ មានរយៈពេលខ្លីក៏ដោយ ក្នុងនាមយើងជាអ្នកការពារក្តី យើងនឹងបង្ហាញភស្តុតាងនានាតាមដែលអាចធ្វើបាន ហើយព្យាយាមបង្ហាញថា ការកាត់ទោសមួយនេះ គឺពុំបានប្រើប្រាស់នូវភស្តុតាង ដោយយោងទៅតាមច្បាប់ថ្មីដែលបានចែងនោះទេ ។ មេធាវីក៏បានស្នើទៅអង្គជំនុំជម្រះដែលរំពឹងតែទៅលើភស្តុតាងទាំងនេះ ឬលើភស្តុតាងស្រដៀងនេះយកមកប្រើប្រាស់ ហើយបានបញ្ជាក់ថា ការកាត់ក្តីនេះពុំអាចឆ្លងផុតពីការដាក់បន្ទុកនោះទេ ។ ជាបញ្ចប់ មេធាវីបាននិយាយថា នឹងបង្ហាញនូវភស្តុតាងយ៉ាងជាក់លាក់មួយ និងបញ្ជាក់ថា នួន ជា ពិតជាពុំមានកំហុសដូចករណី០០២/០២ បានចោទប្រកាន់នោះទេ ។

មេធាវី លីវ សុវណ្ណ ក៏បានផ្តល់វេទិកាទៅកាន់សហមេធាវីរបស់លោក វិកទ័រ កុប៉េ ។

មេធាវី វិកទ័រ កុប៉េ បានចាប់ផ្តើមដោយនិយាយអំពីការពិភាក្សាលើកមុន ដែលទាក់ទងរឿងរ៉ាវប្រឌិត ឬ រឿងមិនពិត ។ មេធាវី វិកទ័រ កុប៉េ បានបញ្ជាក់ថា វាពិតជាមានភាពងាយស្រួលណាស់ ដែលរឿងប្រឌិតមួយនេះត្រូវបានមហាជនជឿជាក់ប្រមាណ ១០ឆ្នាំកន្លងមក ព្រោះអ្នកប្រាជ្ញអង់គ្លេស ក៏ដូចជា ចៅក្រមជាច្រើនបានសរសេរសៀវភៅទាក់ទងអំពីបញ្ហាមួយនេះ ទោះបីគំនិតរបស់គេគ្មានភាពលម្អៀងក៏ដោយ ។

បន្ទាប់មក មេធាវី វិកទ័រ កុប៉េ បានបន្ថែមថា ដោយសាររឿងប្រឌិតមួយនេះត្រូវបានគេជឿជាក់ជាទូទៅ នោះរាល់ការផារបកស្រាយទាំងឡាយ នឹងត្រូវបានធ្លាក់មកលើមេធាវីការពារក្តី ។ មេធាវី វិកទ័រ កុប៉េ បានបន្ថែមថា ទោះបីវាជាភស្តុតាងដែលត្រូវគេយកមកប្រើប្រាស់ ប៉ុន្តែផ្នែកមួយចំនួនគឺមានលក្ខណៈស្រដៀងទៅនឹងការសន្មត់ទៅវិញ ។

អង្គជំនុំជម្រះ ត្រូវតែប្រព្រឹត្តទៅដោយភាពត្រឹមត្រូវជាងមុន ពីព្រោះច្បាប់ថ្មីត្រូវបានយកមកប្រើប្រាស់ និងអនុវត្តរួចរាល់

ហើយ ។

មេធាវី វិកទ័រ កុប៉េ បានបន្ថែមទៀតថា នេះមិនមែនជាតួនាទីរបស់ មេធាវីការពារក្តីដើម្បីតតាំងនោះទេ ប៉ុន្តែ វាគឺជាតួនាទីរបស់តុលាការដើម្បីបញ្ជាក់ថា រាល់ចម្លល់នឹងត្រូវបានបកស្រាយដោយមានភាពច្បាស់លាស់ ក៏ដូចជាពោរពេញទៅដោយភាពពិតប្រាកដ ។

ប្រសិនបើ មេធាវីការពារក្តីអាចរកឃើញនូវមន្ទិលចំពោះភ័ស្តុតាងនានានោះ ការកាត់ទោសនឹងមិនបានសម្រេចនោះទេ ។ ជាទូទៅ មេធាវីការពារក្តីត្រូវបានផ្តល់សិទ្ធិក្នុងការស៊ើបអង្កេតនៅក្នុងតុលាការ ប៉ុន្តែតុលាការមួយនេះត្រូវបានហាមប្រាមមិនឲ្យមានការអង្កេតក្តី ។ អ្នកស៊ើបអង្កេត មិនត្រូវប្រកាន់បក្សពួកខាងណានោះទេ ប៉ុន្តែអ្នកស៊ើបអង្កេតបានជឿជាក់ទៅលើរឿងដែលមិនពិតជាខ្លាំង បន្ថែមពីនេះទៅទៀត អ្នកស៊ើបអង្កេតមើលត្រឹមតែភ័ស្តុតាងដែលនាំជាប់ពិរុទ្ធព្រហ្មទណ្ឌ ប៉ុន្តែមិនមែនជាភ័ស្តុតាងដោះបន្ទុកនោះទេ ។ មេធាវីការពារក្តីគិតថានេះគឺជាការចរចាដែលមិនស្មើភាពមួយ ព្រោះការស៊ើបត្រូវបានបំបិទសិទ្ធិ ។ មេធាវី វិកទ័រ កុប៉េ បានបន្ថែមថា មេធាវីការពារចុងចោទបានស្វែងរក ឯកសារបរទេសសំខាន់ៗ ដើម្បីធ្វើជាឯកសារជំនួយក្នុងរឿងក្តីរបស់ នួន ជា ឧទាហរណ៍ដូចជា ការបង្ហាញនូវផ្នែកចាប់ផ្តើម និងផ្នែកបញ្ចប់នៃរឿងរ៉ាវទាំងមូល ។ មេធាវីការពារចុងចោទ ក៏បានធ្វើការជាមួយសាក្សីរបស់ភាគីដើមចោទដែលជារឿយៗតែងតែផ្តល់ភស្តុតាងទៅកាន់ករណីរបស់ លោក នួន ជា ។

បណ្តឹងក្នុងករណី ០០២/០១ បានបន្តដែលជាផ្លូវឈានទៅរកភ័ស្តុតាង តែតុលាការមិនបានចាប់អារម្មណ៍ក្នុងរឿងក្តីមួយនេះទេ ហើយក៏មិនបានបន្ថែមការស៊ើបអង្កេតដែរ ។ លោក ថេត សម្បត្តិ និង រ៉ូប៊ើត លីមគិន បានផ្តល់ព័ត៌មានបន្ថែម ទៅកាន់អង្គជំនុំជម្រះដែលព័ត៌មាននោះបានមកពីកុនឯកសារ ដែលមានចំណងជើងថា "សត្រូវប្រជាជនឯង" ។ ការសម្ភាស បានផ្តល់នូវព័ត៌មានទាក់ទងជាមួយអំពើក្បត់ជាតិធ្ងន់ធ្ងរក្នុងបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែអង្គចៅក្រម ពុំព្រមទទួលយកអត្ថបទនេះមកធ្វើជាភ័ស្តុតាងទេ ។

មេធាវី វិកទ័រ កុប៉េ បានបន្ថែមថា រាល់ភ័ស្តុតាងដែលមេធាវីការពារក្តី បានរកឃើញ និងត្រូវប្រមែប្រមូលមកធ្វើជាភ័ស្តុតាងសម្រាប់ការពារក្តី នួន ជា នេះ ពុំត្រឹមតែបន្ថែមនូវចម្លល់សម្រាប់ករណីរបស់ដើមចោទនោះទេ ប៉ុន្តែវាជាយុត្តិសាស្ត្រមួយសម្រាប់លុបបំបាត់នូវរឿងប្រឌិតដែលគេបានចោទប្រកាន់ទៅលើ នួន ជា ក៏ដូចជាយុទ្ធសាស្ត្រសម្រាប់ផ្លាស់ប្តូរនូវប្រវត្តិសាស្ត្រជាថ្មី ។

មេធាវី វិកទ័រ កុប៉េ នឹងបង្ហាញយ៉ាងខ្លីពីករណីរបស់ នួន ជា ប្តុ ម្យ៉ាងទៀតហៅថា រឿងក្រពើ និងធ្វើការឆ្លើយតបទៅលើការចោទប្រកាន់របស់ដើមចោទវិញ ។

មេធាវី វិកទ័រ កុប៉េ បានយកឯកសារបកប្រែដើម្បីជាគោលសម្រាប់ទាក់ទាញនូវចំណាប់អារម្មណ៍របស់ចៅក្រម ។ មេធាវី វិកទ័រ កុប៉េ បានបញ្ជាក់ថា ករណីបញ្ចប់សំណុំរឿង ០០២/០១ មិនត្រូវបានតុលាការបកប្រែមកជាភាសាខ្មែរ ប្រមាណជាងមួយឆ្នាំកន្លះមកហើយបន្ទាប់ពីការកាត់ក្តី ។ មេធាវី វិកទ័រ កុប៉េ បានសួរទៅកាន់ចៅក្រមថា តើលោកបានទទួលនូវឯកសារដែលទាក់ទងនឹងករណីរបស់អ្នកការពារក្តីជាភាសាខ្មែរដែរឬទេ ។ ដោយឡែករាល់បណ្តឹងសារទុក្ខ ខាងតុលាការកំពូលវិញ ត្រូវបានគេបកប្រែជាភាសាខ្មែរទាំងអស់ហើយក៏ត្រូវបានផ្តល់ទៅកាន់ចៅក្រមតុលាការកំពូលទាំងអស់រយៈពេលប្រមាណ១ឆ្នាំកន្លះមកនេះ ក៏ដូចជាមុនពេលដែលរឿងក្តីត្រូវបានកាត់ទោស ។ មេធាវី វិកទ័រ កុប៉េ បានធ្វើការអះអាងថាភាពខ្វះខាតមួយនេះអាចជារឿងហេតុមួយដែលមានការប៉ះពាល់ក្នុងការសម្រេចក្តី ។

ជាចុងក្រោយ មេធាវី វិកទ័រ កុប៉េ បានបញ្ជាក់បន្ថែមទៀតថា ករណី នួន ជា ពិតជាមានភាពសាំញ៉ាំណាស់ ដែលរាល់ការវិភាគនូវរឿងក្តីមួយនេះត្រូវធ្វើឡើងយ៉ាងល្អិតល្អន់ បន្ថែមពីនេះទៀត លោកបាននិយាយថា ចៅក្រមអាចយល់នូវករណីនេះលុះត្រាតែគាត់បានអាននូវសំណុំរឿងលម្អិតទាក់ទងរឿងនេះដោយផ្ទាល់ ដែលពុំមែនត្រឹមយោងទៅតាមជំនួយការរបស់ខ្លួនទេ ។ មេធាវី វិកទ័រ កុប៉េ បានស្នើសុំឲ្យមានការបកប្រែនូវឯកសារចុងក្រោយជាភាសាខ្មែរឲ្យបាន រយៈពេលមួយឆ្នាំមុនពេលការកាត់ក្តីត្រូវបានសម្រេច ។ មេធាវី វិកទ័រ កុប៉េ បានបន្ថែមថា បើពុំធ្វើបែបនេះទេ នោះវាហាក់បីដូចជាបានលុបបំបាត់នូវសិទ្ធស្មើភាពរបស់ នួន ជា ជាមួយការតវ៉ាក្តីពេលនេះ ក៏ដូចជាអ្នកការពារក្តីដែរ ។

**រ៉ូនិត អារី**

# រាជវង្សានុវង្សនៃព្រះរាជាណាចក្រកម្ពុជា

រាជាធិបតេយ្យប្រទេសកម្ពុជាមានលក្ខណៈពិសេសនិងបានដើរតួយ៉ាងសំខាន់នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ដែលជាអ្នកថែរក្សា បង្រួបបង្រួមជាតិ និងសន្តិភាពរបស់ប្រទេស ហើយត្រូវបានទទួលស្គាល់មានការយល់ដឹងច្បាស់លាស់ដោយអ្នកសង្កេតការណ៍ឃើញថាការបំបែកណាមួយនៃការបញ្ឈប់ចំណងភ្ជាប់ទៅនឹងរាជានិយមនឹងប្រជាជនកម្ពុជានឹងមានលទ្ធភាពធ្វើឲ្យប្រទេសមានអស្ថិរភាព ។

រាជវង្សានុវង្សកម្ពុជា ដែលជារាជវង្សមានវ័យចំណាស់មួយក្នុងពិភពលោកសព្វថ្ងៃនេះ ដើរតួយ៉ាងសំខាន់ក្នុងទិដ្ឋភាពផ្សេងៗនៃការស្ដាបនាឡើងវិញ និងការអភិវឌ្ឍជាតិនៃប្រទេសកម្ពុជាបន្ទាប់ពីសង្គ្រាមជាច្រើនឆ្នាំ និងរបបប្រល័យពូជសាសន៍ ប៉ុល ពត ។

សៀវភៅរបស់ខ្ញុំអំពីរាជវង្សានុវង្សនៃប្រទេសកម្ពុជាត្រូវបានបោះពុម្ពផ្សាយដំបូងក្នុងឆ្នាំ២០០៣ នៅពេលព្រះករុណាព្រះបាទសម្ដេច ព្រះបរមរតនកោដ្ឋ ពេលដែលព្រះអង្គនៅជាព្រះមហាក្សត្រ ។ តាមការស្នើសុំរបស់សមាជិករាជវង្សានុវង្ស ខ្ញុំបានសម្រេចចិត្តធ្វើការកែសម្រួល និងពង្រីកបន្ថែមសៀវភៅរបស់ខ្ញុំត្រូវបានបង្ហាញក្នុងព្រះរាជពិធីមួយនៅព្រះបរមរាជវាំងដើម្បីថ្វាយព្រះករុណាព្រះបាទសម្ដេច ព្រះបរមនាថ នរោត្ដម សីហមុនី និងព្រះមហាក្សត្រីយានី នរោត្ដម មុនិនាថ សីហនុ នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ ។

សៀវភៅអំពីរាជវង្សានុវង្សនៃព្រះរាជាណាចក្រកម្ពុជា មានដាក់លក់នៅបណ្ណាល័យសៀវភៅម៉ូនុយមែនប៊ុក ។

ការបោះពុម្ពថ្មីបានបន្ថែមជំពូកថ្មីដែលបានសរសេរដូចខាងក្រោម ៖

១) ព្រះករុណា ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្ដម



ព្រះករុណា ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្ដម សីហមុនី និងបណ្ឌិត ហូលីយ៉ូ ដែលជ្រេស អ្នកនិពន្ធសៀវភៅ "រាជវង្សានុវង្សនៃព្រះរាជាណាចក្រកម្ពុជា" បានបោះពុម្ពឡើងវិញ និងសម្ភាធ នៅព្រះបរមរាជវាំង កាលពីខែធ្នូ ឆ្នាំ២០១៧ ។




សីហមុនី

២) ព្រះករុណា ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ

៣) សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ

៤) ព្រះមហាក្សត្រីយានី ស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្នសេរីវឌ្ឍនា

៥) រាជវង្សានុវង្សជំនាន់ក្រោយ ព្រះអង្គម្ចាស់និងព្រះអង្គម្ចាស់ក្សត្រី

៦) សមាជិករាជវង្សានុវង្សដែលបានស្លាប់ក្នុងរបបខ្មែរក្រហម

៧) គ្រឿងឥស្សរិយយស

នៅក្នុងសុន្ទរកថារបស់ព្រះអង្គនៅថ្ងៃទី១៩ ខែធ្នូឆ្នាំ២០១៧ ព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហមុនី បានមានបន្ទូលដូច្នេះថា៖ “នៅឆ្នាំ២០០៣ ការបោះពុម្ពលើកទីមួយនៃសៀវភៅដ៏សំខាន់នេះត្រូវបានបោះពុម្ពផ្សាយនិងលក់បានយ៉ាងឆាប់រហ័សចំនួន ៣.០០០ក្បាល ។ នៅពេលនោះជាព្រះវរបិតាជាទីស្រឡាញ់ និងសោកស្តាយរបស់យើង ព្រះករុណា ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ សព្វព្រះរាជហឫទ័យចំពោះការបោះពុម្ពផ្សាយសៀវភៅរាជវង្សានុវង្សពីព្រោះសៀវភៅនេះបានរកឃើញនូវប្រវត្តិសាស្ត្រដ៏កម្រ និងគួរឲ្យសោកស្តាយបំផុតក្នុងប្រវត្តិសាស្ត្រគ្រួសាររាជវង្សានុវង្សរបស់យើងដែលបានចាប់ផ្តើមដោយសម្តេចព្រះមហាក្សត្រអង្គឌួងជាអ្នកស្តាររាជាធិបតេយ្យ ។

ជំពូកស្តីអំពីរាជវង្សានុវង្សជំនាន់ក្រោយ ព្រះអង្គម្ចាស់ និងព្រះអង្គម្ចាស់ក្សត្រី បានរួមបញ្ចូលទាំងអត្ថបទជាលាយល័ក្ខណ៍អក្សរចំពោះសមាជិកម្នាក់ៗនៃព្រះរាជវង្សានុវង្សដែលកំពុងរួមចំណែកតាមរយៈការងាររបស់ទ្រង់ ក្នុងការកសាង និងអភិវឌ្ឍជាតិកម្ពុជាឡើងវិញ ក្នុងវិស័យសិល្បៈ ធនាគារ ធុរកិច្ច កិច្ចការងារសប្បុរសធម៌ ការអប់រំ បដិសណ្ឋារកិច្ច ស្តារឡើងវិញ និងវិស័យទេសចរណ៍ ។

ទ្រង់បានចូលរួមដើម្បីចែករំលែករូបភាព និងរឿងរ៉ាវនៃជីវិតរបស់ទ្រង់ទាំងនៅខាងក្រៅប្រទេសកម្ពុជា ក្នុងអំឡុងពេលនិរទេសខ្លួន និងនៅក្នុងប្រទេសចាប់តាំងពីការវិលត្រឡប់របស់ទ្រង់ពីបរទេស ។

បន្ថែមជំពូកនេះសៀវភៅរាជវង្សានុវង្សខ្ញុំមានអារម្មណ៍ថាសាធារណជនទូទៅនឹងចាប់អារម្មណ៍ចង់ដឹងថាសមាជិករាជវង្សានុវង្សកម្ពុជា ដែលជារាជវង្សមានវ័យចំណាស់មួយក្នុងពិភពលោកដែលមានសកម្មភាព និងឥរិយាបថប្រព្រឹត្តខុសគ្នាពីគ្រួសាររាជវង្សដទៃទៀតក្នុងន័យថាតាមរយៈការងាររបស់ទ្រង់ សកម្មភាពសប្បុរសធម៌ការចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍ និងការកសាងប្រទេសឡើងវិញហើយមិនពឹងផ្អែកលើការរស់រានមានជីវិតរបស់ទ្រង់នៅក្នុងបញ្ជីស៊ីវិលជាបញ្ជីបុគ្គលដែលត្រូវបានបង់ដោយរដ្ឋាភិបាលជារឿងសាមញ្ញក្នុងចំណោមរាជវង្សនៅអឺរ៉ុប ។

ជំពូកទាក់ទងនឹងវាសនារាជវង្សក្នុងកំឡុងសម័យខ្មែរក្រហមដ៏ឃោរឃៅ (១៩៧៥-១៩៧៩) ត្រូវបានពង្រីកបន្ថែមជាមួយរូបថត និងឯកសារថ្មីៗមួយចំនួន ។

សៀវភៅនេះ គឺជាការគោរពដ៏ជ្រាលជ្រៅចំពោះ ព្រះករុណាព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ដែលខ្ញុំមានឯកសិទ្ធិបម្រើទ្រង់ ចាប់តាំងពីឆ្នាំ១៩៨១ ជាលេខាធិការផ្ទាល់ហើយបន្ទាប់មកជាអ្នកនិពន្ធជីវប្រវត្តិផ្លូវការ ។ ខ្ញុំបានរៀនសូត្រជាច្រើនពីព្រះមហាក្សត្រសម្តេចឪ ។ ជាពិសេសរបៀបក្នុងការស្រឡាញ់ និងគោរពពលរដ្ឋគ្រប់ជាន់ថ្នាក់នៃប្រទេសដ៏ស្រស់ស្អាតមួយនេះ ។ សម្រាប់រឿងអស់នោះ ខ្ញុំមានអំណរគុណជាទីនិរន្តរ៍ចំពោះព្រះករុណាព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ។

សៀវភៅ៣១៨ទំព័រ នឹងគួរជាទីចាប់អារម្មណ៍ចំពោះអ្នកប្រាជ្ញប្រវត្តិវិទូ និស្សិត និងសាធារណជនទូទៅដែលមានបំណងចង់យល់ដឹងបន្ថែមអំពីរាជានិយម និងរាជវង្សនៃព្រះរាជាណាចក្រកម្ពុជា ។ **ហ្សូលីយ៉ូ ជែលត្រេស**

# ពិធីសម្ពោធសៀវភៅដែលមានចំណងជើងថា រាជវង្សានុវ
# ហ្វូលីយ៉ូ វ៉ែលជ្រេស នៅព្រ









# ទ្យនៃព្រះរាជាណាចក្រកម្ពុជា ដែលសរសេរដោយបណ្ឌិត
# ព្រះបរមរាជវាំង ក្រុងភ្នំពេញ









# មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ត្រូវបានរៀបចំបង្កើតឡើងនៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង ក្រោមកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ដែលមានជំនួយទ្រទ្រង់ពីសហភាពអឺរ៉ុប និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍអន្តរជាតិ ។ គោលបំណងសំខាន់ក្នុងការបង្កើតមជ្ឈមណ្ឌលឯកសារនេះ គឺមិនត្រឹមតែជួយបង្កើនឲ្យមានការទទួលបានព័ត៌មានស្តីអំពីរបបខ្មែរក្រហមតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រេចបាននូវបណ្តាញមូលដ្ឋានដែលមាននិរន្តរភាពក្នុងការចែករំលែកព័ត៌មានដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្រុមគ្រួសារ ។

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដឹកនាំដោយលោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានចូលរួមកិច្ចប្រជុំមួយដែលរៀបចំដោយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង និងមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមអធិបតីភាពរបស់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាសម្រេច និងពិនិត្យមើលទីតាំងបន្ទប់ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលជាការប្រគល់ជាផ្លូវការពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង ក្រោមការឯកភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ កិច្ចប្រជុំបានពិភាក្សាជាចម្បងលើការរៀបចំ រចនាបន្ទប់ និងបំពាក់ឧបករណ៍ការិយាល័យមួយចំនួនដែលបម្រើដល់ប្រយោជន៍នៃការចែករំលែកព័ត៌មានស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់សាធារណជន រួមទាំងប្រជាជនក្នុងខេត្តព្រៃវែង ស្វាយរៀង និងជនពិការផង ។ ក្នុងនោះ ឯកសារដែលមានតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួនប្រមាណជាង១លានឯកសារ រួមមាន ឯកសារជាក្រដាស រូបថត ខ្សែភាពយន្ត ខ្សែអាត់សំឡេង និងឯកសារភ័ស្តុតាងជាក់ស្តែង (ឯកសាររណ្តៅសាកសព) នឹងត្រូវយកមកដាក់នៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ។ ឯកសារទាំងនេះនឹងផ្តល់នូវព័ត៌មានស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមយ៉ាងសម្បូរណ៍បែបក្នុងការបម្រើដល់គ្រូបង្រៀន មន្ត្រីរាជការ សិស្សានុសិស្ស និងអ្នករស់នៅក្នុងខេត្តព្រៃវែង និងសាធារណៈដែលមានទីតាំងស្ថិតនៅជាប់នឹងខេត្តនេះទៀតផង ។ តាមរយៈការបង្កើតបន្ទប់ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង វេទិកាអប់រំចល័តក៏នឹងលេចចេញរូបរាងឡើងនាពេលដ៏ខ្លីខាងមុខនេះដែរ ។

លោក ប៊ុយ វុទ្ធី នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង បានសម្តែងការស្វាគមន៍ អបអរសាទរ និងរីករាយចំពោះការបង្កើតបន្ទប់ការិយាល័យមជ្ឈមណ្ឌលឯកសារនេះនៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង ព្រមទាំងបានបង្ហាញពីឧត្តមគតិយ៉ាងមោះមុតក្នុងការថែរក្សានិងការពារដំណើរការនៃការអនុវត្តការងារនៃមជ្ឈមណ្ឌលឯកសារថ្មីនេះឲ្យស្ថិតស្ថេរគង់វង្សរហូត ដើម្បីជាប្រយោជន៍មិនត្រឹមតែគ្រូបង្រៀន គរុសិស្ស និងសិស្សានុសិស្សក្នុងទីរួមខេត្តព្រៃវែងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រជាជនទាំងឡាយដែលកំពុងរស់នៅក្នុងទីជនបទនៃខេត្តព្រៃវែងទៀតផង ។ មានប្រសាសន៍នៅក្នុងកិច្ចប្រជុំនាថ្ងៃដដែល លោក ប៊ួយ វុទ្ធី បានថ្លែងថា «កុំថាឡើយប្រជាជនដែលរស់នៅក្នុងទីជនបទក្នុងខេត្ត សូម្បីតែអ្នករស់នៅក្នុងក្រុងព្រៃវែងមួយចំនួនក៏មិនស្គាល់ទីតាំងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនេះផង ។ ខ្ញុំចង់ឲ្យពួកគាត់ស្គាល់ និងស្វែងយល់ពីកិច្ចការដែលយើងកំពុងធ្វើ និងបង្រៀន ។ នេះជាឱកាសល្អមួយដែលខ្ញុំអាចនិយាយទៅកាន់អ្នកទាំងនេះ (អ្នកក្រុង) និងប្រជាជនដែលរស់នៅតាមជនបទថា ខ្ញុំមានបន្ទប់បណ្ណាល័យមួយដែលសម្បូរណ៍ទៅដោយឯកសារប្រវត្តិសាស្ត្រ ជាពិសេសប្រវត្តិសាស្ត្រខ្មែរក្រហមតែម្តង ។ ខ្ញុំចង់ឲ្យពួកគាត់មកមើល និងរៀនសូត្របន្ថែមពីប្រវត្តិសាស្ត្រដ៏ជូរចត់នារបបខ្មែរក្រហម ហើយចង់ឲ្យគាត់ចែករំលែករឿងរ៉ាវរបស់គាត់មកកាន់យើង ដើម្បីយើងថែរក្សាប្រវត្តិរបស់គាត់» ។ បន្ថែមលើអ៊ី

ដែលលោក ប៉ូយ វុទ្ធី បាននិយាយកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ លោកបានបង្ហាញពីគំនិតផ្ទាល់ខ្លួននៅថ្ងៃទី២៥ ខែឆ្នាំដដែលប្រាប់ដល់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា លោកចង់ឲ្យមានកម្មវិធីវេទិកាពិភាក្សាដាច់ដោយឡែកពីគ្នាជាច្រើនដងរាប់ចាប់តាំងពីមន្ត្រីរាជការក្នុងខេត្ត ស្រុក ឃុំ ភូមិ និងប្រជាជនដោយអញ្ជើញអ្នកទាំងនោះមកចូលទស្សនាបន្ទប់ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងចូលរួមពិភាក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមដែលបានកើតឡើងក្នុងទូទាំងប្រទេស និងចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនដើម្បីបំពេញបន្ថែមទំព័រប្រវត្តិសាស្ត្រនេះ ឲ្យមានទំព័រកាន់តែច្រើនឡើងថែមទៀត ក្នុងន័យបង្កើតជាមេរៀនប្រវត្តិសាស្ត្រសម្រាប់ក្មេងៗជំនាន់ក្រោយធ្វើការសិក្សា និងស្រាវជ្រាវ ។

លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា លោកជំទាវមានមោទកភាពខ្ពស់ណាស់ដែលក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការបង្កើតបន្ទប់ការិយាល័យមជ្ឈមណ្ឌលឯកសារក្នុងខេត្តព្រៃវែង ។ លោកជំទាវ បានសម្តែងការគាំទ្រយ៉ាងខ្លាំងចំពោះកិច្ចការនេះ ហើយបានមានមតិផ្តាំផ្ញើមួយចំនួនទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មានស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ការចូលរួមថែរក្សាធ្វើយ៉ាងណាឲ្យបន្ទប់ការិយាល័យនេះស្ថិតនៅជានិច្ចនិរន្ត និងបើកទ្វារបម្រើដល់មហាជនទូទៅដើម្បីពង្រីកការយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម និងព្យាយាមប្រមូលសាច់រឿងដែលបានកើតឡើងក្នុងភូមិឃុំនីមួយៗជុំវិញខេត្ត ។ ទោះជាយ៉ាងនេះក៏ដោយ ក៏លោកជំទាវបានសម្តែងនូវការព្រួយបារម្ភខ្លះៗទាក់ទងនឹងការថែរក្សាបន្ទប់ការិយាល័យ និងរបៀបនៃការទុកដាក់ និងប្រមូលឯកសារប្រវត្តិសាស្ត្រឲ្យនៅគង់វង្សជារៀងរហូត ។ លោកជំទាវបានលើកឧទាហរណ៍មួយចំនួនដែលបង្ហាញពីការខ្វះការយកចិត្តទុកដាក់ និងថែរក្សានូវអ្វីដែលក្រសួងអប់រំ យុវជន និងកីឡា បានប្រគល់ទៅឲ្យសាលារៀនជាអ្នកគ្រប់គ្រង បន្ទាប់ពីមានការប្រគល់ជាផ្លូវការរួចមក តួយ៉ាងដូចជាម៉ាស៊ីនដេរសម្រាប់មុខវិជ្ជាគេហវិទ្យាជាដើម ។ មុននឹងបញ្ចប់សុន្ទរកថា លោកជំទាវបានមានប្រសាសន៍ថា ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា មិនត្រឹមតែបង្កើតបន្ទប់ការិយាល័យតែមួយ នៅក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតមជ្ឈមណ្ឌលឯកសារដូចគ្នានេះនៅគ្រប់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦ ហើយដំណើរការនេះនឹងត្រូវធ្វើឡើងជាបន្តបន្ទាប់ទៀត ។

សូមបញ្ជាក់ថា ក្រសួងអប់រំ យុវជន និងកីឡា និង មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រយៈពេលប្រាំឆ្នាំបន្តទៀតពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ក្នុងការបន្ត និងបង្កើតថ្មីនូវកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដើម្បីពង្រីកវិសាលភាពនៃការអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់យុវជនជំនាន់ក្រោយ និងគ្រូបង្រៀនទូទាំងប្រទេសឲ្យយល់កាន់តែច្បាស់ពីរឿងរ៉ាវពីអតីតកាលរបស់ប្រទេសខ្លួនដែលនាំឲ្យប្រទេសជាតិជួបសោកនាដកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងដើម្បីធានាថា សោកនាដកម្មទាំងនេះនឹងមិនកើតឡើងជាថ្មីម្តងទៀតឡើយលើប្រទេសកម្ពុជា ។ ក្នុងន័យនេះ មជ្ឈមណ្ឌលឯកសារចំនួន៥ទៀតដែលនឹងត្រូវបង្កើតឡើងនាពេលខាងមុខ គឺជាផ្នែកមួយនៃកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។

ជារួម មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងមជ្ឈមណ្ឌលឯកសារនៅតាមបណ្តាខេត្តចំនួន៥ទៀត គឺត្រូវបានបង្កើតឡើងដើម្បីប្រជាជនកម្ពុជាទូទាំងប្រទេសចូលរួមដឹកនាំ និងទទួលបានភាពជាម្ចាស់លើប្រវត្តិសាស្ត្រខ្លួនឯង ។ **ផេង ពង្សរ៉ាស៊ី**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* និង *truthcambodia.com* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ!



ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដឹកនាំដោយលោក ឆេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ចូលរួមកិច្ចប្រជុំដែលរៀបចំដោយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង ក្រោមអធិបតីភាពរបស់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាសម្រេច និងពិនិត្យមើលទីតាំងបន្ទប់ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលប្រគល់ជាផ្លូវការពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង ក្រោមការឯកភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ។







# រឿងរ៉ាវក្រុមគ្រួសារលោក ទេព ឌួង

លោក ទេព ឌួង ធ្វើជានាយទាហានជំនាន់អាណានិគមនិយម បារាំង រហូតដល់ឆ្នាំ១៩៥៩ ទើបគាត់លាឈប់ ។ លោក ឌួង ទៅបម្រើការងារនៅក្រុមហ៊ុនភេសជ្ជៈ បេ ហ្សេ អី (BGI) ដោយមានតួនាទីជានាយករង (ទទួលបន្ទុកការងារនៅខេត្តកំពង់ធំ កំពង់ចាម ក្រចេះ និងស្ទឹងត្រែង) ។

លោក ឌួង ស្រឡាញ់សិល្បៈណាស់ ហើយគាត់ចេះលេងឧបករណ៍ភ្លេងមួយចំនួនទៀតផង ។ នៅរដូវបុណ្យភ្ជុំបិណ្ឌ លោក ឌួង តែងតែមកស្រុកកំណើតនៅភូមិពាមឆ្កោក ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង ហើយរៀងរាល់ពេលយប់ គាត់តែងតែប្រមូលសម្ភារភ្លេងដាក់លើទូកដើម្បីប្រគុំកម្សាន្តសប្បាយ និងបណ្តែតតាមដងទន្លេរហូតដល់ថ្ងៃគាត់ត្រឡប់ទៅភ្នំពេញវិញ ។ នៅមុនពេលរបបខ្មែរក្រហម គ្រួសារលោក ឌួង រស់នៅជាប់ផ្លូវដឹម៉ុងតេរ៉ូ ក្បែរស្ពានជ្រោយចង្វារ ម្តុំផ្សារតូច រាជធានីភ្នំពេញសព្វថ្ងៃ ។ លោក ឌួង មានភរិយាឈ្មោះ លោកស្រី សូ ផាត់ និងមានកូនប្រុសស្រី ចំនួន ១៣នាក់ ។


ទេព វិឡៃ

ក្រោយរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ឆ្នាំ១៩៧០ លោក លន់ នល់ បានប្រមូលអតីតនាយទាហានឲ្យមកបម្រើការវិញ ពេលនោះ លោក ឌួង ក៏បានធ្វើជាមេបញ្ជាការឈរជើងនៅខេត្តឧត្តរមានជ័យ ។ ប៉ុន្តែចាប់ពីក្រោយឆ្នាំ១៩៧៩ ក្រុមគ្រួសារលោក ឌួង ក៏បាត់ដំណឹងរហូតមក ។

លោកស្រី ទេព វិឡៃ ជាកូនស្រីច្បងរបស់លោក ទេព ឌួង និងអ្នកស្រី សូផាត់ ។ ទេព វិឡៃ ជាស្ត្រីដែលមានសម្រស់ផូរផង់ (ដូចកូនកាត់បារាំង) ។ ទេព វិឡៃ ត្រូវបានជ្រើសរើសជានាង សុជាតា ជាកញ្ញាឯកមានសម្រស់ស្អាត សម្រាប់ពិធីបុណ្យពាក់កណ្តាលសាសនា នៅពេលនោះ ។ ទេព វិឡៃ រៀបការជាមួយ លោក ពេជ្រ ណារ៉ុង ដែលជាកូនប្រុសទោលរបស់លោក ពេជ្រ លឹម និងអ្នកស្រី ទៀប ឡាយ តាំងពីអាយុប្រមាណ១៨ឆ្នាំ ។

មុនសម័យប៉ុលពត ទេព វិឡៃ បាន



ពេជ្រ ណារ៉ុង

លែងលះប្តី ពេជ្រ ណារ៉ុង ហើយបានស្លាប់ដោយសារជំងឺមុនពេលកងទ័ពខ្មែរក្រហមចូលមកដល់ក្រុងភ្នំពេញ ។ សពរបស់ ទេព វិឡៃ ត្រូវបានដាក់តម្កល់នៅក្នុងវិហារកាតូលិក ម្តុំផ្សារតូច ។ ក្រោយមក វិហារនោះត្រូវបានវាយកម្ទេចចោល ហើយសព្វថ្ងៃបានក្លាយជាផ្ទះ ជាផ្សារ ទៅហើយ ។

ទេព វិឡៃ មានកូន៤នាក់ (ស្រី៣ ប្រុស១) ហើយក្នុងចំណោមកូនទាំង៤នាក់នោះមានតែម្នាក់ប៉ុណ្ណោះដែលនៅរស់រហូតដល់សព្វថ្ងៃនេះ គឺលោកស្រី ពេជ្រ សំផាន មានអាយុ៥៨ឆ្នាំ រស់នៅក្រុងកំពង់ចាម ខេត្តកំពង់ចាម ដែលជាទីកន្លែងរបស់លោកស្រី ទេព វិឡៃ រស់នៅពីក្មេងជាមួយជីដូនជីតាខាងឪពុក ។ រីឯកូនបីនាក់ទៀតរបស់លោកស្រី ទេព វិឡៃ បានស្លាប់នៅក្នុងសម័យខ្មែរក្រហមម្នាក់ និងក្រោយសម័យខ្មែរក្រហមពីរនាក់ ។

លោកស្រី ពេជ្រ សំផាន និងកូនស្រីប្រុសតែងតែព្យាយាមស្វែងរកដំណឹងក្រុមគ្រួសាររបស់លោក ទេព ឌួង និងលោកស្រី សូ ផាត់ រួមជាមួយកូនប្រុសស្រីរបស់លោក ទេព ឌួង និងអ្នកស្រី សូ ផាត់ ដែលត្រូវជាឪពុកមា និងម្តាយមីងរបស់អ្នកស្រី ពេជ្រ សំផាន ។ កាលពីចុងឆ្នាំ២០១៨ កូនប្រុសរបស់លោកស្រី ពេជ្រ សំផាន បានស្វែងរកឃើញសាច់ញាតិមួយចំនួនដែលត្រូវជាក្មួយប្រុសស្រីរបស់លោក ទេព ឌួង និងលោក ស្រី សូផាត់ ប៉ុន្តែពុំដែលបានទទួលដំណឹងពីកូនប្រុសស្រីបង្កើតរបស់លោក ទេព ឌួង និងអ្នកស្រី សូ ផាត់ ឡើយ ។ លោកស្រី ពេជ្រ សំផាន នៅតែមានការជឿជាក់ថា ក្នុងចំណោមឪពុកមា ម្តាយមីងទាំង១៣នាក់ ប្រាកដជាមានអ្នកនៅរស់រានមានជីវិត ។



ពេជ្រ សំផាន

◆ សមាជិកគ្រួសាររបស់លោក ទេព ឌួង និងលោកស្រី សូ ផាត់ មាន៖

១) ទេព វិឡុង
២) ទេព វិឡាម (ហៅយក្ស)
៣) ទេព វិឡន់
៤) សង្ហា បានប្រពន្ធសែស្រឡាយរបស់ លន់ នល់
៥) ម៉ាប់
៦) ទេព កុសល ហៅ សុខ
៦) ទេព សាវី
៧) ពៅ
៨) ប្រុស
៩) ស្រីឡុង
១០) ស្រីឡែន

**សែម ចិន្តា**

# ដំណឹងស្វែងរកសមាជិកគ្រួសារដែលបាត់ខ្លួនក្នុងសម័យខ្មែរក្រហម

◆ ខ្ញុំបាទឈ្មោះ ទឹម សាន សូមគោរពមជ្ឈមណ្ឌលឯកសារកម្ពុជាជាទីរាប់អាន ។ ខ្ញុំបាទសូមស្នើមជ្ឈមណ្ឌលឯកសារកម្ពុជាជួយស្វែងរកឈ្មោះឪពុក និងឪពុកមាទាំងបួនដែលបានបាត់ខ្លួនក្នុងសម័យកាលខ្មែរក្រហម ។ ឪពុកខ្ញុំបាទមានបងប្អូនប្រាំនាក់ (ប្រុសទាំងអស់) ។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ឪពុក និងបងប្អូនបីនាក់ទៀតបានបាត់ខ្លួនជាបន្តបន្ទាប់ ក្រោមហេតុផលថាអង្គការហៅទៅរៀនសូត្រ និងប្តូរទីកន្លែងបំពេញការងារ ។ ឈ្មោះដែលបាត់ខ្លួនទាំង៤នាក់ រួមមាន៖

១) អ៊ិន ហេន អតីតគ្រូបង្រៀន នៅសាលាចំរើនរដ្ឋ ក្រុងភ្នំពេញ ត្រូវជាឪពុក ។

២) អ៊ិន ហុន មេឃុំកំពង់កុង ស្រុកអង្គរជ័យ ខេត្តកំពត

៣) អ៊ិន ហ៊ុត និស្សិតសាលាតិចណូ ភ្នំពេញ

៤) អ៊ិន សារិ និស្សិតសាកលវិទ្យាល័យភូមិន្ទភាកែវ កំពត

ក្រុមគ្រួសារទាំងអស់របស់ឪពុកខ្ញុំបាទ មានស្រុកកំណើតនៅភូមិស្មោង ឃុំសំលាញ ស្រុកអង្គរជ័យ ខេត្តកំពត ។ ខ្ញុំបាទសូមអរគុណមជ្ឈមណ្ឌលឯកសារកម្ពុជាទុកជាមុន ដែលបានជួយផ្សព្វផ្សាយដំណឹងនេះ ។

◆ ខ្ញុំបាទឈ្មោះ ហ៊ិន សារុន សូមគោរពមជ្ឈមណ្ឌលឯកសារកម្ពុជា ជាទីរាប់អាន ។ ខ្ញុំបាទសូមស្នើមជ្ឈមណ្ឌលឯកសារកម្ពុជាជួយស្វែងរកឈ្មោះឪពុក ម្តាយធំ និងកូនបីនាក់ ដែលបានបាត់ដំណឹងនៅពេលដែលក្រុងភ្នំពេញធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ដូចមានរាយឈ្មោះខាងក្រោម៖

១) កង សយ ភេទប្រុស ជាមន្ត្រីធ្វើការនៅពន្ធនាគារព្រៃសរ

២) ហ៊ិន យ៉ន មេផ្ទះ ត្រូវជាប្រពន្ធឈ្មោះ កង សយ

៣) កង សុន ត្រូវជាកូនប្រុស និង

៤) កូនស្រីៗពីរនាក់ទៀត ។

ខ្ញុំខិតខំស្វែងរកអ្នកទាំង៤ស្ទើរគ្រប់ទីកន្លែង រួមទាំងនៅសារមន្ទីរទួលស្លែងផង ប៉ុន្តែនៅតែរកមិនឃើញសោះ ។ ហេតុដូច្នេះខ្ញុំបាទស្នើ សុំមជ្ឈមណ្ឌលឯកសារកម្ពុជា មេត្តាជួយស្រាវជ្រាវរកឈ្មោះខាងលើឲ្យខ្ញុំបាទដោយក្តីអនុគ្រោះ ។

***សូមអរគុណ!***

# ៧ មករា ១៩៧៩ ដល់ ៧ មករា ២០១៨ ជាថ្ងៃកំណើតជីវិតទី២របស់ខ្ញុំ បាន៣៩ឆ្នាំហើយ

## *មនុស្សសំណាងមួយនាក់ ក្នុងចំណោមមនុស្ស៥.០០០នាក់ ដែលមានជីវិតរស់នៅ រួចផុតពីការកាប់សម្លាប់ក្នុងរបបខ្មែរក្រហម*

*ប្រវត្តិពិតៗជាច្រើនឆ្នាំមកហើយ ដែលខ្ញុំលាក់ទុកក្នុងចិត្ត...*

ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសកម្ពុជាយើងបានធ្លាក់ចូលទៅក្នុងភ្លក់ភ្លើងសង្រ្គាមយ៉ាងសន្ធោរសន្ធៅ ប្រជាពលរដ្ឋខ្មែរទាំងអស់បានក្លាយទៅជាចំណាប់ខ្មាំងរបស់សង្រ្គាម មានន័យថា ប្រជាជនម្ខាងស្ថិតនៅក្នុងការគ្រប់គ្រងរបស់របបសាធារណរដ្ឋខ្មែរ ដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ ។ រីឯប្រជាជនម្ខាងទៀត ស្ថិតនៅក្នុងតំបន់រំដោះ ដែលមានសម្តេចព្រះនរោត្តម សីហនុ ជាព្រះប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ។ ព្រះអង្គបានអំពាវនាវតាមវិទ្យុពីទីក្រុងប៉េកាំងមក ឲ្យកូនចៅទាំងអស់ចូលព្រៃម៉ាគីដែលនៅជិតៗដើម្បីឲ្យកូនចៅធ្វើការតស៊ូដណ្តើមយកឯករាជ្យមកវិញ ។



រូបថតអតីតបុគ្គលិក នៅមន្ទីរ ក-១២ ថតនៅដើមឆ្នាំ១៩៧៨ នៅពេលទៅទស្សនាសិល្បៈ ដែលសម្តែងដោយក្រុមសិល្បៈរូម៉ានី នៅសាលមហោស្រពទន្លេបាសាក់ ។ រូបថតរាប់ពីឆ្វេង ៖ មិត្តនារី វី មិត្តនារី អឿន មិត្ត សារិន (ម្ចាស់អត្ថបទ) មិត្ត សាន មិត្ត រី ហៅ រី ឆ្នូក មិត្ត សារុន ហៅ តាសាច់បុក និង មិត្ត សំ បើកឡានឲ្យទូតគុយបា ។

ក្នុងនោះ មានរូបខ្ញុំបាទម្នាក់ដែរ ដែលបានស្ម័គ្រចិត្តចូលបម្រើការងារបដិវត្តន៍នា សម័យនោះ ។ ខ្ញុំបាទឈ្មោះ សរ សារិន កើតនៅភូមិត្រពាំងក្រពើ ឃុំមួងវៀវ ស្រុកត្បូងឃ្មុំ តំបន់២១ ភូមិភាគបូព៌ា (បច្ចុប្បន្នខេត្តត្បូងឃ្មុំ) ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិទី៥ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម (ទូរស័ព្ទលេខ ០១២ ២៣៩ ៥៧២ និង ០៩៧ ៨១៥ ៦៨៥៧) ។

ដោយមានការឈឺចាប់ និងធ្លាប់រងគ្រោះដោយសារយន្តហោះរបស់អាមេរិកបាញ់ និងទម្លាក់គ្រាប់បែកលើសាច់ញាតិ និងខ្លួនខ្ញុំផ្ទាល់ ទើបខ្ញុំចង់រៀបរាប់អំពីវិនាសកម្មជាក់ស្តែងដើម្បីឲ្យកូនចៅជំនាន់ក្រោយបានដឹងអំពីវិនាសសកម្មនេះ ។ នៅឆ្នាំ១៩៧០, ៧១, ៧២, ៧៣ យន្តហោះអាមេរិកបានទម្លាក់គ្រាប់បែកមកលើភូមិករ ផ្ទះសម្បែងរបស់ខ្ញុំមានដូចខាងក្រោម ៖

លើកទី១ នៅចុងឆ្នាំ១៩៧០ យន្តហោះទ្រុងជ្រូកបានបាញ់មកលើភូមិកំពង់ឫស្សី ប៊ឹងកក់ ប៊ឹងកំបោរ រហូតដល់ភូមិស្ពានឈើ នៅតាមដូរមាត់ទន្លេ ។ កាលណោះ ខ្ញុំទៅផ្ទះ ឪពុកមាររបស់ខ្ញុំ ឈ្មោះ អុន ហៅតាទីន ប្រហែលជាក្នុងអំឡុងពេលបុណ្យភ្ជុំ និងទៅលេងជីដូនជីតាផង ។ ពេលនោះយន្តហោះទ្រុងជ្រូកបានបាញ់មកលើទូកធំៗតាមដូរមាត់ទន្លេតាំងពីព្រឹករហូតដល់យប់ ។

លើកទី២ យន្តហោះបានទម្លាក់គ្រាប់នៅក្រោយផ្ទះរបស់ខ្ញុំ ចំនួនប្រមាណជា៨គ្រាប់ នៅប្រកអំពុក ហៅទួលអំពិល មានចម្ងាយ ៥០០ម៉ែត្រពីផ្ទះរបស់ខ្ញុំដែលបន្សល់ទុកនូវរណ្តៅធំៗប៉ុនរណ្តៅ B-៥២ មាត់រណ្តៅប្រមាណ៣០ម៉ែត្រ និងមានជម្រៅទៅក្រោមពី៥ទៅ ៦ម៉ែត្រ ដោយសារក្រុមយៀកកុងបានបាញ់យន្តហោះអាការូរបស់អាមេរិក ។

លើកទី៣ អាមិកស្វាបជ្រីង ល្បឿនលឿនជាងសំឡេងពី ៥០០ម៉ែត្រទៅ១.០០០ម៉ែត្រ បានទម្លាក់គ្រាប់និងបន្សល់ទុកនូវរណ្តៅដែលមានទំហំ៤ម៉ែត្ររាងមូល មានជម្រៅត្រឹមជង្គង់ ។ យន្តហោះដែលមកទម្លាក់គ្រាប់បែកនោះមានចំនួន៦គ្រឿង ដែលក្នុងនោះយន្តហោះឈ្មោះ អាការ៉ូ មាន៣គ្រឿង អាសំគម ហៅអាបង្គួយមួយគ្រឿង និងអាគន្ធាត់ មានចំនួនពីរគ្រឿងនៅចាំការពារអាការ៉ូ ។ ទាហានដែលជិះនៅលើយន្តហោះបានចុះមកផែកនេរខ្ញុំ និងបងប្អូនដែលទៅឃ្វាលគោ-ក្របី ឲ្យស្រាតខោ-អាវ និងស្រាយបង្ខិចដែលខ្ញុំខ្ចប់ត្រកួនដែលបានបេះយកទៅផ្ទះ ។ ការផែកនេរនេះ ប្រហែលជារកកាំភ្លើង ឬក៏រកអង្ករ ព្រោះខ្លាចពួកយើងយកទៅឧបត្ថម្ភឲ្យក្រុមវៀតកុង ។ ប្រហែលដប់ថ្ងៃក្រោយមក យន្តហោះអាការ៉ូ បានបាញ់ត្រូវបងជីដូនមួយរបស់ខ្ញុំស្លាប់ និងចាប់បងប្រុសរបស់ខ្ញុំដាក់យន្តហោះយកទៅបាត់ ដោយសារឃើញគាត់ដឹកអង្ករ និងដឹកអុស ។

លើកទី៤ យន្តហោះទម្លាក់គ្រាប់ណាប៉ាល់ (គ្រាប់ធុងសាំងឬប្រេង) ក្នុងការប្រយុទ្ធ គ្នារវាងយៀកកុង (វៀតណាមខាងជើង) និងពួកធីវគី (វៀតណាមខាងត្បូង) ដោយយកភូមិសាស្ត្រទឹកដីកម្ពុជាធ្វើជាទីលានប្រយុទ្ធ ។ ជាក់ស្តែងនៅក្នុងភូមិរបស់ខ្ញុំ មានការប្រយុទ្ធគ្នា រវាងយៀកកុង និងពួកធីវគី ដោយពេលនោះយៀកកុងបានបាញ់រថក្រោះរបស់ពួកធីវគី ឆេះអស់ចំនួន១៣គ្រឿង និងយន្តហោះមួយគ្រឿង នៅពាសពេញវាលស្រែ ។ ការប្រយុទ្ធគ្នាចាប់ផ្តើមតាំងពីម៉ោងប្រាំបួនព្រឹករហូតដល់ម៉ោង៥-៦ល្ងាច ដោយមានគ្រាប់កាំភ្លើងដូចបាចអង្ករ ។ លុះស្អែកឡើង យន្ត



ស សារិន ថតនៅវិមានមិត្តភាពកម្ពុជា-វៀតណាម នៅក្នុងស្រុកស្នួល ខេត្តក្រចេះ

ហោះបានមកទម្លាក់គ្រាប់ណាប៉ាល់ឆេះផ្ទះនៅក្នុងភូមិរបស់ខ្ញុំគ្មានសល់មួយឡើយ ។

លើកទី៥ យន្តហោះទម្លាក់គ្រាប់ ព-៥២ លាន់សន្ទឹកដូចដីស្រែករពើទ្បើងញ័ររញ្ជួយដី ។ គ្រាប់ B-៥២ ទម្លាក់នៅចម្ការកៅស៊ូខាងកើតថ្នល់ទទឹង (បច្ចុប្បន្នសាលាស្រុក ត្បូងឃ្មុំ) នៅពេលដែលខ្ញុំរកអុស និងប្រូតស្មៅ ពេលនោះយន្តហោះទម្លាក់គ្រាប់ B-៥២ ប្រហែលជាម៉ោង៩ព្រឹក ។ ក្រោយពីបានឮសន្ទឹកគ្រាប់ផ្ទុះ ខ្ញុំក៏បានលោតចូលសម្ងំពួនក្នុងរណ្ដៅនៅក្បែរផ្លូវដែលជាលេណដ្ឋានចាស់ៗរបស់យៀកកុង ។ ពេលនោះ មានគ្រាប់បែក មួយបានធ្លាក់នៅក្បែររណ្ដៅដែលខ្ញុំពួន តែសំណាងល្អ គ្រាប់នោះមិនផ្ទុះទើបខ្ញុំបានរួចជីវិត តែវាសនាអាក្រក់សម្រាប់បងជីទូតមួយរបស់ខ្ញុំរួមជាមួយអ្នកភូមិមួយចំនួនបានស្លាប់ក្នុងពេលនោះ ហើយខ្ញុំសូមផ្ដាំផ្ញើទៅអង្គការស៊ីម៉ាកតាមរយៈព័ត៌មាននេះ សូមមកយកគ្រាប់ B-៥២ នេះផង ព្រោះសព្វថ្ងៃនៅទេគ្រាប់បែកនេះ គឺនៅខាងត្បូងផ្លូវជាតិលេខ៧ ជ្រុងទិសនិរតី សាលាស្រុកត្បូងឃ្មុំបច្ចុប្បន្ន ។

លើកទី៦ មានយន្តហោះមកទម្លាក់គ្រាប់ B-៥២ នៅភូមិត្រពាំងក្រពើនៅវេលាម៉ោង ១២យប់ បណ្ដាលឲ្យម្ដាយ និងបងរបស់ខ្ញុំ ព្រមទាំងប្រជាជនក្នុងភូមិប្រមាណ១០០នាក់ត្រូវស្លាប់ ។ ដុំដីជាច្រើនបានធ្លាក់នៅជុំវិញទីកន្លែងដែលឪពុកខ្ញុំ និងខ្ញុំក្រាបពួន ។ ដុំដីដែលហោះប៉ើងទៅលើដោយសារកម្លាំងគ្រាប់ផ្ទុះបានធ្លាក់មកបណ្ដាលឲ្យបាក់ដំបូល និងរនាបផ្ទះ ហើយនៅជុំវិញផ្ទះខ្ញុំ (គ្រាប់ធ្លាក់ត្រូវចំនួនប្រាំមួយគ្រាប់) គ្រាប់ដែលបានទម្លាក់នៅពេលនោះជាប្រភេទគ្រាប់អម្បែងធ្លាក់ប្រហែលជា៣០ម៉ែត្រ ឯ៥គ្រាប់ផ្សេងទៀតជាប្រភេទគ្រាប់បូម ធ្លាក់ប្រហែលជា៤០ទៅ៥០ម៉ែត្រ និងបន្សល់ទុករណ្ដៅប្រហែលជា៤០ម៉ែត្រ ។ សូមបញ្ជាក់ថា យន្តហោះមកទម្លាក់គ្រាប់ B-៥២ ម្ដងៗមានចំនួន៣គ្រឿង ហើយក្នុងយន្តហោះមួយគ្រឿងទម្លាក់គ្រាប់បូមបួន មានន័យថា ឥទ្ធិពលរបស់គ្រាប់បូមធ្វើឲ្យកើតជារណ្ដៅជ្រៅ និងមាត់រណ្ដៅធំប្រហែលជា៣០ម៉ែត្រ បើធ្លាក់ពីរគ្រាប់ជាប់គ្នាមានប្រវែង៦០ម៉ែត្រ និងមានគ្រាប់អម្បែងមួយគ្រាប់ ។ គ្រាប់អម្បែងនេះ ធ្វើឲ្យកើតមានជារណ្ដៅតូចទេ មាត់រណ្ដៅប្រហែល៧ម៉ែត្រ ជម្រៅប្រហែល២ម៉ែត្រ ។ យន្តហោះទាំងបីគ្រឿងនេះបូកចូលគ្នាបានទម្លាក់គ្រាប់បែកចំនួន១៥៦គ្រាប់ ។ ខ្ញុំមានការឈឺចាប់ខ្លាំងណាស់ចំពោះអាមេរិកដែលទម្លាក់គ្រាប់បែកមកលើភូមិឋានរបស់ខ្ញុំ ហេតុនេះហើយបានជាខ្ញុំស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ ។

អាមេរិកបានទម្លាក់គ្រាប់បែកធ្វើឲ្យស្លាប់ប្រជាជនខ្មែរអស់រាប់សែននាក់ ឆេះផ្ទះសម្បែង វត្តអារាម និងភោគផលផ្សេងៗដែលប្រជាជនខិតខំផលិតបាន ។ ជាក់ស្ដែងនៅស្រុកត្បូងឃ្មុំ ក្នុងភូមិត្រពាំងក្រពើ ផ្សារស្នួល វិហារហ្លួង តំណាក់ចារ ចាន់ទូង នគរជាខ្វារ ប្រធាតុ កណ្ដុរជ្រុំ ស៊ឹង ក្រែក ជីមាន់ និងឡើងទៅស្រុកមេមត់ ភោគផល និងផ្ទះសម្បែង របស់ប្រជាជនដែលបានខូចខាត បើគិតជាប្រាក់គឺមានតម្លៃរាប់រយលានដុល្លារ ។

## ដំណើរចូលបដិវត្តន៍

ខ្ញុំបានចូលបដិវត្តន៍ បម្រើការងារជាអ្នកឃោសនាខាងរណសិរ្ស តាមរយៈដើរសម្ដែងសិល្បៈឲ្យប្រជាជនបានទស្សនា ហើយឆ្លៀតក្នុងឱកាសនោះយើងបានធ្វើការឃោសនាជាបណ្ដើរៗ ។ ពេលនោះ ខ្ញុំបានឃោសនាថា រណសិរ្សរួបរួមជាតិកម្ពុជា សាសនាព្រះមហាក្សត្រ រាជវង្សានុវង្ស ព្រះសង្ឃ ប្រជាជន យុវជន យុវនារី ដោយមិនប្រកាន់ពូជសាសន៍ឬពណ៌សម្បុរឡើយ ដើម្បីឲ្យចូលបម្រើក្នុងជួររណសិរ្ស ។ កាលណោះមាន ចម្រៀងមួយចំនួន ពេលដែលបានស្ដាប់ហើយ ធ្វើឲ្យយុវជនស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ព ដូចជាបទចម្រៀងត្រុឌ មានចំណងជើងថា «បើយុវជនណាមិនស្ម័គ្រចិត្តចូលបម្រើនៅសមរភូមិមុខ និងមិនចុះជាប់ជនបទកែប្រែជីវភាពប្រជាជនទេ កុំមកប៉ងប្រាថ្នាលើ យុវនារីយើងខ្ញុំ» ។ មានបទចម្រៀងខ្លះទៀត ជាចម្រៀងរបស់ជនជាតិចារ៉ាយដែលមានចំណងជើងថា «យើងខ្ញុំយុវនារីគាំទ្រយកឥតរួញរា ចំពោះយុទ្ធជនពិការនៅសមរភូមិមុខ» ។ បទចម្រៀងខ្លះទៀតមានដូចជា «ពុកយើងទៅធ្វើកងឈ្លប» «ចិន្ទូងភូមិជំរំជ័យ» និងបទចម្រៀងជាច្រើនទៀតដែលធ្វើឲ្យយុវជនស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពយ៉ាងច្រើនកុះករ ។ អ្នកដែលមានប្រវត្តិរូបមិនល្អ មិនអនុញ្ញាតឲ្យចូលបម្រើក្នុងជួរកងទ័ពទេ ។ អ្នកដែលមានប្រវត្តិរូបមិនល្អសំដៅលើ អនិកជនចិន យួន (បើយួនត្រូវបោសសម្អាតតែម្ដង) និងអ្នកមានបងប្អូននៅតំបន់ក្រោមការដឹកនាំរបស់លោក លន់ នល់ជាដើម ។

លុះដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ សង្រ្គាមអាកាស អាមេរិក ត្រូវបានបញ្ចប់នៅក្នុងប្រទេសកម្ពុជា ពេលនោះខ្ញុំក៏បាន ចូលបដិវត្តន៍ពេញសិទ្ធិ ។ អង្គការបានរើសយុវជនស្ម័គ្រចិត្តនៅក្នុង ឃុំមូងរៀវបានចំនួនប្រហែល១៣០នាក់ ដើម្បីឲ្យទៅរៀនក្បួន យុទ្ធសាស្រ្ត និងទៅប្រយុទ្ធនៅសមរភូមិមុខ ។ បន្ទាប់ពីរៀនបាន រយៈពេលពីរខែមក គណៈមេបញ្ជាការយោធាស្រុកត្បូងឃ្មុំឈ្មោះ ជុំ ហ៊ិល និងគណៈបញ្ជាការយោធាតំបន់២១ឈ្មោះ ទន់ គ្រី បានមកទទួលកម្លាំងយកទៅសមរភូមិមុខ ។ ពេលនោះ ទន់ គ្រី និង ជុំ ហ៊ិល មិនឲ្យខ្ញុំទៅ សមរភូមិទេ តែបានចាត់តាំងឲ្យខ្ញុំដើរប្រមូល ស្បៀងតាមមូលដ្ឋាន ។ កាលណោះ ការជ្រើសរើសយុទ្ធជនទៅ សមរភូមិបានជាង១២០នាក់ឲ្យចូលទ័ពស្រុក ក្រោយមកក៏បាន កាត់ទៅខាងទ័ពតំបន់២១ ។ ខ្ញុំបានប្រមូលស្បៀងតាមមូលដ្ឋាន ក្នុងឃុំមូងរៀវ ដែលមាន៨ភូមិ មានជាបាយកញ្ចប់ និងអង្ករតស៊ូ (ហៅថាអង្ករក្តាប់) ដើម្បីចិញ្ចឹមកងទ័ពនៅសមរភូមិ ។ តាមគ្រួសារ នីមួយៗ ពេលដាំបាយ ត្រូវដកអង្ករមួយក្តាប់ចេញ ទុកសម្រាប់ ឧបត្ថម្ភទៅសមរភូមិ ។ ក្នុងមួយថ្ងៃៗខ្ញុំបានដើរប្រមូលអង្ករបាន ៤បាវ មានទម្ងន់ប្រហែល៤០០គីឡូក្រាម ។ ក្រៅពីនេះ មាន អំបិល ប្រហុក ផ្អក ពងមាន់ ពងទា មាន់ ទា ទៅតាមតម្រូវការរបស់ សមរភូមិ ។ ស្បៀងដែលខ្ញុំរៃអង្គាសបាននេះ គឺសម្រាប់យកទៅ ឧបត្ថម្ភយោធាតំបន់២១ និងយោធាស្រុកត្បូងឃ្មុំដែលប្រចាំការ នៅសមរភូមិត្រើយខាងកើតទន្លេកំពង់ចាម មានសមរភូមិវត្តឃ្លង សមរភូមិទន្លេបិទ សមរភូមិព្រែកជីក សមរភូមិប៉មរកាធំ និងសម រភូមិជីរោទ៍ ។ លុះដល់ក្រោយថ្ងៃ១៧ មេសា កងទ័ពទាំងអស់ត្រូវ ដកទៅប្រចាំការនៅតាមព្រំដែនកម្ពុជា-វៀតណាម គឺនៅស្រុក មេមត់ និងស្រុកត្រមូងវិញម្តង ។

ចំណែកឯស្បៀងរបស់ខ្ញុំត្រូវឧបត្ថម្ភឲ្យខាងកងទ័ព លន់ នល់ ម្តងដែលចុះចូលនៅតំបន់រំដោះ ហើយថ្នាក់លើបានយកទៅឲ្យរស់ នៅក្នុងវត្តមង់ ដែលនៅស្ថិតក្នុងឃុំមូងរៀវ ។ ក្រោយមក ថ្នាក់ លើចាត់តាំងខ្ញុំ និងមិត្តដទៃទៀត ប្រហែលជា២០នាក់ ហើយបាន មកជួបជុំគ្នានៅសួង រួមជាមួយកម្លាំងផ្សេងៗទៀត សរុបទាំង អស់បានប្រហែលជាង១០០នាក់ ។ យើងក៏ធ្វើដំណើរមកទីកន្លែង ប្រមូលផ្តុំរបស់គណៈតំបន់២១ នៅខាងកើតចម្ការម៉ៃសាក់ ឃុំ ស្រឡប់ ស្រុកត្បូងឃ្មុំ ជាអាទិ៍មានយុវជន និងយុទ្ធជនមកពីស្រុក ត្បូងឃ្មុំ ស្រុកពាម ជីលាំង ស្រុកក្រូចឆ្មារ ស្រុកឆ្លូង ស្រុកតំបែរ ស្រុកទឹកជ្រៅ ស្រុកមេមត់ ស្រុកត្រមូង នៅក្នុងតំបន់២១នេះទៀត បានចំនួន១០០០នាក់ តាមការប្រកាសឲ្យដឹងរបស់គណៈមេបញ្ជា ការ ។ យើងទាំងអស់គ្នាបានធ្វើដំណើរដោយថ្មើរជើងឡើងតាមផ្លូវ ជាតិលេខ៧ មកផ្លូវទទឹង ហើយក៏បានធ្វើដំណើរតាមផ្លូវជាតិ ឆ្ពោះទៅក្រុងព្រៃវែង ។ លុះទៅដល់វត្តស្វាយរមៀត ក្នុងឃុំក្បឿង រាយ ស្រុកស៊ីធរកណ្តាល ដែលជាទីស្នាក់ការប្រមូលផ្តុំរបស់កងទ័ព ភូមិភាគ២០៣ ហៅភូមិភាគបូព៌ា បានប្រមូលកម្លាំងតាមតំបន់មាន តំបន់២០ តំបន់២១ តំបន់២២ តំបន់២៣ និងតំបន់២៤ ។ យើង ទាំងអស់គ្នាបានរៀននៅទីនោះប្រហែលជាកន្លះខែ ។ សាលានេះ ហៅថាសាលា "ស-២០០" របស់កងទ័ពភូមិភាគបូព៌ា ។ សមមិត្ត ប្រធានសេនាធិការយោធាភូមិភាគ២០៣ ឈ្មោះ កែវ សំណាង ហៅ ម៉ុន បានប្រកាសថា កងទ័ពយើងមានគ្នាចំនួន៥០០០នាក់ ថ្នាក់លើមានការចាំបាច់ និងបន្ទាន់ត្រូវការមិត្តទាំងអស់គ្នាដើម្បីឲ្យ បម្រើការងារ ។ កែវ សំណាង ក៏បានមានមតិផ្តាំផ្ញើថា សូមសមមិត្ត ទាំងអស់ គ្នាបន្តវីរភាពក្លាហានឲ្យដូចបងៗជំនាន់មុន កងទ័ពភូមិភាគ បូព៌ាយើងជាកងទ័ពដ៏អង់អាចក្លាហាន បានវាយរំដោះទីក្រុងអ្នក លឿងដែលនៅក្នុងសម័យសង្រ្គាមកន្លងមកហៅថា ព្រៃនគរទី២ និងសមរភូមិជាច្រើនទៀត នៅជុំវិញភ្នំពេញ ប្រហែលជា៧០ភាគ រយដែលកង ទ័ពភូមិភាគបូព៌ាយើង វាយបានជ័យជម្នះទាំងស្រុង នាថ្ងៃ១៧ មេសា ១៩៧៥ ។ ដូច្នេះសមមិត្តទាំងអស់គ្នាត្រូវ គោរពវិន័យ និងសីលធម៌ជាកងទ័ពបដិវត្តន៍ កុំឲ្យខូចពូជកងទ័ព បូព៌ា ។ នេះជាអត្ថន័យមួយឃ្លា ដែលខ្ញុំចងចាំជាងគេកាលពីសម័យ នោះ ។ ក្រោយមកទៀត យើងទាំងអស់គ្នាក៏បានឡើងមកទីក្រុង ព្រៃវែង យើងក៏បានធ្វើដំណើរទាំងយប់មកអ្នកលឿង ហើយបន្ត ឆ្ពោះមកទីក្រុងភ្នំពេញ ដោយមិនបានដឹងពីគោលដៅថាត្រូវទៅ ណានោះទេ គ្រាន់តែដឹងថាមកតាមការចាត់តាំងរបស់ថ្នាក់លើ ។ ពេលមកដល់ច្បារអំពៅបានសម្រាក នៅទីនោះពីរយប់ ។

**(តទៅលេខក្រោយ)**

**ស សារិន**

# ព្រលឹងមាសម្ដាយ

***(តពីលេខមុន)***


អ៊ុង វណ្ណា ម្ចាស់អត្ថបទ

*គ្រាប់ S១១១ ទម្លាក់នៅក្រៅភូមិទាំងអស់ គ្រោះថ្នាក់ផ្ទាល់ ដោយការទម្លាក់គ្រាប់បែកនេះ បានធ្លាក់ទៅលើអ្នកកំពុងប្រកបរបរនេសាទ អ្នកនៅធ្វើចម្ការឯវាល និងសត្វពាហណៈខ្លះ ប៉ុន្ដែ ជាទូទៅមនុស្សភាគច្រើនមិនហ៊ានចេញទៅវាលទេក្នុងអំឡុងពេលនោះ ម្នាក់ៗចាំតែមាត់រូង ឬលេណដ្ឋានដូចសត្វកណ្ដុរ ។ ប៉ុន្ដែគ្រោះថ្នាក់មិនផ្ទាល់កើតឡើងជាឥទ្ធិពលវែងឆ្ងាយទៅលើភូមិស្រុកជិតកន្លែងទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ គឺជំងឺរាគមួលដែលបានកើតឡើងក្នុងអំឡុងមួយអាទិត្យក្រោយការទម្លាក់នោះ និងបានផ្ដាច់ផ្ដិលជីវិតមនុស្សយ៉ាងសាហាវ ។ អ៊ំ ស្រី និងម្ដាយមីងខាងអ្នកម្ដាយខ្ញុំនៅភូមិពាមស្ដីនេះ បានលាចាកលោកទាំងពីរនាក់ ដោយជំងឺរាកមួល គាត់ទាំងពីរបន្សល់ទុកនូវកូនកំព្រាម្ដាយ១២នាក់ ។*

*ព្រឹត្តិការណ៍ទាំងនេះ សឹងតែក្លាយជារឿងសាមញ្ញទៅវិញហើយ សម្រាប់ជីវិតក្នុងព្យុះសង្គ្រាមរបស់ប្រជាកសិករខ្មែរម្នាក់ៗក្លាយទៅជាអ្នកថ្មីកសង្គ្រាម និងស៊ាំនឹងការឈឺចាប់ទៅហើយ ។ ទ្រឹស្ដីជីវិតដ៏ប្រសើររបស់យើងនៅពេលនោះ គឺរស់នៅត្រូវចេះកាត់ចិត្ត បើមិនចេះកាត់ចិត្ត គឺរស់មិនកើត និងប្រយោគថា រស់ពិបាកជាងស្លាប់ អ្នកស្លាប់ជាអ្នកឆាប់ផុតទុក្ខ យើងត្រូវទទួលស្គាល់ស្ថានភាពនេះ ។*

## សង្គ្រាមណាប៉ាល់ ឬ គ្រាប់ធុងសាំង

*យើងត្រឡប់ក្រោយបន្ដិចទៅរដូវវស្សាឆ្នាំ១៩៧១ មកដល់ការទម្លាក់គ្រាប់បែក និងស្នូរកាំភ្លើងហាក់ស្ងប់ស្ងាត់ទៅវិញ ទ័ពរដ្ឋាភិបាលលែងហ៊ានធ្វើដំណើរដើរតាមផ្លូវជាតិ ទ័ពរំដោះបានកាន់កាប់ទឹកដីភាគច្រើនបំផុតនៃភូមិសាស្ដ្រក្នុងខេត្តព្រៃវែង ទីរួមខេត្តព្រៃវែង សល់តែប្រឡង់ដូចស្មាបានទូល កសិករ មានសន្ដិភាពបន្ដិចយើងអាចចាប់ផ្ដើមកសិកម្មឡើងវិញខ្លះ ដើម្បីក្រពះ ។*

*ចលនារណសិរ្សសេរីការជាតិ បានផ្ដើមចេញពីព្រំដែនវៀតណាម-ខ្មែរមក សាយភាយគ្រប់ភូមិឃុំ ។ លោកអាចារ្យ ព្រឿង អតីតចៅអធិការវត្តពោធិ៍លាស់ ក្នុងខេត្តព្រៃវែង គាត់មានអាយុប្រមាណ៨៥ឆ្នាំ មាឌដំបង មានថ្ពាសទូលាយ ភ្នែកធំជ្រៅបង្ហាញចិញ្ចើមធំក្រាស់ រង្គះមាត់ទូលាយ ស័ក្ដិសមជាវាគ្មិនដ៏ពូកែ ។ ឧបាសក ឧបាសិកា ជាច្រើនបានដំណាលតគ្នាអំពីកិត្ដិនាមនៃអតីតព្រះចៅអធិការដ៏ល្បីល្បាញរូបនេះ ព្រោះធ្លាប់ជាប់ចិត្តនឹងបទទេសនាដ៏ពិរោះក្បោះក្បាយគ្មានប្រៀបនោះ ។ លោកអាចារ្យ ព្រឿង ក្នុងឋានៈជាចៅហ្វាយស្រុកពាមរក៍របស់ចលនារណសិរ្សសេរីការជាតិ បានដឹកនាំក្រុមសមាជិក សមាជិកា រណសិរ្សនយោបាយស្រុកពាមរក៍ ត្រាច់រង្កាត់ពីភូមិមួយទៅភូមិមួយ ដើម្បីចងក្រងបណ្ដាញរណសិរ្សគ្រាប់ភូមិឃុំ ចំណុះឲ្យស្រុករបស់គាត់ ។ នេះជាឈ្មោះយន្ដការគ្រប់គ្រងរដ្ឋបាលទូទាំងប្រទេស ដ៏មានបណ្ដាញរាយល្អិតដូចក្រឡាសំណាញ់របស់ចលនាបដិវត្តន៍ គេបានចងក្រងជារណសិរ្សមជ្ឈិម ខេត្ត ស្រុក ឃុំ ភូមិ និងក្រុមរបនាសម្ព័ន្ធថ្នាក់ទាបបំផុតដែលមានមនុស្សម្នាក់កាន់ក្ដាប់មនុស្ស១០នាក់ ។ អ្នករស់ក្នុងតំបន់រំដោះ គ្មាន នរណាម្នាក់នៅក្រៅសំណាញ់នេះឡើយ ហើយអ្នកដែលគេចាត់ទុកថា ជាខ្មាំងចក្រពត្តិ មិនអាចជ្រៀតចូលបានឡើយ ព្រោះខ្សែបណ្ដាញនេះ គឺជាភ្នែកម្ចាស់របស់បដិវត្តន៍នៅទីនេះ ។*

*ថ្ងៃមួយ ពេលដែលព្រះអាទិត្យរលត់អស់រស្មីទៅភ្លាម ស្រាប់តែស្នូរសម្រិបជើងសេះ កុបៗ បានមកដល់ ។ ប្រធានអនុប្រធានភូមិស្ដៅកោង និងលោកគ្រូពេទ្យ ឈន បានឆ្មាត់ឆ្វែងចែកផ្លូវគ្នាដើរប្រមូលយកសិស្សពេទ្យដែលស្នាក់នៅតាមបណ្ដាផ្ទះប្រជាជនឲ្យមក ជួបជុំគ្នាភ្លាម ។ អង្គប្រជុំបានចាប់ផ្ដើមយ៉ាងបន្ទាន់៖*

*លោកអាចារ្យ ព្រឿង ៖ សោកស្ដាយណាស់ ដោយយុវជន*

យុវនារី យើងកំពុងក្រេបជញ្ជក់នូវវិជ្ជាពេទ្យមិនទាន់បានប៉ុន្មានផង ថ្ងៃនេះសភាពការណ៍បដិវត្តន៍ តម្រូវឲ្យយើង រំសាយវគ្គសិក្សានេះសិន តើមិត្តបានដឹងទេថា យុទ្ធសាស្ត្រសង្គ្រាមរបស់ចក្រពត្តិបានដូរផ្លាស់ទៅដល់ណាហើយ? រដូវវស្សាដែលមានទឹកជំនន់ធំធេងនេះ មិនអាចបើកការវាយប្រហារ បំផ្លិចបំផ្លាញប្រជាជន តាមផ្លូវគោកបាន វាឈានដល់គ្រាប់ណាប៉ាល់ ជាប្រភេទគ្រាប់បែកសាំង ។ ព្រឹកមិញ វាទម្លាក់នៅភូមិពាមស្តី ពុកម៉ែប្រជាជនស្លូតត្រង់របស់យើងរងគ្រោះដំណំណាស់ ។ គេហដ្ឋានទាំងអស់ជាង២០០ខ្នង បានត្រូវឆេះរលាយជាផ្សែង នៅសល់តែសសរបេតុង ត្រឹមៗទឹក និងទីទួលវត្តតែប៉ុណ្ណោះ ប្រជាជនបានអុំទូករត់ឆ្លងមកភូមិស្ពោ និងពន្លៃដីគោក ប៉ុន្តែអភ័ព្វប្រជាជន១៨នាក់ត្រូវស្លាប់ និង៥៦នាក់ទៀត ត្រូវគ្រាប់ភ្លើងសាំងអណ្តែតដេញតាមឆេះ ទាំងទូកទៀតផង ។ អ្នកខ្លះឆេះខ្នងប៉ុនៗបាតដៃ ខ្លះឆេះរលួយ របេះពេញទាំងខ្លួន ក្នុងពេលដែលខ្នងកំពុងឆេះក្តៅរោលរាល ប្រជាជនខ្លះខំលោតទៅក្នុងទឹកស្មានថាអាចរំលត់ភ្លើងនោះបាន តែផ្ទុយទៅវិញវាមានអំណាចអាចឆេះក្នុងទឹក ក៏ដូចជាលើទឹកដែរ ។

លោកគ្រូពេទ្យ ឈុន ៖ មូលហេតុនេះហើយ ដែលអង្គការលើកអង្គប្រជុំបន្ទាន់នៅថ្ងៃនេះឡើង អង្គការសុំផ្អាកវគ្គគ្រូពេទ្យបណ្តោះអាសន្នសិន សូមអញ្ជើញសមមិត្ត សមមិត្តនារី ពេទ្យបដិវត្តន៍យើងវិលទៅកាន់ភូមិដ្ឋានរៀងៗខ្លួនវិញ បំពេញភារកិច្ចបម្រើប្រជាជនឲ្យបានសមស្របតាមសីលធម៌បដិវត្តន៍ ជាពិសេសសមមិត្ត សមមិត្តនារីដែលមកពីភូមិស្ពោ និង ភូមិពន្លៃនឹងមានភារកិច្ចមមាញឹក ដោយពុកម៉ែប្រជាជន យុវជន យុវនារី ក៏ដូចជាកុមាររងគ្រោះរបស់យើងមកពីភូមិពាមស្តី កំពុងស្នាក់នៅក្នុងភូមិរបស់បណ្តាមិត្ត ពួកគាត់កំពុងរង់ចាំជំនួយបច្ចេកទេស និងទឹកចិត្តមនុស្សធម៌ដ៏ប្រពៃរបស់សមមិត្តទាំងអស់ ។

យើងត្រងត្រាប់ស្តាប់ព្រឹត្តិការណ៍នោះទាំងរន្ធត់ញាប់ញ័រ និងពោរពេញដោយការប្តេជ្ញាជួយព្យាបាលប្រជាជនយើង ។ លោកគ្រូពេទ្យវ័យក្មេងទាំងអស់ ស្រូតរូតរះលើកសម្ពាយសាក់កាដូឡើងខ្នង ដោយទឹកចិត្តរំភើបញាប់ញ័រ វិលមកភូមិដ្ឋានវិញដោយដំណើរថ្មើរជើងយ៉ាងស្វាហាប់ ។ ពេលនោះ យុវមិត្តពេទ្យភូមិស្ពោ ពន្លៃ ព្រៃកណ្តៀងយើង រួមដំណើរគ្នាដោយផ្លូវតែមួយចេញពីស្ពោកោងមក ហើយមកបែកគ្នាត្រឹមភូមិព្រៃកណ្តៀង ។

យប់នោះភ្លៀងរលឹមស្រិចៗ ខ្យល់ខែដំឡើងបក់បោកវូៗ គួចចុងរុក្ខាតាមបណ្តោយដងផ្លូវឲ្យពត់ពេនរឹតចុះ រឹតឡើងគួរឲ្យព្រឺខ្លាច អាកាសធាតុត្រជាក់ស្រិប កំណាត់ផ្លូវលំខ្លះត្រូវគ្របដណ្តប់ដោយទឹកជំនន់ត្រឹមជង្គង់ត្រឹមចង្កេះ ឬរហូតដល់ដើមទ្រូង ធ្វើឲ្យយើងក្តៅខណ្ឌៗស្រួលនៅពេលកំពុងលុយទឹក តែរងាររញ្ជាក់រណ្តំថ្គាមនៅពេលឡើងផុតពីទឹក ហើយដើរលើដីគោក ។

ក្នុងស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ចំពោះចិត្តសាស្ត្រអង្គការ ដែលបានជ្រើសរើស យុវជនម្នាក់ យុវនារីម្នាក់ ក្នុងភូមិនីមួយៗឲ្យរៀនពេទ្យ ហើយក្នុងពេលបិទវគ្គ អង្គការបង្កើតកម្មវិធីឲ្យយើងធ្វើដំណើរពេលយប់យ៉ាងនេះ ដើម្បីអ្វីទៅ? យុវមិត្តភូមិព្រៃកណ្តៀងបានចោទសំណួរនេះមកចំឈ្មោះខ្ញុំ និងក៏មានបំណងសួរទៅកាន់យុវមិត្ត៤រូប ទៀតដែរ ។

ខ្ញុំ ៖ ខ្ញុំយល់ ខ្ញុំតប! បើយើងខ្វះស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ យើងអាចជួបនូវគ្រោះកាចនោះប្រហែលជាបទពិសោធន៍របស់អង្គការចង់ស្ទង់មើលថា តើក្រោយពីបំពាក់សីលធម៌១២ប្រការរួចហើយ យុវជន យុវនារី អាចប្រកាន់ខ្ជាប់នូវសីលធម៌នោះបានឬទេ?

មិត្តនារីព្រៃកណ្តៀង ៖ សូម្បីតែអង្ករមួយកំប៉ុង ម្ជុលមួយដើម ចេសមួយសរសៃ ឬម្ទេសមួយផ្លែ ក៏មិនត្រូវប៉ះពាល់ទ្រព្យសម្បត្តិប្រជាជនឡើយ ។

យុវមិត្តភូមិពន្លៃ ៖ ហាមស៊ីជក់ ស៊ីផឹក និយាយស្តី ឬប្រព្រឹត្តអ្វីដែលមានចរិតពាលាអា វ៉ាសែ មិនបដិវត្តន៍ ។ តើមានន័យយ៉ាងដូចម្តេច សូមមិត្តទាំងអស់ជួយបកស្រាយមើល?

យុវនារីភូមិពន្លៃបានតឿនរម្លឹកទាំងអស់គ្នា ៖ មេឃខែរនោចកាន់តែងងឹត ធាតុអាកាសខែនេះ ពេលយប់កាន់តែជ្រៅកាន់តែរងារ យើងគួរតែខំស្រូតដំណើរទៅ ។

មេឃងងឹតឥតព្រះចន្ទទេ អាកាសធាតុត្រជាក់ខ្លាំង ពពកប្រផេះ អណ្តែតពាសពេញមេឃា តំណក់គ្រាប់ភ្លៀងរលឹមស្រិចៗមកលើរាងកាយថ្មើរជើងយើង តែដួងចិត្តយើងហាក់មានអំណាចកក់ក្តៅដោយភ្លើងកំហឹងចំពោះចក្រពត្តិ ឆាបឆួលក្នុងដួងចិត្ត កាលណានឹកឃើញដល់ប្រសាសន៍សមមិត្តពូ ព្រឿង រៀបរាប់ពីព្រឹត្តិ

ការណ៍ណាប៉ាល់ម្តងៗ យុវមិត្តយើង ហាក់មានអារម្មណ៍ក្លៃថែង ចាំងដោយអំណាចបដិវត្តន៍ ម្នាក់ៗហាក់មានថាមពលរឹងប៉ឹងក្នុងខ្លួនឥតគណនា យើងបោះជំហានទៅមុខប្រឹបៗយ៉ាងស្វាហាប់ យើងទៅមុខៗលុះត្រាមេឃរលំ ភ្នំរលាយ មហាសមុទ្ររីងស្ងួតក៏ឆន្ទៈយើងមិនអាចរីងស្ងួតនូវថាមពលបដិវត្តន៍ដ៏ក្លៀវក្លានេះបានឡើយ ។ ឱកាសនេះ ជាយុគមាស យុគប្រាក់ ដែលយើងក្នុងនាមជាយុវជន-យុវនារី គ្រប់រូបមានភារកិច្ចប្រើដំបង គល់ឫស្សី ដើម្បីដេញកម្ចាត់ចក្រពត្តិដែលមានអាវុធយុទ្ធភណ្ឌទំនើបប្រកបដោយកម្លាំងវិទ្យាសាស្ត្រតែអសីលធម៌នេះ ឲ្យវាវិនាសសាបសូន្យពី ទឹកដីអង្គរនៃយើងទៅ ។ យើងមានភារកិច្ចត្រូវបន្ត និងស្តារឋាននូវនាមដ៏មានន័យនៃពូជខ្មែរអង្គរ ក្នុងតួនាទីជាមនុស្សសំខាន់របស់ជាតិ ជាតិត្រូវការយើង យើងធ្វើអ្វីៗដែលជាតិត្រូវការ ។ ឱ! នេះហើយជាឆន្ទៈពិតរបស់ប្រជាកសិករខ្មែរ យុវកសិករខ្មែរជំនាន់នោះ ម្នាក់ៗគិតថា ជីវិតខ្លួននឹងមានន័យបរិបូណ៌ មានសារប្រយោជន៍ចាំបាច់សម្រាប់ជាតិ ។

## ជីវិតស្មាមួយអំម្រែកពីរ

### វីរភាពឥតន័យ

ចុះទឹកក្រពើ ឡើងលើខ្លា ។ យប់រស់នៅក្នុងហ្វូងក្អែកខ្មៅ ថ្ងៃក្រាបលូនក្រោមពស់ រាជសីហ៍ លលកសអើយ បោះពួយត្រដែតរកស៊ីតាមហេតុ ទម្រាំស្រុករាប ។ យប់រំដោះ ចូលថ្ងៃទាហានរដ្ឋាភិបាល នេះជាស្ថានភាពនៅឆ្នាំ១៩៧២ ។ ផ្លូវជាតិលេខ១១ គឺជាសមរភូមិក្តៅ ដែលទឹកដោតទៅដោយភ្លៀងឈាម គ្រហឹមគំរាមដោយស្នូរអាវុធធុនតូច ធុនធំគ្មានស្រាកស្រាន្តពាឆ្នាំ ហើយរស់នៅក្នុងភ្នក់ភ្លើងសង្គ្រាម ក្រាបលូនរត់គេចគ្រាប់រំសេវគ្មានឈប់ឈរ ។ កាលព្ទស្នូរអាតាក់លើកទី១ អ្នកស្រុកតាមដងផ្លូវជាតិលេខ១១នេះ ភ័យរាកអាចម៍ រាកនោម ស្ទើរលោះព្រលឹង ឥឡូវពេលព្ទស្នូរកាំភ្លើង គេនិយាយថា «នោះ ប៉ុកគ្រិមៗ ដូចស្នូរឃើកេទៀតហើយ ឬថា យើស នៅចុងប៉មព្រៃវែង គេឃុំរោងលេងយីកេទៀតហើយ» ។ អ្នកស្រុកឥឡូវក្លាយជាអ្នកថ្មីកសង្គ្រាម គេស៊ាំនឹងស្នូរអាវុធ គេស្គាល់ស្នូរបាញ់ចេញពីទីជិត ទីឆ្ងាយ ស្នូរបម្រុងធ្លាក់ជិត ឬឆ្ងាយ ដូច្នេះ គេអាចប្រកបរបរស្រែចម្ការ ឬនេសាទត្រី កាត់គ្រាប់រំសេវបាន ។ កាលណាព្ទស្នូរកាំភ្លើងក្តុងៗ រ៉ាកៗ រ៉ើកៗ ធ្ងន់គេក៏ក្រាបចុះ កាលណាព្ទសូរភ្ជុចរើរស្រាលគេបន្តការងាររធម្មតា ។ ម្យ៉ាងទៀត ការវាយប្រហារធ្ងន់ បានថយចុះយ៉ាងខ្លាំង ដោយខាងទាហានរដ្ឋាភិបាល លន់ នល់ ភាគច្រើនបានទម្លាក់ចោលនូវស្មារតីប្រយុទ្ធ គេធ្វើទាហានយកតែប្រាក់ខែចិញ្ចឹមជីវិតតែប៉ុណ្ណោះ ។

លោកឪពុកខ្ញុំជាអតីតចៅអធិការវត្តភូមិស្តៅ (ភូមិស្តៅមាន២ គឺស្តៅ-ពន្លៃ នៅក្នុងឃុំព្រៃកណ្តៀង ស្រុកពាមរក៍ និងមួយទៀតភូមិស្តៅកោង ស្ថិតនៅឃុំឈើកាច់ ស្រុកបាភ្នំ) ដែលបានលាចាកសិក្ខាបទកាលពីគាត់អាយុ៤០ឆ្នាំ ។ គាត់មានភរិយា និងកូន៨នាក់ ប្រកបរបរជាកសិករខ្នាតធំៗមួយរូប ហើយដែលនៅតែរក្សាសីលប្រាំចាំសីល៨យ៉ាងខ្ជាប់ខ្ជួន ។ ប្រជាជនក្នុងភូមិតែងគោរពស្រឡាញ់ និងចាត់ទុកលោកជាមេគំនិត ឬជាទីប្រឹក្សាក៏កក់ក្តៅមួយរូប រាល់ពេលមានបញ្ហាតូចធំចោទឡើងក្នុងគ្រួសារក្តី ក្នុងរឿងភូមិឃុំក្តី រឿងនយោបាយក្តី សង្គ្រាមក្តី អ្នកស្រុកតែងតែទទួលស្គាល់នូវយោបល់ដ៏ក្លៃស្វាងរបស់លោក ដូចជាកាលលោកនៅជាសង្ឃដូច្នោះដែរ ។

យប់មួយក្នុងខែមករា ឆ្នាំ១៩៧២ ជាឆ្នាំដែលសង្គ្រាមប្តូរយុទ្ធសាស្ត្រពីការវាយប្រហារដោយកម្លាំងអាវុធទៅរកការវាយលុកចិត្តសាស្ត្រ និងមនោគមន៍កាន់តែស៊ីជម្រៅបំផុត បង កន និងបង គង់ បាននាំផ្លូវជូនលោកអាចារ្យ ព្រឿង ដែលជាមិត្តភក្តិចាស់របស់លោកឪពុកខ្ញុំ ដែលធ្លាប់ទេសឆ្លងឆ្លើយគ្នាកាលនៅបុព្វជិតដូចគ្នា អ្នកទាំងពីរបានលូនកាត់គ្រាប់ផ្លោង ដែលបាញ់ផ្តក់ចេញពីខេត្តព្រៃវែងរៀងរាល់យប់មករកលោកឪពុកខ្ញុំ ។ លោកឪពុកខ្ញុំបានរៀបចំបដិសណ្ឋារកិច្ចចំពោះលោកអាចារ្យ ព្រឿង និងបងជីដូនមួយខ្ញុំទាំងពីរនាក់យ៉ាងយកចិត្តទុកដាក់ ប៉ុន្តែយ៉ាងសស្ងាត់សស្ងៀត និងអាថ៌កំបាំងបំផុត ។

អ្នកម៉ែខ្ញុំបានធ្វើបបរមាន់ និងដាំតែជូនភ្ញៀវពិសេសនេះ ។ យើងបានសាកសួរយ៉ាងខ្លីអំពីរបួសរបស់បង កន ។ បង កនបង្ហាញស្នាមរបួសលើស្មាឆ្វេងរបស់គាត់កាលដែលកន្ទុំរុយបាញ់គ្រាប់រ៉ុក្កែតត្រូវគាត់នៅទួលជ្រៃកាលពីឆ្នាំ១៩៧១ ។

ម្ចាស់ផ្ទះ និងភ្ញៀវពិសេសនេះ អង្គុយជុំគ្នាពិសាបបរមាន់លើគ្រែឫស្សីក្រោមផ្ទះយើងដោយឥតមានអុចចង្កៀងទេ យើងពឹងទៅលើពន្លឺព្រះខែ បង គង់ ជាអ្នកឆ្វេលអើតមើលផ្លូវឆ្វេងស្តាំ

ការពារសុវត្ថិភាពលោកអាចារ្យ ព្រឿង និង បង កន ។

លោកអាចារ្យ ព្រឿងៈ លោកអាចារ្យ សាយ គួរណាស់តែលះបង់គ្រួសារ ទៅរួមចំណែកតស៊ូជាមួយខ្ញុំមួយរយៈសិនទៅ ដើម្បីសន្តិសុខដល់ជីវិតលោកអាចារ្យ និងម៉្យាងទៀត ដោយអង្គការកំពុងត្រូវការមនុស្សដែលមានឥទ្ធិពលទៅលើទឹកចិត្តប្រជាជនដូចលោកអាចារ្យនេះ ។

ឪពុកខ្ញុំ ៈ ចិត្តខ្ញុំស្រឡាញ់លើមាគ៌ាបដិវត្តន៍ដែលសម្បូរទៅដោយយុទ្ធជនដ៏មានគុណធម៌បរិបូរណ៍ ប្រជាជនទាំងអស់ក៏ពិតជាគិតដូចខ្ញុំដែរ តែខ្ញុំគិតថាសមរភូមិមុខត្រូវការពឹងសមរភូមិក្រោយដូចសំពៅពឹងសំប៉ាន ខ្ញុំពេញចិត្តនឹងនៅសមរភូមិក្រោយបង្កបង្កើនផលផ្គើជូនកងទ័ពសមរភូមិមុខ រៀបចំចលនាសំចៃចង់អង្ករតស៊ូរួមចំណែកជួយបដិវត្តន៍ ។ ក្រោមការប្រើប្រែងរបស់ខ្ញុំមួយឆ្នាំមកហើយ ប្រជាជនតែងក្ដាប់អង្ករដាក់ទៅក្នុងថង់មួយរាល់ពេលដាំបាយ រំលែកប្រាក់ដែលទុកទិញម្ហូបប្រចាំថ្ងៃ៥កាក់ក្ដី ១ រៀលក្ដី បង់ចូលក្នុងថង់សម្រាប់ផ្គើជូនកងទ័ព ពេលមានការប្រយុទ្ធជាប់ដៃ ប្រជាជនដាំបាយវេចខ្ចប់រួចរែកសែង លួនកាត់គ្រាប់រំសេវ យកទៅជូនកងទ័ព បើគ្មានចលករពេញទំហឹងពីខ្ញុំទេ ចលនានេះក៏មិនបានរីងប៉ឹងដូចសព្វថ្ងៃដែរ បើខ្ញុំទៅទៀត សមរភូមិមុខច្បាស់ជាពិបាកហើយ ។

ក្រោយពីការអូសទាញនោះមិនបានជោគជ័យ បង កន និងលោកអាចារ្យ ព្រឿង បានចរចាជាមួយលោកឪពុកខ្ញុំ សូមឲ្យជួយអូសទាញទាហានបន្ទាយវត្តស្ដៅឲ្យចុះចូលជាមួយទ័ពរំដោះដោយមិនចាំបាច់មានការបង្ហូរឈាម ។ ក្រោយពីពិសាបបរមាន់រួច អ្នកតស៊ូទាំងបីរូប បានរំលៀកខ្លួនលាអ្នកផ្ទះចេញទាំងកណ្ដាលអាធ្រាត្រស្ងាត់ ភូមិទាំងមូលបាត់សំឡេងឆ្កែព្រុសជាច្រើនឆ្នាំហើយ គ្មានផ្ទះណា ភូមិឃុំណាចិញ្ចឹម ឬរក្សាទុកសត្វឆ្កែទេ នេះជាផែនការតស៊ូស្ងិតស្ងួត និងល្អិតល្អន់របស់កុម្មុយនីស្ដ ។ បង កន និង បង គង់ ចាកចេញទៅដោយក្រសែភ្នែកសំឡឹងផ្ដោតមកលោកឪពុក និងមកលើខ្ញុំ ដោយគ្មានពាក្យអ្វីក្រៅពីសុំលាហើយតែប៉ុណ្ណោះ ។

ពិតមែន ខ្ញុំបានដឹងខ្លះដែរថា នៅរាត្រីខ្លះនៃការវាយឡោមព័ទ្ធទីក្រុងព្រៃវែង ឬបារាយណ៍អណ្ដែតដែលមានចម្ងាយ១០គីឡូម៉ែត្រខាងជើងភូមិខ្ញុំ ជាការវាយប្រហារដែលអ្នកស្រុកយើងមិនបារម្ភថា គ្រាប់អាចហើរមកជិតយើងនោះ ខ្ញុំដឹងថា អ្នកស្រុកយើងក្រោមការរៀបចំយ៉ាងសាមញ្ញរបស់លោកឪពុកខ្ញុំ បានប្រមូលគ្នាតាមក្រុម តាមកង នូវពំនូតជុំបាយដែលគេវេចដោយស្លឹកចេករួចចងរឹតកង់ៗជានំអន្សម បាយក្ដៅត្រូវនឹងក្លិនស្លឹកចេកស្រស់ ធំក្លិនប្រហើរ ធ្វើឲ្យយើងរមួលពោះទាំងយប់ ។ ម្ហូបសាមញ្ញដែលយើងប្រមូលជូនទ័ព គឺជាត្រីងៀតអាំង ប្រហុកដុត កូនផ្អកក្រិម ឬជាពងទាប្រៃ-សាប ជាមួយនឹងប្រាក់សំចៃ មេក្រុមខ្លះប្រមូលបានតិច ឬច្រើន គេរៀបចំតាមក្រុម និងចាត់អ្នកសែងយកស្បៀងទាំងនេះទៅជូនទ័ព ។ ជាទូទៅ គេណាត់ជួបគ្នាប្រគល់ស្បៀងទៅជូនទ័ពនៅទួលសំរោង ឬទួលបារាយណ៍អណ្ដែត ទៅតាមសហករណ៍អនុក្រោះ ។ គេគ្មានគេអូប្រើដូចខាងទាហានទេ ព័ត៌មានទំនាក់ទំនងត្រូវពឹងលើនីសារវ័យជំទង់ ឬយុវជនវ័យក្មេង ដែលធ្វើដំណើរដោយថ្មើរជើង ឬទោចក្រយានកាត់ពីភូមិឃុំមួយទៅមួយទៀត ។ នីសារនាំសំបុត្រសរសេរដៃ របស់មេបញ្ជាការទ័ពរំដោះប្រចាំតំបន់ ឬប្រចាំខេត្តស្រុកមកឲ្យរដ្ឋអំណាចរំណសិរ្សភូមិ-ឃុំ ដែលគេចាត់តាំង ។ ជាទូទៅ នៅសម័យកាលនោះ នរណាក៏ដឹងដែរ ទ័ពរំដោះក៏ដឹង ទាហានរដ្ឋាភិបាលក៏ដឹងដែរថា រដ្ឋអំណាចភូមិឃុំសុទ្ធតែក្បាលពីរ ។ ពេលណាខាងរំដោះ ពង្រីកការកាន់កាប់បានច្រើនរដ្ឋអំណាចចាំបាច់ត្រូវតែមានការងារ និងទំនាក់ទំនងជិតស្និទ្ធ ជាមួយរំដោះច្រើន ហើយពេលណាដែលខាងទាហានរដ្ឋាភិបាលបានពង្រីកផ្ទៃដីបានវិញ និន្នាការនេះ ចាំបាច់ត្រូវតែផ្លៀងផ្លងយ៉ាងគ្មានលំនឹង ។ យូរៗទៅគេនិយាយគ្នាថា ខ្មែរដូចតែគ្នា ជួនឃ្លោកលិចអម្បែងអណ្ដែត ទឹកឡើងត្រីស៊ីស្រមោចទឹកហោចស្រមោចស៊ីត្រីជាច្បាប់ធម្មជាតិ ដែលយើងមិនអាចកែប្រែវាបាន ។ ឱ! សុភាសិត បែបនេះត្រូវបានប្រើប្រាស់ ឡើងយ៉ាងផុសផុលក្នុងស្រទាប់មហាជនប្រជាជនខ្មែរ អ្នកណាក៏ចេះប្រើប្រាស់វាដែរ ពីព្រោះទិដ្ឋភាពជាក់ស្ដែងនោះ វាបង្ហាញយ៉ាងច្បាស់ ។

នៅបន្ទាយភូមិស្ដៅពេលនោះ មានទាហាន១កងអនុសេនាតូច៣០នាក់ ។ លោក ស័ក្តិ២ ហ៊ីន មេបញ្ជាការកងអនុសេនាតូចរូបនោះ ទំនងជាដឹងច្បាស់ថា លោកឪពុកខ្ញុំ ជាមេបណ្ដាញសំខាន់នៃចលនារំដោះប្រចាំភូមិឃុំនេះ លោកបង្កើតទំនាក់ទំនងជិតស្និទ្ធណាស់ជាមួយលោកឪពុកខ្ញុំ លោកទទូចសុំតែម៉្យាង ឲ្យជួយប្រាប់

*លោក ប្រសិនបើដឹងថា ថ្ងៃណាមួយទ័ពរំដោះចង់វាយប្រហារលោកនឹងមិនដឹកនាំឲ្យមានការតតាំងទេ តែដើម្បីរក មធ្យោបាយដកទ័ពថយ ឬទម្លាក់អាវុធចុះចូល ។*

*យប់មួយ នៅចុងខែមករា ឆ្នាំ១៩៧២ ខ្ញុំកំពុងនិទ្រាលក់ប្រមាណម៉ោង១២អធ្រាត្រ ស្រាប់តែស្នូរផ្ទុះអាវុធប្រកបដោយគ្រាប់ភ្លើងហើរព្រោងព្រាត និងពន្លឺព្រាកៗ ច្រាចៗ ឡើងទៅលើនៅជុំវិញបន្ទាយទាហានវត្តខ្ញុំ ។ យើងស្ដាប់ដឹងថា មានការបាញ់ចូលយ៉ាងច្រើន ប៉ុន្តែការបាញ់ចេញមានតិចតួច របៀបដូចជាមានការក្រញិបចូលចាប់យ៉ាងងាយ ហើយគ្រាប់ស្ទើរទាំងអស់សុទ្ធតែបាញ់បង្ហើរឡើងលើ ។ ប្រមាណម៉ោង១ទៀបភ្លឺ យុទ្ធជននៃទាហានរដ្ឋាភិបាលប្រចាំការនៅវត្តស្ដៅទាំងអស់ អ្នកខ្លះមានទាំងភរិយា និងកូន តូចមកជាមួយផង ត្រូវបានកងទ័ពរំដោះនាំដើរកាត់ផ្លូវធ្លាក្រោយផ្ទះខ្ញុំ ចុះទៅលិចទំនងជាតម្រង់ទៅភូមិពាមស្ដី ឬអន្លង់ទ្រា ឬជ្រោយជ្រៃ យើងមិនច្បាស់ទេ ប៉ុន្តែយើងជឿថា ពួកគាត់ត្រូវគេនាំទៅរស់នៅភូមិណាមួយនៃតំបន់រំដោះ ។ ខ្ញុំបានឮច្បាស់នូវសម្រែករបស់ភរិយាលោកស័ក្តិ២ ហឹម សេហុកងអនុសេនាតូច ដែលអំពាវនាវ ដោយក្ដីភិតភ័យថា បង ប្អូនអ្នកស្រុកអើយ សូមជួយមើលសុខទុក្ខយើងខ្ញុំផង ។*

*ពីមុនការបាញ់ប្រហារគ្នា រវាងខ្មែរ និងខ្មែរ ដូចជាមានចរិតសាហាវស៊ីសាច់ហុតឈាមគ្នា តែចូលឆ្នាំទី៣ ទ័ពរំដោះពោរពេញដោយមោទកភាពនៃការមើលឃើញជោគជ័យ សង្គ្រាមលើដីគោកលើទឹក សង្គ្រាមអាកាសរបស់មហាយក្សចក្រពត្តិថយរិទ្ធិទៅ ហើយទាហានរដ្ឋាភិបាលលែងមានទឹកចិត្តប្រយុទ្ធទាល់តែសោះ រាល់ការប្រយុទ្ធ គេបាញ់តយ៉ាងរបេះរបោះទំនងជាគ្រាន់តែដោះស្រាយឲ្យរួចពីការព្រមាន ឬការធ្វើទារុណកម្មពីមេកើយគេប៉ុណ្ណោះ ។ មេទាហានរដ្ឋាភិបាល ក៏ទំនងជារអានឹងទ័ពរំដោះខ្លាំងហើយ គេដេកព្រួយ អង្គុយព្រួយ បន់ស្រន់សុំតែសេចក្ដីសុខ មេទាហានខាងរដ្ឋាភិបាលបំភ័យដោយចិត្តសាស្ត្រថា យៀកកុងនឹងវះពោះប្រកស្មោ បើសិននាយទាហាន ពលទាហានណាហ៊ានរត់ទៅចុះចូល ។*

*យៀកកុង ឬវៀតកុងជាឈ្មោះទ័ពវៀតណាមខាងជើងដែលជាសម្ព័ន្ធមិត្តរបស់ទ័ពរំដោះចូលមកជួយវាយបណ្ដេញចក្រពត្តិអាមេរិក ដែលប្រើប្រាស់កងទ័ពវីកយ៉ា ឬវៀតណាមខាងត្បូងជាកងកម្លាំងរបស់ខ្លួន ។ ប៉ុន្តែជាទូទៅទាហានរដ្ឋាភិបាលប្រើពាក្យយៀកកុងនេះ សម្រាប់ហៅទ័ពខ្មែររំដោះទូទៅ ក្នុងន័យប្រមាថមើលងាយ ពីព្រោះគេជឿជាក់ថា ក្បាលម៉ាស៊ីនរបស់ខ្មែររំដោះ ឬខ្មែរក្រហមនេះ គឺមានប្រភពមកពីកុម្មុយនីស្ដយៀកណាមខាងជើងនេះឯង ។ ឯពាក្យថា វីកយ៉ា វិញ គឺជាពាក្យប្រមាថមើលងាយរបស់ទ័ពរំដោះទៅលើកងទាហានយៀកណាមខាងត្បូងដែលស៊ីជំនួយ ឬស៊ីឈ្នួលចក្រពត្តិអាមេរិក ចូលមកជួយវាយបណ្ដេញយៀកកុង និងខ្មែរក្រហមនេះដែរ ។ នៅក្នុងអំឡុងចុងឆ្នាំ១៩៧១ ដោយទ័ពវីកយ៉ាបង្កវិនាសកម្មធ្ងន់ធ្ងរពេកទៅលើប្រជាពលរដ្ឋខ្មែរតាមព្រំដែនវៀតណាម ជាពិសេស ខេត្តស្វាយរៀង និងព្រៃវែង នេះឯង សម្ដេចព្រះនរោត្តមសីហនុ បានប្រកាសដេញទ័ពវីកយ៉ាឲ្យចាកចេញ ហើយខាងរណសិរ្សសេរីកាជាតិក៏ប្រកាសធ្វើមាតុភូមិនិវត្តន៍កងទ័ពវៀតកុងនេះទៅវិញដែរ ។ ទន្ទឹមនឹងពេលនោះ លោកប្រធានាធិបតី លន់ នល់ ក៏ប្រកាសធ្វើមាតុភូមិនិវត្តន៍ទាហានវៀតណាមខាងត្បូងដូចគ្នាដែរ ។ ព្រឹត្តិការណ៍នេះ ធ្វើឲ្យប្រជាពលរដ្ឋខ្មែរជឿជាក់មួយទៀតថា រវាងសម្ដេចឪ និងលោក លន់ នល់ គឺជាផែនការតែមួយ ហើយជឿថា ខ្មែរធ្វើសង្គ្រាមដើម្បីរកដំណោះស្រាយវិបត្តិនយោបាយខ្មែរ ដើម្បីរក្សាកិត្យានុភាព បូរណភាពដែនដី និងឯករាជ្យភាពរបស់ខ្មែរ ។ នេះជាស្មារតីសុទិដ្ឋិរបស់កសិករខ្មែរ ចំពោះសម្ដេចព្រះនរោត្តម សីហនុ និងចំពោះមូលហេតុបុព្វហេតុនៃសង្គ្រាម១៩៧០-៧៥នោះ ។*

*តាំងពីថ្ងៃមានការចុះចូលក្រោមរូបភាពបាញ់ពព្រុះពព្រះបន្តិចបន្តួចនោះមកពុំមានការដាក់ទាហានមកបន្ទាយវត្តស្ដៅវិញទេ ទាហានរដ្ឋាភិបាលបានរះសឺម៉ង់ចូលមកនៅពេលព្រឹក និងត្រឡប់ទៅព្រែកណ្ដៀងវិញនៅពេលរសៀល ។*

*រសៀលមួយនេះ ដោយមានអ្នកគោរពស្រឡាញ់ទាំងសង្ខាង លោកឪពុកខ្ញុំពុំបានទទួលព័ត៌មានជាមុនអំពីការប៉ុនប៉ងចាប់ខ្លួនលោកដោយទាហាន លន់ នល់ ។ លោកឪពុក បានភៀសខ្លួនចេញពីផ្ទះតែម្នាក់ឯង នៅពេលព្រលប់ទៅតំបន់រំដោះមួយរយៈ ។*

**(តទៅលេខក្រោយ)**

**អ៊ុខ ខណ្ណា**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល : truthpdara@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ : ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 217, January 2018 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.